00801357

E1/63.1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 19-Apr-2012, 14:45
CMS/CFO: Kauv Keoratanak

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២**

**ម៉ោង ០៩:០៦ នាទី**

**សវនាការលើកទី៥១**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍

*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)

*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

កញ្ញា ណាតាចា វីស៊ែល រីសឺ

*(Ms. Natacha WEXELS-RISER)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល

*(Mr. Vincent de wilde d'ESTMAEL)*

លោក ឌេល លីសាក់ (*Mr. Dale LYSAK*)

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ហ្សាស្ពើ ប៉ៅ(*Mr Jasper PAUW)*

លោក អេនឌ្រូ អ៊ីនូហ្ស៊ី

*(Mr. Andrew IANUZZI)*

លោក វិចទ័រ កូប៉េ(*Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោកស្រី អង់តា ហ្គីសសេ

*(Ms. Anta GUISSÉ)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី ទី ស្រីនណា

លោក ហុង គីមសួន

លោក វ៉ែន ពៅ

លោក ឡោ ជុនធី

លោកស្រី ម៉ុច សុវណ្ណារី

លោក សំ សុគង់

លោក បាណាបេ ណេគ្វី

*(Mr. Barnabé NEKUIE)*

លោកស្រី អេលីហ្សាប៉ែត រ៉ាបេសាន់ដ្រាតាណា

*(Ms. Elisabeth RABESANDRATANA)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក សេង ប៊ុនឃាង | ខ្មែរ |
| លោក សុន អរុណ | ខ្មែរ |
| លោក ហ្សាស្តេី ប៉ៅ | អង់គ្លេស |
| លោក អេនឌ្រូ អ៊ីនូហ្ស៊ី | អង់គ្លេស |
| លោក អាង ឧត្តម | ខ្មែរ |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក នួន ជា | ខ្មែរ |
| លោក សួត្រ ទឿង (TCW-617) | ខ្មែរ |
| លោក លឹម ប៊ុនហេង (មេធាវីតំណាងរបស់សាក្សី) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី ៖ លោក សុត្រ ធឿន** (TCW-617)


សួរដោយប្រធានអង្គជំនុំ ផ្ដើមពី៖ ....................ទំព័រ ១០

សួរដោយលោក សេង ប៊ុនឃាង ផ្ដើមពី៖ ....................ទំព័រ ១៧

សួរដោយលោក ខេល លីសាក់ ផ្ដើមពី៖ ....................ទំព័រ ៤៧

# កិច្ចដំណើរការនីតិវិធី

[០៩:០៦:០០]

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ កិច្ចដំណើរការសវនាការនៅថ្ងៃនេះ នឹងចាប់ផ្ដើមដោយការស្ដាប់នូវសេចក្ដីថ្លែងការណ៍របស់ជនជាប់ចោទ នួន ជា ចំពោះការផ្ដល់សក្ខីកម្មរបស់សាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច ដែលបានធ្វើរយៈកាលកន្លងមក នៅមុនចូលឆ្នាំខ្មែរ ហើយនិងកិច្ចដំណើរបន្ទាប់ទៀតនោះគឺ នឹងបន្តនីតិវិធីដោយការសួរចម្លើយជនជាប់ចោទ នួន ជា ដោយអង្គជំនុំជម្រះ ប្រសិនបើជនជាប់ចោទអនុវត្តនូវសិទ្ធិឆ្លើយតបទៅនឹងសំណួរ ដែលនឹងសួរដេញដោលដោយអង្គជំនុំជម្រះ ឬដោយភាគី។

[០៩:០៧:២០]

ហើយក្នុងករណីនេះ អង្គជំនុំជម្រះក៏បានគ្រោងផងដែរ នឹងបន្តដោយការស្ដាប់សក្ខីកម្មរបស់សាក្សី ដែលអង្គជំនុំជម្រះបានជម្រាបជូនភាគីរួចហើយ ក្នុងករណីជនជាប់ចោទ នួន ជា រក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតប។

ក្រឡាបញ្ជីឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះហៅចូលរួមនៅក្នុងកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

លោកស្រី សែ កុលវុឌ្ឍី!

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន ស្ថានភាពវត្តមាន និងអវត្តមានភាគីដែលត្រូវបានអញ្ជើញចូលរួមនៅក្នុងសវនាការថ្ងៃនេះមានដូចតទៅ៖ តំណាងសហព្រះរាជអាជ្ញាមានវត្តមានគ្រប់ចំនួន។ ជនជាប់ចោទលោក នួន ជា លោក អៀង សារី ហើយនិងលោក ខៀវ សំផន មានវត្តមាន។ ក្រុមមេធាវីការពារឲ្យជនជាប់ចោទលោក នួន ជា មានវត្តមាន។ ក្រុមមេធាវីការពារឲ្យជនជាប់ចោទលោក អៀង សារី មានវត្តមានតែមេធាវីជាតិ និងក្រុមមេធាវីការពារឲ្យជនជាប់ចោទ ខៀវ សំផន មានវត្តមាន។ មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានវត្តមានគ្រប់ចំនួន។ ដោយឡែកសាក្សីដែលត្រូវមកផ្ដល់សក្ខីកម្មនៅ

ក្នុងថ្ងៃនេះ សាក្សី TC-617 មានវត្តមាន រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ សាក្សីរូបនេះមិនមានជាប់ចំណងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទណាមួយ ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។ សាក្សីបានធ្វើសម្បថរួចហើយ។

[០៩:០៨:៥៨]

**ប្រធានអង្គជំនុំ៖**

អរគុណ។

អនុរក្សមន្ទីរឃុំឃាំងឲ្យនាំលោក នួន ជា មកកាន់ឈើរាងរង់ក្រចកសេះនៅចំពោះមុខអង្គជំនុំជម្រះនេះ!

**លោក ហ្សាស្តេ ប៉ោ៖**

លោកប្រធាន សូមជម្រាបសួរចៅក្រម លោកប្រធាន ហើយនិងភាគីទាំងអស់ ហើយនិងសាធារណជនផងដែរ។ ខ្ញុំមានមតិខ្លីៗពីរបីដើម្បីជម្រាបតុលាការ មុននឹងផ្តល់វេទិកាចោទសួរលោក នួន ជា។ ខ្ញុំសូមអនុញ្ញាតពេលតែពីរនាទីតែប៉ុណ្ណោះ។ យើងបានទទួលអ៊ីម៉ែលពីមន្ត្រីច្បាប់ជាន់ខ្ពស់ថា យើងមិនត្រូវបានអនុញ្ញាតឲ្យធ្វើសេចក្តីសន្និដ្ឋានទេព្រឹកនេះ។ ហើយតាមពិតយើងនឹងគោរពទៅតាមការសម្រេចបែបនោះ ហើយយើងនឹងមិនធ្វើនូវសេចក្តីសន្និដ្ឋានដូចដែលយើង-- ផែនការនឹងធ្វើនោះទេ។

[០៩:០៩:០២]

ដើម្បីកត់ត្រាក្នុងកំណត់ហេតុតុលាការនោះ គឺថាយើងខ្ញុំសូមបញ្ជាក់ថា សេចក្តីសន្និដ្ឋាននឹងលើកឡើងនូវបញ្ហាសំខាន់ៗនៅក្នុងសវនាការក្នុងការតាំងសំណួរទៅសាក្សី ឌុច។ ជាពិសេស ការព្រួយបារម្ភទាក់ទងទៅនឹងការជំនុំជម្រះដោយយុត្តិធម៌ ហើយនិងបើកឲ្យសាធារណជនបានជ្រាបអំពីអ្វីដែលយើងនឹងលើកឡើង។ ហើយយើងយល់ថាសវនាការសាធារណៈ គឺទាក់ទងទៅនឹងការបំពានសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់កូនក្តីខ្ញុំ ហើយគប្បីធ្វើជាសាធារណៈ។ ហើយមិនត្រឹមតែអាស្រ័យទៅលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរប៉ុណ្ណោះទេ។ ដូច្នេះហើយ យើងនឹងធ្វើសេចក្តីសន្និដ្ឋាននេះបន្ទាប់ពីការតាំងសំណួរទៅលោក នួន ជា។ សូមគោរពតុលាការ បាទ។

[០៩:១១:០៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក នួន ជា ដោយមុននឹងចាប់ផ្តើមកិច្ចដំណើរការសវនាការស្តាប់សក្ខីកម្មសាក្សី

កាំង ហ្គេកអ៊ាវ ហៅ ឌុច។ លោកមានបំណងនៅក្នុងការធ្វើសេចក្តីថ្លែងការណ៍ពាក់ព័ន្ធនឹងការផ្តល់សក្ខីកម្មរបស់សាក្សីរូបនោះ ប៉ុន្តែដោយនីតិវិធីមិនអាចធ្វើដូច្នេះបាន អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យលោកធ្វើពីដំបូងនោះទេ។ អង្គជំនុំជម្រះបានសន្យាជាមួយលោកថា នឹងអនុញ្ញាតឲ្យលោកធ្វើសេចក្តីថ្លែងការណ៍ក្រោយពេលសាក្សី កាំង ហ្គេកអ៊ាវ ហៅ ឌុច បានបញ្ចប់នូវការផ្តល់សក្ខីកម្មរបស់ខ្លួននៅចំពោះមុខអង្គជំនុំជម្រះ។ ប៉ុន្តែដោយសារពេលវេលានៅថ្ងៃចុងបញ្ចប់នៃសវនាការមុនពេលចូលឆ្នាំខ្មែរនោះ គឺពេលវេលាអត់អំណោយផលនៅក្នុងការផ្តល់វេទិកាជូនទៅលោក ដើម្បីឲ្យលោកធ្វើសេចក្តីថ្លែងការណ៍។ ដូច្នេះហើយបានជាអង្គជំនុំជម្រះ លៃពេលវេលាដំបូងនៃកិច្ចដំណើរការសវនាការព្រឹកនេះ ដើម្បីផ្តល់ឱកាសជូនទៅលោក ដើម្បីឲ្យលោកមានឱកាសក្នុងការធ្វើសេចក្តីថ្លែងការណ៍ ឬក៏ធ្វើការសង្កេតទៅលើការផ្តល់សក្ខីកម្មដោយសាក្សីឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច។

សូមអញ្ជើញលោក នួន ជា!

[០៩:១២:២៩]

**លោក នួន ជា៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងបងប្អូនរួមជាតិជាទីគោរព។ ខ្ញុំមានមតិខ្លីទេ តែជាមតិពិត និងយុត្តិធម៌។ ខ្ញុំសូមប្រកាសជូនបងប្អូនប្រជាជនខ្មែរទាំងអស់ថា ខ្ញុំមិនដែលមានពេលណាមួយនោះ ទទួលខុសត្រូវលើមន្ទីរ ស-២១ នោះទេ។ អ្វីដែល ឌុច និយាយចោទប្រកាន់មកលើរូបខ្ញុំ គឺជាការភូតបំផ្លើសការពិត និងអយុត្តិធម៌មកលើរូបខ្ញុំប៉ុណ្ណោះ។ ខ្ញុំមិនដែលបញ្ជា ឬទទួលឯកសារស្អីទេពី ឌុច ហើយខ្ញុំក៏មិនដែលជាមេរបស់ ឌុច នោះដែរ។ ឌុច ជាមនុស្សពូកែខាងវោហារដ៏មានបទពិសោធន៍ណាស់តាមរយៈសវនាការកន្លងមក។ ឌុច មានការភ័ន្តច្រឡំ វិលវល់ មិនអាចកំណត់ចំណារឲ្យបានច្បាស់លាស់ នោះគាត់កែច្នៃចំណាររបស់ ប៉ុល ពត ថាជារបស់ខ្ញុំ។

ខ្ញុំសូមស្នើអង្គជំនុំជម្រះច្រានចោលនូវការចោទប្រកាន់ទាំងប៉ុន្មានរបស់ ឌុច មកលើរូបខ្ញុំ។ បើ ឌុច មានចំណាររបស់ខ្ញុំមែន សូមឲ្យ ឌុច យកមកបង្ហាញខ្ញុំចំពោះមុខតុលាការ។ ខ្ញុំ-- ពេលនេះទេ។ សូមអរគុណលោកប្រធាន។

[០៩:១៤:៥២]

**ប្រធានអង្គជំនុំ៖**

ចុះលោក នួន ជា តើលោករក្សាសិទ្ធិមិនឆ្លើយតបទៅនឹងសំណួរពីភាគីនានា។ ចុះសំណួររបស់

អង្គជំនុំជម្រះដែលគ្រោងនឹងតាំងសួរលោកឥឡូវនេះ តើលោកឆ្លើយតបទៅនឹងសំណួររបស់អង្គជំនុំជម្រះដែរឬទេ?

**លោក នួន ជា៖**

គោរពលោកប្រធាន ខ្ញុំស្តាប់មិនច្បាស់ទេ។

**ប្រធានអង្គជំនុំ៖**

អំមិញនេះយើងស្តាប់បានហើយ លោកបានបង្ហាញថា ជំហរច្បាស់លាស់ថា លោកនឹងមិនឆ្លើយតបចំពោះសំណួរទាំងឡាយដែលនឹងសួរលោក ដោយភាគីនានានៃរឿងក្តីនេះទេ។ ប៉ុន្តែ នៅក្នុងអង្គសវនាការនេះ អង្គជំនុំជម្រះមិនមែនភាគីទេ គឺជាអង្គជំនុំជម្រះដែលភាគីត្រូវធ្វើការបង្ហាញភស្តុតាងឲ្យដល់អង្គជំនុំជម្រះស្តាប់ ដើម្បីពិចារណាសម្រេចសេចក្តីនៅទីបញ្ចប់។ អ៊ីចឹងដោយសារលោកបានលើកឡើងអំមិញ គឺអត់មានលក្ខខណ្ឌថា នឹងរក្សាមិនឆ្លើយតបនឹងការតាំងសំណួរដោយអង្គជំនុំជម្រះទេ។ លោកកម្រិតត្រឹមតែថា មិនឆ្លើយតបទៅនឹងសំណួរដែលនឹងសំណួរដោយភាគី។

ចុះបើសិនជាអង្គជំនុំជម្រះតាំងសំណួរចំពោះលោកវិញ តើលោករក្សាសិទ្ធិនៅស្ងៀមឆ្លើយតបដែរ ឬក៏លោករក្សាសិទ្ធិក្នុងការឆ្លើយតប? ពីព្រោះយើងប្រាប់អម្បាញ់មិញហើយថា នីតិវិធីសវនាការសម្រាប់ថ្ងៃបន្ទាប់ពីស្តាប់សេចក្តីថ្លែងការណ៍ទៅលើការផ្តល់សក្ខីកម្មរបស់ ឌុច កន្លងមកនេះ អង្គជំនុំជម្រះនឹងបន្តការសួរសំណួរចំពោះលោកទៅលើអង្គហេតុនៃវគ្គពីរ សម្រាប់សំណុំរឿង០០២/០១។

[០៩:១៦:៥៣]

ឥឡូវនេះ តើលោករក្សាសិទ្ធិក្នុងការឆ្លើយតបទៅនឹងសំណួររបស់អង្គជំនុំជម្រះ ដែលនឹងសួរលោកបន្តិចទៀតនេះដែរឬទេ? ឬក៏លោករក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបដែរ ចំពោះការតាំងសំណួររបស់អង្គជំនុំជម្រះ?

**លោក នួន ជា៖**

ជម្រាបលោកប្រធាន ខ្ញុំសូមពិភាក្សាជាមួយមេធាវីខ្ញុំសិន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

អនុរក្សមន្ទីរឃុំឃាំងអាចដកថយ ដកខ្លួនថយចេញដើម្បីឲ្យទុកឱកាសឲ្យមេធាវី និងជនជាប់ចោទអាចពិភាក្សាគ្នាដោយសម្ងាត់។

*(មេធាវី និងជនជាប់ចោទពិភាក្សាគ្នា)*

[០៩:១៨:៣៥]

បើក១ បើកក្បាលមីក្រូបាទ!

**លោក នួន ជា៖**

ខ្ញុំសូមគោរពលោកប្រធាន ខ្ញុំសូមរក្សាសិទ្ធិនៅស្ងៀម។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងលោករក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតប សូម្បីតែអង្គជំនុំជម្រះ ចៅក្រមនៃអង្គជំនុំជម្រះក៏ដោយ អ៊ីចឹងមែនទេ?

**លោក នួន ជា៖**

ចាំខ្ញុំពិភាក្សាជាមួយមេធាវីខ្ញុំសិន។

[០៩:១៩:១៤]

**ប្រធានអង្គជំនុំ៖**

អំមិញពិភាក្សាហើយ? ពិភាក្សាទៀត? ឥឡូវចាំស្ដាប់សំណួរយើងចុងក្រោយ។ អំមិញគឺអង្គជំនុំជម្រះស្ដាប់បាននូវសម្ដីរបស់លោក ទីមួយ គឺថាលោកបានប្រកាសថា លោកនៅស្ងៀមមិនឆ្លើយតបចំពោះសំណួរដែលនឹងសួរដោយភាគី ហ្នឹងអង្គជំនុំជម្រះយល់ហើយ។ បន្ទាប់មកទៀត អង្គជំនុំជម្រះសួរថា ចុះអង្គជំនុំជម្រះដែលនឹងសួរលោក តើលោករក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតប ឬក៏លោកឆ្លើយតបនឹងទៅនឹងសំណួរដែលអង្គជំនុំជម្រះនឹងសួរ? ពីព្រោះសវនាការថ្ងៃនេះ គឺនឹងបន្តនីតិវិធីដោយការសួរតាំងសំណួរជាក់លាក់ចំពោះលោកដោយអង្គជំនុំជម្រះ។ អំមិញលោកបាននិយាយថា លោករក្សាសិទ្ធិនៅស្ងៀម។ អង្គជំនុំជម្រះចង់ដឹង ថាតើរក្សាសិទ្ធិនៅស្ងៀមចុងក្រោយនេះ នៅស្ងៀមមិនឆ្លើយតប ជាមួយនឹងសំណួររបស់អង្គជំនុំជម្រះដែលសួរលោក ឬយ៉ាងម៉េច?

**លោក នួន ជា៖**

គោរពលោកប្រធាន ខ្ញុំសូមរក្សាសិទ្ធិនៅស្ងៀម។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើន ដោយសារបង្ហាញជំហររួចហើយ។

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម។ ខ្ញុំបង្ហាញជំហររបស់យើងខ្ញុំនៅពេលនេះម្តងទៀតថា សំណើមួយចំនួនដែលរង់ចាំការសម្រេច។ ហើយយើងឃើញថាជាជំហររបស់លោក នួន ជា បានធ្វើហ្នឹង គួរឲ្យសង្ស័យដែលថា ថាគាត់នឹងធ្វើសេចក្តីថ្លែងការណ៍ព្រឹកនេះ ហើយៗគាត់នឹងត្រូវតាំងខ្លួនឲ្យទទួលនូវសំណួរសួរ។ ប៉ុន្តែពេលដែលគាត់ធ្វើសេចក្តីថ្លែងការណ៍ហើយ គាត់បដិសេធមិនឆ្លើយតបនូវសំណួររបស់ភាគី រួមទាំងចៅក្រមផងដែរ។

[០៩:២១:៣១]

ជំហរនៅពេលនេះ ខ្ញុំមិនយល់ថាជាការសមស្របទេ គឺថាឲ្យគាត់ថ្លែងពីជំហររបស់គាត់ទៅតុលាការថា គាត់មិនៗ-- បាទប្រកាន់ជំហរមិនឆ្លើយ ហើយគាត់បដិសេធសក្ខីកម្មរបស់សាក្សីថាជាការកុហក ហើយសូមជម្រាបតុលាការថា ការអះអាងរបស់គាត់នេះមិនមានទម្ងន់អ្វីគួរឲ្យជឿជាក់នោះទេ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការរៀបរយ ណ៎! គាត់អត់ស្តាប់សំឡេងបកប្រែជាភាសាខ្មែរបានទេ។ ពិនិត្យមើល៍ អាចអស់ថ្ម។ ឧបករណ៍ហ្នឹង ឧបករណ៍ស្តាប់សំឡេងហ្នឹង ស្តាប់មិនបានផង។

នួន ជា អត់ៗ លោកស្តាប់មិនបានទាំងស្រុងអម្បាញ់មិញនេះ ដែលនិយាយដោយតំណាងសហព្រះរាជអាជ្ញាអន្តរជាតិអំមិញនេះ លោកស្តាប់មិនបានទាំងស្រុង មែនទេ?

**លោក នួន ជា៖**

ខ្ញុំបាទស្តាប់មិនបានទាំងស្រុងទេ។

[០៩:២៣:០៥]

**ប្រធានអង្គជំនុំ៖**

បាទៗ ឡូវនេះ សូមលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ធ្វើការបង្ហាញនូវជំហររបស់ខ្លួនសាជាថ្មី។

**លោក ឌេល លីសាក់៖**

បាទ លោកប្រធាន ខ្ញុំនឹងបញ្ជាក់ឡើងវិញ។ ដូចដែលខ្ញុំបានជម្រាប ហើយមានសំណើដែលរង់ចាំការសម្រេច ហើយគឺជាទម្លាប់អនុវត្តមួយដែលមិនអាចទទួលយកបានទេ ដែលជនជាប់ចោទគាត់រក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតប ហើយគាត់បានធ្វើសេចក្តីថ្លែងការណ៍ ថាគាត់មិនធ្វើការងារអ្វីនោះទេ

ហើយគាត់មិនមានអ្វីពាក់ព័ន្ធនឹង ស-២១ ទេ អ្នកចោទប្រកាន់ខ្ញុំឈ្មោះ ឌុច នោះ គឺជាអ្នកកុហក។ ការដែលធ្វើការអះអាងបែបនេះ ហើយនិងបដិសេធមិនឆ្លើយនូវសំណួរផ្សេងៗ នេះគឺជាករណីមួយ។

[០៩:២៤:០៦]

តាមសំណើរបស់យើងខ្ញុំ គឺវាមានផលវិបាកមួយ កាលណាជនជាប់ចោទដោះសានៅក្នុងករណីបែបនេះ ហើយគឺមិនមានអ្វីគួរថ្លឹងថ្លែងជាការកំណត់នូវភស្តុតាងនោះទេ។ ការអះអាងរបស់គាត់។ នេះហើយ នៅក្នុងសំណើរបស់យើងខ្ញុំនោះ គឺថាគប្បីតែតុលាការប្រើការបកស្រាយបែបអវិជ្ជមានប្រឆាំងនឹងរូបគាត់ នៅក្នុងករណីដែលគាត់នៅស្ងៀមបែបនេះ។ ចំណុចសំខាន់ ដែលថាជនជាប់ចោទបានដឹងហើយ ថាយើងនឹងពិនិត្យលើបញ្ហានេះឡើងវិញ បន្ទាប់ពីមានការសម្រេចពីអង្គជំនុំជម្រះនៅលើសំណើរបស់យើងខ្ញុំ។ ហើយនៅពេលមួយ ជនជាប់ចោទអាចនឹងពិចារណាជំហររបស់គាត់ នឹងឆ្លើយសំណួររបស់ភាគី ហើយៗយើងខ្ញុំនឹងកត់ត្រានូវសំណួរមួយចំនួន ដែលថាសំណួរណាដែលជនជាប់ចោទដែលគាត់មិនឆ្លើយតបនោះ។

ខ្ញុំជម្រាបតុលាការថា ពេលវេលាដែលយើងខ្ញុំធ្វើបែបនោះ គឺរហូតទាល់តែអង្គជំនុំជម្រះបានសម្រេចលើសំណើរបស់យើងខ្ញុំ។ សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រមបាទ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ។ សូមអញ្ជើញ មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោក សុន អរុណ៖**

ខ្ញុំអាចឆ្លើយតបទៅព្រះរាជអាជ្ញាសិនបានទេ?

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន លោក លោកស្រីចៅក្រម សូមជម្រាបសួរភាគីទាំងអស់។ ជាដំបូងតាងនាមឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្នុង-- ឲ្យយើងបង្ហាញអំពីការមិនសប្បាយចិត្ត ពាក់ព័ន្ធទៅនឹងបញ្ហាច្បាប់។ លោក នួន ជា គាត់បានធ្វើសេចក្តីថ្លែងការណ៍ គាត់បានចេញពីភាពស្ងៀមស្ងាត់និយាយពាក្យមួយចំនួននៅក្នុងសេចក្តីថ្លែងការណ៍របស់គាត់ ហើយបន្ទាប់មកគាត់ត្រឡប់ទៅជាមិននិយាយ ចូលទៅភាពស្ងៀមស្ងាត់វិញ។

[០៩:២៥:៥៩]

ដូច្នេះបញ្ហាដែលចោទឡើងនៅទីនេះ ថាតើ ហេតុអីបានជាមានលទ្ធភាពមានច្បាប់បែបនេះក្នុងការធ្វើសេចក្តីថ្លែងការណ៍នៅពេលដែលគាត់ចង់ ហើយបន្ទាប់មកគាត់លែងនិយាយវិញ។ តើមានលក្ខខណ្ឌច្បាប់បែបណាដែលអនុញ្ញាតឲ្យគាត់បានធ្វើនេះ ហើយមានវិធានផ្ទៃក្នុងមានចែងអំពីលទ្ធភាពនៃអាកប្បកិរិយាបែបនេះដែរឬទេ?

ក្រៅពីនេះទៀត លោក នួន ជា បានគិតថា គាត់អាចដកខ្លួនចេញពីការប្រឈមមុខដាក់គ្នា ហើយគាត់រក្សាភាពស្ងៀមស្ងាត់ ហើយគាត់មិនបានតទល់ជាមួយនឹងសាក្សី។ ដូច្នេះ សវនាការយុត្តិធម៌មិនមែនត្រឹមតែគោរពសិទ្ធិរបស់មេធាវីការពារក្តីនោះទេ គឺត្រូវតែគោរពសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែរ ជាសិទ្ធិរបស់ប្រជាជនកម្ពុជាទាំងអស់គ្នា។ ហើយប្រសិនបើលោក នួន ជា នៅតែបន្តធ្វើរបៀបនេះនៅពេលដែលគាត់ចង់នោះ ដោយមិនឆ្លើយទៅនឹងសំណួរបែបនេះ គាត់មិនគោរពទៅនឹងគោលការណ៍នៃសវនាការយុត្តិធម៌នោះទេ ហើយយើងមានវិធាន២១ នៃវិធានផ្ទៃក្នុងរបស់យើងផងដែរ។

[០៩:២៧:១៥]

ហើយខ្ញុំសូមបន្ថែមទៀតថា លោក នួន ជា មិនមែនជាមនុស្សតែម្នាក់ទេដែលរក្សាសិទ្ធិមិនឆ្លើយតបនៅទីនេះនោះ។ ដូច្នេះអ្វីៗត្រូវតែមានភាពច្បាស់លាស់។ សិទ្ធិក្នុងការរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបនោះមិនមែនថា មិនមែនជាសិទ្ធិនៅក្នុងច្បាប់ខំមិនឡូទេ វាជាសិទ្ធិនៅក្នុងច្បាប់ស៊ីវិលឡូ។ នៅពេលដែលជនជាប់ចោទនិយាយនោះ គាត់និយាយដោយសម្បថនៅក្នុងច្បាប់ខំមិនឡូ។ នៅទីនេះ គាត់មិននិយាយដោយការស្បថទេនៅក្នុងច្បាប់ស៊ីវិលឡូនេះ។

[០៩:២៧:៥៥]

ដូច្នេះសិទ្ធិក្នុងការរក្សាភាពស្ងៀមស្ងាត់នេះ មិនមែនជាសិទ្ធិដាច់ខាតនៅទីនេះទេ។ ហើយវាហួសពីលក្ខណៈយុត្តិធម៌នៃសវនាការ ហើយវារំលោភទៅនឹងសិទ្ធិរបស់ភាគីក្នុងការតទល់ទៅនឹងជនជាប់ចោទ។ ដូច្នេះសិទ្ធិនេះ គឺជាសិទ្ធិតាមទំនើងចិត្ត ហើយគាត់ធ្វើអ្វីតាមចិត្តរបស់គាត់ ដើម្បីតែផលប្រយោជន៍គាត់ គឺមិនទទួលយកនូវការជំទាស់ទៅនឹងគាត់។ ដូច្នេះ អង្គជំនុំជម្រះនៅពេលអនាគតនោះ មិនគួរនឹងអនុញ្ញាតឲ្យមានសិទ្ធិក្នុងការរក្សាភាពស្ងៀមស្ងាត់បែបនេះទេ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ សូមអញ្ជើញលោកមេធាវីការពារក្តីលោក នួន ជា!

[០៩:២៨:៤១]

**លោក សុន អរុណ៖**

សូមគោរពអង្គសវនាការ សូមគោរពលោកប្រធានសាជាថ្មី។ ខ្ញុំសូមឆ្លើយសរុបទៅទាំងព្រះរាជអាជ្ញា ទាំងដើមបណ្ដឹងរដ្ឋប្បវេណី។ លោក នួន ជា សុំសិទ្ធិឆ្លើយធ្វើសុន្ទរកថានៅពេលខ្លីថា ប្រាំទៅដប់ប្រាំនាទីតាំងពីមុនដំបូងបើកសវនាការ ឌុច បើកការសាកសួរ ឌុច ប៉ុន្តែដោយការមិនអនុញ្ញាតពីលោកប្រធាន ពេលនុ៎ងថា ចាំពេលក្រោយ។ យើងគោរពតាមតុលាការ មិនមែន នួន ជា ហ្នឹងមិនគោរពធ្វើអីតាមចិត្តដូចលោក-- ដូចខាងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីចោទប្រកាន់នោះទេ។ គោរពតុលាការរហូតមកដល់ថ្ងៃនេះ មុននឹងដល់ថ្ងៃនេះ មុន-- កាលពីអាទិត្យមុនបានបញ្ជាក់តុលាការទៀត។ តុលាការបានប្រាប់ថា ឲ្យចប់ ហើយចប់ដូចតុលាការបានពន្យល់ព្រឹកមិញហើយ ថាពេលវេលាមិនអនុញ្ញាតដោយសារពេលវេលាចប់។ ម៉្លោះហើយសូមឲ្យមកដល់ថ្ងៃហ្នឹង សុន្ទរកថារបស់លោក នួន ជា ខ្លីមិនដល់ដប់នាទីផង គាត់សរសេរដៃគាត់ធំៗមិនបានមួយទំព័រផង។

នេះគ្រាន់ការឆ្លើយតបបូកសរុបនៃការចោទប្រកាន់របស់ ឌុច តែប៉ុណ្ណឹងទេ ហើយគាត់សុំសិទ្ធិមិននិយាយឆ្លើយតបនឹងការសួររបស់ព្រះរាជអាជ្ញាក្ដី របស់ភាគីទាំងអស់ ព្រមទាំងមិនឆ្លើយតបចំពោះតុលាការទៀត ដោយសារគាត់ថាចាំមកពិភាក្សានៅជាមួយមេធាវីរបស់គាត់នៅពេលក្រោយ នឹងឆ្លើយនៅពេលក្រោយ។ គាត់មិនមែនមិនឆ្លើយទេ នឹងឆ្លើយ ប៉ុន្តែសុំនៅពេលក្រោយ មិនមែនគាត់ធ្វើអីស្រេចនឹងចិត្ត ដោយគ្មានតុលាការទេ។ អាហ្នឹងសូមឆ្លើយតបទៅព្រះរាជអាជ្ញា និងដើមបណ្ដឹងរដ្ឋប្បវេណី។ សូមអរគុណ។

[០៩:៣០:៤៦]

**ប្រធានអង្គជំនុំ៖**

មានបញ្ហាអីទៀតទេ? បើបញ្ហាដដែល យើងបញ្ឈប់ការពិភាក្សាលើបញ្ហាដដែលនេះទៀតហើយ។ លោកតំណាងព្រះរាជអាជ្ញាអន្តរជាតិ លោកមានបញ្ហាអីថ្មីទេ? បើមានថ្មី បានយើងអនុញ្ញាតឲ្យនិយាយ។

**លោក ឆេល លីសាក់៖**

ខ្ញុំមិនមានអ្វីថ្មីទេ លោកប្រធាន ហើយខ្ញុំជម្រាបទៅដល់មេធាវីការពារ ហើយជនជាប់ចោទថាគាត់បានធ្វើសេចក្ដីថ្លែងការណ៍មួយ ហើយគាត់គប្បីតែជាបុគ្គលដែលអាចនឹងទទួលសំណួរ ហើយនិងឆ្លើយ ប៉ុន្តែគាត់បានប្ដូរជំហរទៅនឹងផ្ទុយនឹងការថ្លែងរបស់គាត់។

**ប្រធានអង្គជំនុំ៖**

អនុរក្សមន្ទីរឃុំឃាំងឲ្យនាំលោក នួន ជា ទៅកាន់ទីកន្លែងសម្រាប់គាត់ ដែលនៅពីក្រោយមេធាវីរបស់គាត់វិញចុះ។ អត់មានអ្នកបកប្រែឈប់ៗ។

*(មានបញ្ហាបច្ចេកទេសបកប្រែ)*

អនុរក្សមន្ទីរឃុំឃាំងឲ្យនាំ នួន ជា ទៅកាន់កន្លែងសម្រាប់គាត់ ដែលនៅពីក្រោយមេធាវីរបស់គាត់។ បញ្ហាបច្ចេកទេសបកប្រែភាសាយ៉ាងម៉េចទៅ? ម្តងហើយម្តងទៀត ពិនិត្យ ហើយរាយការណ៍ប្រាប់ខ្ញុំភ្លាម ថាវាអាចដំណើរការបាន ឬអត់?

*(មានបញ្ហាបច្ចេកទេសបកប្រែ)*

[០៩:៣៣:៣១]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះយើងបន្តទៅកិច្ចដំណើរការសវនាការ ស្តាប់សក្ខីកម្មសាក្សីមួយរូប ដែលអង្គជំនុំជម្រះបានគ្រោងទុកសម្រាបស្តាប់សក្ខីកម្មនៅក្នុងថ្ងៃនេះ ក្នុងករណីជនជាប់ចោទ នួន ជា រក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតប ហើយមុននឹងកោះហៅសាក្សី TCW-617 ចូលមកកាន់បន្ទប់សវនាការ អង្គជំនុំជម្រះសូមជម្រាបជូនភាគីនៃរឿងក្តីនេះថា ចំពោះការដែលជនជាប់ចោទរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបនៅក្នុងកិច្ចដំណើរការពិភាក្សាដេញដោល អង្គជំនុំជម្រះនឹងចេញសេចក្តីសម្រេចលើបញ្ហានេះ នៅបន្ទាប់ពីសម្រាកនៅក្នុងព្រឹកនេះ។

មន្ត្រីរដ្ឋបាលតុលាការ អញ្ជើញសាក្សី TCW-617 ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[០៩:៣៥:៥៤]

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការ ម៉េចក៏មិនរៀបចំឲ្យគាត់ស្តាប់ ឧបករណ៍សម្រាប់ស្តាប់សំឡេង?

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

អររុណសួស្តីសាក្សី!

**ស៖** ស្តាប់ឮទេ សាក្សី? តើលោកឈ្មោះអ្វីទៅ?

**លោក សួត្រ ទឿង៖**

**ឆ៖** ទឿង។

**ស៖** ឆ្លើយម្តងទៀត ហើយរង់ចាំៗមានភ្លើងៗសញ្ញានៅក្បាលមីក្រូ សូមចាប់ផ្តើមឆ្លើយណ៎ា! លោកឈ្មោះអ្វីដែរ?

**ឆ៖** សួត្រ ទឿង។

**ស៖** ក្រៅពីឈ្មោះ សួត្រ ទឿង តើលោកមានមានឈ្មោះអ្វីផ្សេងទៀតដែរឬទេ? សាក្សីបង្អង់បន្តិច បង្អង់ហើយរង់ចាំឲ្យមានភ្លើងក្រហមនៅក្បាលមីក្រូ សូមចាប់ផ្តើមឆ្លើយ មិនចាំបាច់ប្រញាប់ប្រញាល់ទេណ៎ា។ តើលោកមានឈ្មោះអ្វីផ្សេងក្រៅពីឈ្មោះ សួត្រ ទឿង នេះដែរឬទេ?

[០៩:៣៧:៣១]

**ឆ៖** អត់មាន។

**ស៖** ដល់ឆ្នាំនេះ តើលោកមានអាយុប៉ុន្មានឆ្នាំហើយ?

**ឆ៖** ឆ្នាំនេះអាយុ៦២។

**ស៖** សព្វថ្ងៃតើលោកមានមុខរបរធ្វើអ្វីដែរ?

**ឆ៖** ធ្វើចម្ការ។

**ស៖** តើឪពុករបស់លោកឈ្មោះអី?

**ឆ៖** យ៉ា ឈ្មោះ យ៉ា។

**ស៖** ចុះម្តាយរបស់លោកឈ្មោះអ្វីដែរ?

**ឆ៖** យឹម។

[០៩:៣៨:២៧]

**ស៖** លោកមានកូនប៉ុន្មាននាក់?

**ឆ៖** ប្រាំបួននាក់។

**ស៖** លោក សួត្រ ទឿង តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការអម្បាញ់មិញនេះថា តាមសមត្ថភាពដែលលោកអាចដឹង លោកមិនមានឪពុកម្តាយ បុព្វញាតិ កូន បងប្អូនប្រុសស្រី បងប្អូនថ្លៃប្រពន្ធ ត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងក្តីនេះទេ ហើយក៏មិនជាប់ញាតិលោហិត

ជាមួយនឹងជនជាប់ចោទទាំងបីរូបដែរ។ តើពិតមែនដែរឬទេ?

**ឆ៖** មែន។

**ស៖** ហើយសាក្សីបានរាយការណ៍ថាលោកបានស្បថរួចហើយ តើពិតមែនដែរឬទេ?

**ឆ៖** មែន។

[០៩:៣៩:២៦]

**ប្រធានអង្គជំនុំ៖**

មុននឹងតាំងសំណួរដល់លោក អង្គជំនុំជម្រះសូមជម្រាបអំពីសិទ្ធិ និងករណីយកិច្ចក្នុងនាមលោកជាសាក្សី ដូចខាងក្រោមនេះ៖ លោក ស្វូត្រ ទឿង ក្នុងនាមលោកជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការនៅចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយទៅនឹងសំណួរ ឬក៏ធ្វើអំណះអំណាងណាមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង គឺសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ មានន័យថា ដោយសារតែចម្លើយ ឬអំណះអំណាងរបស់លោកនោះនាំឲ្យលោកនឹងត្រូវទទួលរងការចោទប្រកាន់។

[០៩:៤០:១០]

ទន្ទឹមនឹងនេះ លោកក្នុងនាមជាសាក្សី មានករណីយកិច្ចត្រូវផ្តល់សក្ខីកម្មនៅក្នុងកិច្ចដំណើរការសវនាការនេះចំពោះមុខអង្គជំនុំជម្រះ ដោយត្រូវឆ្លើយតបទៅនឹងសំណួរទាំងឡាយដែលភាគី ឬអង្គជំនុំជម្រះតាំងសំណួរចំពោះលោក។ លើកលែងតែក្នុងករណីឆ្លើយទៅនឹងសំណួរ ឬការធ្វើអត្ថាធិប្បាយមួយឬច្រើនដែលវានាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចអង្គជំនុំជម្រះបានជម្រាបជូនខាងលើ។ ហើយលោកជាសាក្សីត្រូវតែឆ្លើយឲ្យការណ៍នូវការណ៍ណាដែលពិត ដែលខ្លួនបានដឹង បានឮ បានឃើញ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវបញ្ហា នូវព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធទៅនឹងសំណួរ។

លោកយល់ដែលឬទេ អំពីសិទ្ធិ និងករណីយកិច្ចនេះ?

[០៩:៤១:០៥]

**លោក ស្វូត្រ ទឿង៖**

មិនសូវដែរ ខ្ញុំ។

**ប្រធានអង្គជំនុំ៖**

យើងពន្យល់លោកថា ក្នុងករណីសំណួរដែលមានការដាក់ពិរុទ្ធលើរូបលោក នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះគឺ លោកមិនមានសិទ្ធិ មិនឆ្លើយតបទៅនឹងសំណួរនោះបាន។ តែបើសិនជាលោកអនុវត្តសិទ្ធិឆ្លើយតប ក៏មិនមានបញ្ហាអ្វីដែរ។ នេះជាសិទ្ធិរបស់លោកដែលច្បាប់ការពារ។ ផ្ទុយទៅវិញករណីយកិច្ចលោកត្រូវតែឆ្លើយឱ្យការណ៍ដល់អង្គជំនុំជម្រះនូវបញ្ហាណាដែលលោកបានដឹង បានឮ បានឃើញ មានបទពិសោធន៍ឆ្លងកាត់ ឬបានធ្វើការសង្កេតដោយខ្លួនលោកផ្ទាល់នូវអ្វីដែលលោកបានដឹង បានឮ បានឃើញ នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។

[០៩:៤២:១៧]

អង្គជំនុំជម្រះសូមជម្រាបតំណាងសហព្រះរាជអាជ្ញាថា ក្នុងកិច្ចដំណើរការសវនាការពិភាក្សាដេញដោលក្នុងការស្តាប់សក្ខីកម្មសាក្សីរូបនេះ អង្គជំនុំជម្រះផ្តល់វេទិកាទៅតំណាងសហព្រះរាជអាជ្ញាតាំងសំណួរដេញដោលចំពោះសាក្សីនេះ មុនភាគីដទៃទៀត។

អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា! សូមអញ្ជើញ!

សូមអញ្ជើញមេធាវីការពារក្តី នួន ជា!

**លោក អេនគ្រូ អ៊ីន្ទូហ្ស៊ី៖**

អរុណសួស្តី លោកប្រធាន លោក លោកស្រី! ខ្ញុំមានសំណើសុំសង្ខេបទេ ទាក់ទងទៅអ្វីដែលទើបលើកឡើងអនុវត្តទៅតាមវិធាន២៨ នៃវិធានផ្ទៃក្នុង។ យើងសូមឱ្យមានការបញ្ជាក់ឱ្យបានច្បាស់ និងជាពិសេសថា សាក្សីរូបនេះត្រូវតែឆ្លើយតបទៅនឹងសេចក្តីថ្លែងរបស់ ក.ស.ព ដែលថាសាក្សីរូបនេះក៏នៅតែអាចប្រឈមមុខទៅនឹងការចោទប្រកាន់ ហើយដែលបានស្នើសុំដោយសហព្រះរាជអាជ្ញា នៅថ្ងៃទី០៣ មេសា ២០១២។ ដូច្នេះ ជំហររបស់យើងខ្ញុំយល់ឃើញថា សាក្សីរូបនេះបានយល់យ៉ាងពេញលេញនូវអ្វីដែលអង្គជំនុំជម្រះទើបនឹងជម្រាបគាត់អម្បាញ់មិញនេះ។ ដូច្នេះ ជំហររបស់យើងខ្ញុំគឺថា ដោយសារថាការ-- ដោយសារសហចៅក្រមស៊ើបអង្កេត ក៏ដូចជា ក.ស.ព ដែលបានផ្តល់ការធានារបស់គាត់នោះ។ ដូច្នេះ អង្គជំនុំជម្រះត្រូវតែធ្វើអន្តរាគមន៍សួរបញ្ជាក់ឱ្យបានច្បាស់មែនទែនតែម្តងដែលថា អាចនឹងមានការចោទប្រកាន់ណាមួយទៅដល់សាក្សីរូបនេះ។ អនុលោមទៅតាមវិធាន២៨(៣) នៃវិធានផ្ទៃក្នុងគឺថា អង្គជំនុំជម្រះ ឬក៏សហចៅក្រមស៊ើប តម្រូវឱ្យសាក្សីឆ្លើយទៅនឹងសំណួរ ហើយត្រូវធានាទៅដល់សាក្សីរូបនេះថា ភស្តុតាងដែលអាចផ្តល់មកនេះ គឺថាអាចនឹងរក្សាជាការសម្ងាត់ មិន

ឲ្យសាធារណជនដឹងបាន ឬក៏នឹងត្រូវយកមកប្រើប្រាស់ដោយផ្ទាល់ ឬដោយប្រយោលដើម្បីធ្វើការចោទប្រកាន់ដោយ អ.វ.ត.ក នោះទេ។

[០៩:៤៤:៥០]

តែតាមការពិតនោះគឺថា អ.វ.ត.ក ត្រូវតែធានាថានឹងមានការចោទប្រកាន់ មិនមែនពាក់ព័ន្ធទៅនឹងលទ្ធភាពរបស់គាត់ សមត្ថភាពរបស់គាត់នោះទេ។ គឺថាចម្លើយរបស់គាត់អាចនឹងត្រូវបានចោទប្រកាន់ដោយតុលាការជាតិ។ ដូច្នេះនេះគឺ ខ្ញុំសូមបញ្ជាក់ឲ្យបានច្បាស់ម្តងទៀតថា ចម្លើយរបស់សាក្សីរូបនេះអាចនឹងត្រូវទទួលរងនូវការចោទប្រកាន់ដោយអនុលោមទៅតាមវិធាន២៨(៨) ដែលថា ប្រសិនណាបើភាគីយល់ឃើញថា ចម្លើយ-- នៅពេលដែលភាគីណាមួយដឹងថា ការធ្វើសក្ខីកម្មរបស់សាក្សីម្នាក់អាចបណ្តាលឲ្យមានការ បញ្ហាពាក់ព័ន្ធទៅនឹងការដាក់ពិរុទ្ធភាពលើខ្លួនឯង ឬក៏នៅពេលដែលលើកឡើងបញ្ហាលើកឡើងដោយខ្លួនឯង។ ដូច្នេះខ្ញុំសុំបញ្ជាក់ថាវិធាន២៨(៨) នេះដោយសារគាត់បញ្ជាក់--សាក្សីរូបនេះបានបញ្ជាក់រួចហើយ។ ហើយក៏ ក.ស.ច.ស ក៏បានធានាមកដល់រូបគាត់ទៀត ហើយ ក.ស.ព ក៏បានបញ្ជាក់អះអាងធានាមកដល់រូបគាត់។ ដូច្នេះជំហររបស់ខ្ញុំគឺថា សុំឲ្យអង្គជំនុំជម្រះមេត្តាបញ្ជាក់ឲ្យបានច្បាស់លាស់ ឬក៏អាចគឺថាបញ្ជាក់ដល់សាក្សីរូបនេះនៅក្នុងសវនាការជាសម្ងាត់។ សូមអរគុណ ដែលអនុលោមទៅតាមវិធាន២៨(៨) នេះតែម្តង។ សូមអរគុណ។

[០៩:៤៦:១៦]

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ខេល លីសាក់៖**

លោកប្រធាន ខ្ញុំគិតថាហាក់បីដូចជាមានបញ្ហាណាស់ ដែលមេធាវីបានលើកឡើងបញ្ហានេះចំពោះសាក្សីតែម្តងនេះ។ ហើយគាត់បានស្នើសុំថា បើសិនណាជាអាចធ្វើ គឺៗធ្វើទៅបានអង្គជំនុំជម្រះអាចធ្វើសវនាការជាសម្ងាត់ក្នុងការបញ្ជាក់ដល់សាក្សីរូបនេះ។ ហើយយើងនឹងនិយាយអំពី បើសិនណាបើលើកឡើងអំពីបញ្ហានេះបន្តទៅទៀត គឺថាគាត់ស្នើសុំឲ្យៗមានសវនាការជាសម្ងាត់ ហើយការដែលគាត់លើកឡើងអំពីសេចក្តីថ្លែងរបស់សហការីរបស់ខ្ញុំហ្នឹង គឺជារឿងមិនត្រឹមត្រូវទាល់តែសោះ។ យើងមិនត្រូវឲ្យសាក្សីរូបនេះមានការព្រួយបារម្ភចំពោះបញ្ហានេះ ហើយគាត់មិនត្រូវបង្ហាញនូវឥរិយាបថក្នុងលក្ខណៈបែបនេះនោះទេ។ សូមអរគុណ។

**លោក ពេជ អង្គ៖**

សូមអនុញ្ញាត។

[០៩:៤៧:២៤]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

**លោក ពេជ អង្គ៖**

បាទសូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម និងសាធារណជនទាំងអស់។ ខាងដើមបណ្តឹងរដ្ឋប្បវេណីមានការភ្ញាក់ផ្អើលដែលលោកមេធាវីការពារក្តីឲ្យលោក នួន ជា បានលើកអំពីបញ្ហានេះ។ ហើយៗជាពិសេស ដោយឡែកចំពោះសាក្សីរូបនេះ ហើយដែលចំពោះករណីសាក្សីមុនៗលោកមិនបានលើកអំពីបញ្ហាដូចគ្នានេះទេ។ ហើយដែលការលើកនេះអាចមានការប៉ះពាល់ទៅដល់អារម្មណ៍របស់សាក្សីនៅក្នុងការឆ្លើយការពិត។ ហើយជាការពិតច្បាប់ក៏បាននិយាយថា មានតែជនពីរប្រភេទទេ ដែលនឹងអាចទទួលរងនូវការចោទប្រកាន់តាមច្បាប់ស្តីពីការកាត់ទោសអ្នកដែលទទួលខុសត្រូវក្នុងសម័យខ្មែរក្រហម គឺអ្នកដែលទទួលខុសត្រូវ អ្នកដែលជាមេដឹកនាំជាន់ខ្ពស់ ហើយនិងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតនូវឧក្រិដ្ឋកម្មនៅក្នុង-- កើតនៅក្នុងសម័យខ្មែរក្រហម។ ដូច្នេះ គឺមានតែបុគ្គលមួយក្តាប់តូចតែប៉ុណ្ណោះ ដែលស្ថិតនៅក្នុងក្របខ័ណ្ឌនៃច្បាប់ដែលបានលើកឡើង ដែលអាចត្រូវទទួលការចោទប្រកាន់បាន។

ដូច្នេះករណីបុគ្គល-- សាក្សីនេះ ទោះជាយ៉ាងណាក៏ដោយ ក៏មិនត្រូវលើកអំពីបញ្ហាអំពីការចោទប្រកាន់ណាមួយដែលអាចធ្វើឲ្យគាត់មានការប៉ះពាល់ដល់ផ្លូវអារម្មណ៍របស់គាត់ ដែលអាចធ្វើឲ្យគាត់មានការខ្លាចរអាលនៅក្នុងការឆ្លើយនោះឡើយ។ អ៊ីចឹងការដែលធ្វើ ការដែលលើកឡើងដោយមេធាវីរបស់លោក នួន ជា នេះ ជាការមិនសមស្របទេ។ សូមអរគុណលោកប្រធាន។

[០៩:៤៩:០៨]

**ប្រធានអង្គជំនុំ៖**

អញ្ជើញ!

**លោក អេនគ្រូ អ៊ីនួហ្ស៊ី៖**

សូមអរគុណ លោកប្រធាន ទីមួយខ្ញុំមិនបានបង្ហាញអ្វីទាំងអស់ ដែលថាវាជាលក្ខណៈសម្ងាត់ ខ្ញុំ

និយាយតែអំពីសក្ខីកម្មរបស់សាក្សីរូបនេះនោះទេ។ ដែលថា ដើម្បី-- ហេតុដូច្នេះហើយបានខ្ញុំថាបើសិនជាអាចធ្វើទៅបាន គឺថាយើងអាចនឹងធ្វើជាសវនាការសាធារណៈជាមួយនឹងសាក្សីរូបនេះ ដើម្បីបញ្ជាក់ឲ្យបានច្បាស់ចំពោះសក្ខីកម្មដែលគាត់នឹងផ្ដល់ ដើម្បីចៀសវាងការលើកឡើងនូវអង្គហេតុទាំងឡាយណាដែលនាំឲ្យពាក់ព័ន្ធដល់សាក្សីរូបនេះ។ ហើយរឿងមួយទៀត ដែលនិយាយអំពីបញ្ហាអវត្តមានរបស់ ឌុច គឺខ្ញុំបានលើកឡើងអំពីសេចក្ដីថ្លែងមួយរបស់សហព្រះរាជអាជ្ញាអន្តរជាតិមួយរូប។ នៅពេលនោះគឺថាមិនមានអ្នកណាបានលើកឡើងអំពីបញ្ហានេះនោះទេ។

[០៩:៥០:០៧]

ហើយចំណុចទីបី គឺអនុញ្ញាតឲ្យភាគីទាំងអស់គឺថាអាចលើកនូវបញ្ហានេះបាន។ អ្នកណាក៏ដោយ ភាគីណាក៏ដោយ ដែលមានវត្តមាននៅក្នុងដំណើរការនីតិវិធី ដោយអនុលោមតាមវិធាន ២៨(៨) គឺថាអាចដែលបញ្ជាក់ឲ្យឃើញថា សក្ខីកម្មរបស់សាក្សីម្នាក់ អាចបណ្ដាលឲ្យមានការពាក់ព័ន្ធទៅនឹងការដាក់បន្ទុក ការដាក់ពិរុទ្ធលើខ្លួនឯងបាន។

ដូច្នេះប្រហែលជាសហព្រះរាជអាជ្ញាអាចលើកបញ្ហានេះឡើង ប្រហែលជាមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីក៏អាចលើកឡើង ហើយប្រហែលជាអង្គជំនុំជម្រះតែម្ដង ក៏អាចនឹងលើកឡើងបញ្ហានេះតែម្ដង។ ខ្ញុំបានបញ្ជាក់ហើយ គឺថាខ្ញុំមិននិយាយអំពីការចោទប្រកាន់នៅចំពោះមុខ អ.វ.ត.ក នោះទេ។ ខ្ញុំមិននិយាយពីយុត្តាធិការរបស់ អ.វ.ត.ក នោះទេ ដែលខ្ញុំនិយាយថា គឺយើងត្រូវតែផ្ដល់ការធានាស្របច្បាប់ និងប្រត្យក្សទៅដល់សាក្សីរូបនេះ ហើយដូចដែលខ្ញុំបានលើកឡើងរួចមកហើយថា ឆ្លើយទៅនឹងសហព្រះរាជអាជ្ញាអន្តរជាតិ ដែលថាអាចនៅតែមានលទ្ធភាពក្នុងការចោទប្រកាន់ចំពោះសាក្សីរូបនេះបាន។

[០៩:៥១:២១]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះផ្ដល់វេទិកាទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីនេះ។

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក សេង ប៊ុនឃាង៖**

សួស្តីលោកសាក្សី!

**ស៖** ខ្ញុំនឹងសួរសំណួរមួយចំនួនទៅលោក ហើយសំណួររបស់ខ្ញុំដំបូងនេះគឺ សួរថាតើលោកចូលបដិវត្តន៍នៅពេលណា?

**លោក អេនឌ្រូ អ៊ីនួហ្ស៊ី៖**

តើៗ-- ខ្ញុំសូមសួរបញ្ជាក់អង្គជំនុំជម្រះថា សំណើររបស់ខ្ញុំផ្ទាល់មាត់អម្បាញ់នេះគឺត្រូវបានអង្គជំនុំជម្រះច្រានចោល ឬក៏យ៉ាងម៉េចទើបបានជាផ្តល់វេទិកាទៅសហព្រះរាជអាជ្ញា?

[០៩:៥២:១៥]

**ប្រធានអង្គជំនុំ៖**

លោកនិយាយដូចជាមិនមានសំណើអីច្បាស់លាស់សោះនេះ បើជាភាសាខ្មែរនេះវាមិនចេញជាសំណើអីច្បាស់លាស់សោះ។ លោកគួរតែរៀបពាក្យយ៉ាងម៉េច និយាយឱ្យវាចេញជាសំណើច្បាស់លាស់ដើម្បីឱ្យអង្គជំនុំជម្រះយល់ផង។ រួចអង្គជំនុំជម្រះ ប្រធានសវនាការនេះអត់យល់ថា លោកនិយាយអំពីសំណើស្អីឱ្យបានច្បាស់លាស់។ លោកប្រើគ្រាន់តែពាក្យ "អាចៗ" ហ្នឹងវាយ៉ាងម៉េចទៅអានេះ?

**លោក អេនឌ្រូ អ៊ីនួហ្ស៊ី៖**

នេះជាកំហុសរបស់ខ្ញុំ ដែលបញ្ជាក់អត់បានច្បាស់លាស់។ ខ្ញុំសូមឱ្យច្បាស់ ខ្ញុំសូមដាក់សំណើសុំដោយអនុវត្តទៅតាមវិធាន ២៨(៨) គឺយើងអាចបើកសវនាការអសាធារណៈ។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៥៤:៥៥]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសម្រេចបដិសេធនូវសំណើសុំរបស់មេធាវីអន្តរជាតិការពារក្តីលោក នួន ជា ដែលបានស្នើសុំឱ្យអង្គជំនុំជម្រះធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីរូបនេះជាអសាធារណៈ។

ទីពីរ បញ្ជាសុំឱ្យលោកមេធាវីការពារក្តីទាំងអស់ និងភាគីដទៃទៀតនៅពេលណាដែលខ្លួនមានបំណងគិតថាគប្បីធ្វើសុំសំណើសុំឱ្យស្តាប់សក្ខីកម្មណាមួយជាអសាធារណៈនៅពេលអនាគត គប្បីធ្វើសំណើនោះ មុនពេលអង្គជំនុំជម្រះអញ្ជើញសាក្សីឱ្យចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់

សវនាការ។ ម្យ៉ាងទីទៀត គឺសូមឲ្យរៀបរយនូវសេចក្ដីស្នើសុំរបស់ខ្លួនឲ្យបានជាក់ច្បាស់ផង ចៀសវាងមានការភ័ន្តច្រឡំរវាងការធ្វើសំណើ ហើយនិងធ្វើការ គ្រាន់តែជាការសង្កេតរបស់ខ្លួន។

[០៩:៥៦:១៩]

**លោក អេនឌ្រូ អ៊ីនូហ្វ៊ី៖**

សូមអរគុណលោកប្រធាន។ តែយ៉ាងណាក៏ខ្ញុំសូម គ្រាន់តែចង់បញ្ជាក់នូវការលើកឡើងរបស់ខ្ញុំដើម្បីជាការកត់ត្រារបស់អង្គជំនុំជម្រះ។ បាទសូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមផ្ដល់វេទិកាទៅតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ-- អ៎! តំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** លោកសាក្សី ខ្ញុំនឹងសួរសំណួរនេះឡើងវិញ។ សួរថា តើលោកចូលបដិវត្តន៍នៅពេលណា?

**លោក សួត្រ ទៀង៖**

**ឆ៖** នៅឆ្នាំ៦៨។

**ស៖** បាទ អរគុណ។ តើនៅពេលដែលលោកចូលហ្នឹង នរណាជាអ្នកណែនាំលោកឲ្យចូល?

**ឆ៖** អ៊ីង ឈ្មោះ អ៊ីង។ បងអ៊ីង។

**ស៖** នៅពេលនោះ លោករស់នៅកន្លែងណាដែរ លោកនៅចាំទេ?

**ឆ៖** កន្លែងនោះ កាលណោះអត់សូវចាំដែរ ព្រោះវាច្រើនកន្លែងដែរ។ វាតំបន់អណ្ដូងមាស អត់សូវចាំ នៅក្មេងកាលណោះ តូច។

**ស៖** ចុះឈ្មោះ អ៊ីង ហ្នឹងគាត់មានតួនាទីអីដែរនៅក្នុងបដិវត្តន៍ហ្នឹង?

**ឆ៖** គាត់ជាអ្នកដឹកនាំដែរ ប៉ុន្តែដឹកនាំកម្រិតណា ខ្ញុំអត់ដឹងទេណ៎ា វា ខ្ញុំវានៅក្មេងប៉ុណ្ណោះ ហៅថាជាមួយពួកកុមារ ចលនាតស៊ូ។

[០៩:៥៨:៣៥]

**ស៖** ឈ្មោះ អ៊ីង ហ្នឹងគាត់ជាអ្នកដឹកនាំខាងណាដែរ លោកនៅចាំបានទេ?

**ឆ៖** ខាងព្រៃឈើស្លាន។

**ស៖** នៅពេលដែលលោកចូលបដិវត្តន៍នៅឆ្នាំ១៩៦៨ នុ៎ង តើលោកត្រូវបានគេចាត់តាំងឲ្យធ្វើអីដែរនៅក្នុងបដិវត្តន៍ហ្នឹង?

**ឆ៖** អត់។ ដល់តែ នៅតាមកន្លែងគេចល័តចុះ ចល័តឡើងតាមមន្ទីរ នៅតូចៗ នៅមន្ទីរកុមារ។

**ស៖** ចុះលោកធ្លាប់ជាសមាជិករបស់បក្សកុម្មុយនីស្តកម្ពុជា ឬក៏ជាសមាជិករបស់សម្ព័ន្ធយុវកកអីទេ កាលនុ៎ង?

**ឆ៖** អត់មានទេ កាលនុ៎ង។

[០៩:៥៩:៣១]

**ស៖** ចុះនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ តើលោកធ្លាប់ជាសមាជិករបស់បក្សកុម្មុយនីស្តកម្ពុជា ឬក៏ជាសមាជិកសម្ព័ន្ធយុវកកទេ?

**ឆ៖** ខ្ញុំកាលណោះ វាត្រឹមសម្ព័ន្ធយុវកក។

**ស៖** លោកនៅចាំទេ ថានៅពេលណាដែលលោកចូលជាសមាជិកសម្ព័ន្ធយុវកកហ្នឹង?

**ឆ៖** ប្រហែលឆ្នាំណា? អត់ចាំដែរ។

**ប្រធានអង្គជំនុំ៖**

ឈប់ៗ! សម្រាកសិន! អត់ដូចមានបញ្ហាផ្នែកខាងបកប្រែភាសា។ យ៉ាងម៉េចទៅ? ក្រោយចូលឆ្នាំខ្មែរ ហើយមានបញ្ហាបច្ចេកទេសរហូតអ៊ីចឹង។

សូមៗអញ្ជើញតំណាងសហព្រះរាជអាជ្ញាបន្ត!

[១០:០០:៤២]

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** លោកសាក្សី តើលោកចាំទេថានៅពេលដែលលោកចូលជាសមាជិកសម្ព័ន្ធយុវកកហ្នឹង?

**លោក ស្ងួត ទឿង៖**

**ឆ៖** កាលនោះនៅកន្លែង ដូចកន្លែងន័៎ អត់ចាំទេ។ ឆ្នាំ៧២ ចិតអីហ្នឹង។

**ស៖** ចុះអ្នកដែលណែនាំលោកឲ្យចូលសម្ព័ន្ធយុវកកហ្នឹង តើជាអ្នកណាដែរ?

**ឆ៖** ឈ្មោះន៉ែ គូ។

**ស៖** បាទ អរគុណ។ តើការចូលជាសមាជិករបស់សម្ព័ន្ធយុវកកហ្នឹង លោកធ្លាប់បានចូលរួមក្នុងវគ្គបណ្តុះបណ្តាល ឬក៏វគ្គសិក្សាដើម្បីរៀនសូត្រអំពីមាគ៌ាបក្ស ហើយនិងគោលនយោបាយរបស់បក្សអីដែរទេ?

**ឆ៖** អត់បានៗ។

[១០:០២:១៥]

**ស៖** ចុះលោកធ្លាប់ដែលបានទទួលឯកសារអីរបស់បក្សដែរទេនៅពេលនុ៎ង?

**ឆ៖** អត់មានដែរ អត់ឃើញមាន។ មានតែសៀវភៅតូច គេសម្រាប់អប់រំសីលធម៌ ១២ប្រការប៉ុននុ៎ងឯង។

**ស៖** ចុះលោកដែរ ដែលឃើញឯកសារដែលមានឈ្មោះថា "ទស្សនាវដ្តីយុវជន យុវនារីបដិវត្ត" អីទេដែរនៅពេលនុ៎ង?

**ឆ៖** កាលនុ៎ងខ្ញុំអត់ចេះអក្សរផង គេអត់ឲ្យ។

**ស៖** បាទសូមអរគុណ។ សូមលោកជួយរៀបរាប់ជូនអង្គសវនាការថា នៅពេលដែលលោកចូលតស៊ូក្នុងបដិវត្តន៍ឆ្នាំ១៩៦៨ ហ្នឹង រហូតដល់ថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥។ តើលោកនៅកន្លែងណា? ហើយលោកធ្វើអ្វីដែរនៅពេលនោះ?

[១០:០៣:២៧]

**ឆ៖** តាំងពីឆ្នាំ៦៨ ខ្ញុំអត់សូវចាំដែរ កុមារវាច្រើនណ៎ា ប្រមូលមក ដល់អ៊ីចឹងគេចល័តចុះចល័តឡើង ដូរកន្លែងរហូត។ ហើយក្មេងៗប៉ុណ្ណឹងវាច្រើនដែរ ប៉ុន្មានទេ មិនសូវចាំដែរ។ ដប់នាក់ទៅប្រាំនាក់ទៅកន្លែងនេះបន្តិច នៅកន្លែងនោះបន្តិច។ វាអ៊ីចឹង អត់បាននៅកន្លែងយូរទេ។ គេផ្លាស់រហូត។

**ស៖** នៅក្នុងអំឡុងពេលនោះ តើលោកធ្លាប់ធ្វើជាទាហាន ឬក៏ជាកងទ័ពដើម្បីច្បាំងជាមួយនឹងកងទ័ពភាគីរបស់ខាងណាដែរទេ អង្គាល់នុ៎ង?

**ឆ៖** អត់ នៅក្មេង។

**ស៖** នៅមុនខែមេសា ឆ្នាំ១៩៧៥ តើលោកធ្លាប់រស់នៅមន្ទីរមួយដែលមានឈ្មោះថា ប២០ដែរទេ?

**ឆ៖** ប២០ អត់ៗនៅទេ។

[១០:០៤:៤១]

**ស៖** ចុះលោកស្គាល់ទេ មន្ទីរ ប២០?

**ឆ៖** អត់ស្គាល់ទេ ឮតែគេនិយាយដែរ អត់ស្គាល់ទេ។

[១០:០៥:០០]

**ស៖** តើការឮគេនិយាយអំពី ប២០ ហ្នឹង លោកដឹងទេ ថាគេនិយាយថា ប២០ ហ្នឹងមានតួនាទីធ្វើអ្វីដែរ? លោកមានដឹងទេ កាលនុ៎ង?

**ឆ៖** ប២០ តាមខ្ញុំឮ គឺពួកកងដឹកជញ្ជូន ដាំបន្លែ ដាំអីហ្នឹង ប៉ុណ្ណឹង។ អាហ្នឹងហើយសំខាន់ទេ។ ចិញ្ចឹមជ្រូក ចិញ្ចឹមមាន់។

**ស៖** ចុះលោកបានដឹងដែរ ថាប២០ ហ្នឹង មានទីតាំងនៅកន្លែងណាដែរ?

**ឆ៖** អត់ដឹងដែរ។

**ស៖** នៅក្នុងការឆ្លើយរបស់លោកជូនចំពោះការិយាល័យសហចៅក្រមស៊ើបអង្កេត។ ឯកសារ E3/423 ឬក៏ D234/23 ត្រង់ចម្លើយលេខ១៣៧ លោកបាននិយាយថា ប២០ ហ្នឹង ស្ថិតនៅគីឡូលេខ ១០ តើលោករក្សានូវចម្លើយនេះ ដែរទេ?

**ឆ៖** ប២០ ខ្ញុំមិនសូវចាំដែរ។ ប២០ វាផ្លូវទៅណាខ្ញុំភ្លេចដែរ នៅអាកន្លែងហ្នឹង ដូចជាម្ដុំគីឡូ១០ ហើយនិងទៅព្រែកសង្កែ។ តាមនៅៗចាំ។ វាយូរដែរ មិនសូវចាំឆ្នាំដែរ។

**ស៖** តើលោកដឹងទេ គីឡូលេខ១០ ហ្នឹង ស្ថិតនៅឃុំណា? ស្រុកណា? ឬក៏ខេត្តណាដែរ? លោកអាចបញ្ជាក់ជូនអង្គសវនាការបានទេ?

**ឆ៖** ចាំ! នៅខេត្តកំពង់ចាម។

**ស៖** តើលោកចាំអំពីឈ្មោះឃុំ? ឈ្មោះស្រុកដែរទេ?

**ឆ៖** អត់ចាប់អារម្មណ៍កាលណោះ អត់ចាំ។

[១០:០៧:២១]

**ស៖** តើលោកឮទេ ថាមានថ្នាក់ដឹកនាំបក្សធ្លាប់ទៅកន្លែងធ្វើការ ធ្លាប់ទៅធ្វើការនៅ ឬក៏ស្នាក់នៅ ប២០ នុ៎ង ដែរទេ? លោកមានដឹងទេ?

**ឆ៖** អត់ដឹងដែរ។

**ស៖** ចុះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ តើលោករស់នៅកន្លែងណាដែរ នៅពេលនុ៎ង?

**ឆ៖** កាលណោះ ចេញពី ន៉ែ កន្លែងកុមារហ្នឹង គឺទៅនៅកន្លែង គេហៅ កន្លែង ខាំ មី។

**ស៖** លោកនៅកន្លែង ខាំ មី ហ្នឹង នៅពេលណា? បន្ទាប់ពីថ្ងៃ១៧ មេសា ១៩៧៥ ឬក៏មុនហ្នឹង ឬក៏នៅពេលនុ៎ង?

**ឆ៖** ក្រោយ៧៥ ប្រហែលជាជិតកន្លះឆ្នាំមិនដឹង។

**ស៖** ចុះមុនពេលដែលលោកមកកន្លែង ខាំ មី ហ្នឹង តើលោកនៅកន្លែងណាដែរ?

**ឆ៖** នៅកន្លែង-- ការពារនៅនុ៎ង កងការពារនៅនុ៎ង។ ការពារម្ដុំហ្នឹង។ កង-- កាលនុ៎ងកង ខាំ មី កងការពារកងទ័ព។

[១០:០៩:១៨]

**ស៖** កងការពារកងទ័ពហ្នឹង ឈ្មោះអ្វីទៅ?

**ឆ៖** ខ្ញុំអត់សូវចំណាំដែរ កង ខាំ មី។ ព្រោះវា កាលហ្នឹង អត់បានចាប់អារម្មណ៍។ យ១០ ៗ ហ្នឹង។

**ស៖** ចម្លើយរបស់លោកនេះ ចង់បញ្ជាក់ថា នៅពេលដែលលោកមកទីក្រុងភ្នំពេញ អ៊ីចឹងមែនទេ? ចុះមុនពេលដែលលោកមកទីក្រុងភ្នំពេញ តើលោកនៅរស់នៅកន្លែងណាដែរ?

**ឆ៖** ខ្ញុំចេញពី ន៉ែ ចូលពីកន្លែង គេហៅអី? កន្លែងអាដាំបន្លែ ខ្ញុំវាភ្លេចទៅណ៎ះ! ហើយបានចូល យ១០ ក្រោយមកខ្ញុំក៏ចូលទៅ កន្លែងន៉ែការពារជុំវិញហៅថា ក១។

**ស៖** បាទអរគុណ។ លោកបានជម្រាបជូនអង្គសវនាការថា មុនពេលដែលលោកមកទីក្រុងភ្នំពេញ លោកបាននៅកន្លែងដាំបន្លែ តើកន្លែងដាំបន្លែហ្នឹងឈ្មោះអ្វី? ឈ្មោះ ប២០ ឬក៏ឈ្មោះអ្វីផ្សេង?

**ឆ៖** ២០ ហើយអាហ្នឹង។

**ស៖** នៅពេលដែលលោកនៅ ប២០ ហ្នឹងតើលោកធ្លាប់ឃើញថ្នាក់ដឹកនាំបក្សណាទៅទីនោះដែរទេ?

**ឆ៖** ទៅមហាជនធម្មតា។ វាចម្រុះ។

**ស៖** បាទអរគុណ។ សូមលោកជួយជម្រាបជូនអង្គសវនាការ អំពីតួនាទីរបស់លោកនៅ ប២០ តើលោកធ្វើអ្វីដែរនៅពេលនុ៎ង?

**ឆ៖** អត់មានធ្វើអីទេ។ មានតែនាំគេម្ដង គេហៅទៅដឹកជញ្ជូនការឈូត បន្លែអ៊ីចឹងទៅ ហើយយកគ្រាប់យកទៅ ប៉ុណ្ណឹងឯង ចុះទៅចុះឡើង។ ជំនាន់នុ៎ងនៅតូចដែរ ដឹកអង្ករអ៊ីចឹងទៅ។

**សៈ** បាទអរគុណ។ តើនៅពេលនុ៎ងលោកបានដឹង អំពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញដែរទេ ហើយនៅពេលណាដែរលោកដឹង?

**ឆៈ** ខ្ញុំអត់ដឹងដែរ ស្រាប់តែទៅភ្នំពេញមនុស្សវាអស់ដែរ។ អត់ឃើញមនុស្សនៅ ឃើញតែប្រជាជននៅតាមផ្លូវតែប៉ុណ្ណឹង។

**សៈ** នៅកន្លែងដែលលោកស្នាក់នៅមុនដែលលោកមកទីក្រុងភ្នំពេញហ្នឹង តើលោកបានឃើញប្រជាជនដែលគេជម្លៀសហ្នឹង ចូលទៅភូមិឃុំដែលលោករស់នៅហ្នឹងដែរទេ?

**ឆៈ** ឃើញប្រជាជនភៀសខ្លួនពីក្រុងភ្នំពេញឃើញមកតាមហ្នឹងផ្លូវហ្នឹងឯង។

[១០:១២:២៧]

**សៈ** តើលោកចាំទេថា ប្រជាជនដែលគេជម្លៀសទៅហ្នឹង គេចាត់ចែងគាត់យ៉ាងម៉េច? គេយកគាត់ទៅដាក់ត្រង់ណា?

**ឆៈ** អត់ចាំដែរ។

**សៈ** តើនៅពេលនោះមានដូចជា ទាហាន ឬក៏កម្មាភិបាលបក្ស ដែលនៅកន្លែងលោកហ្នឹងបានផ្តល់ណែនាំអ្វីទាក់ទងទៅនឹងថា តើធ្វើយ៉ាងណាចំពោះប្រជាជន ដែលជម្លៀសចេញពីទីក្រុងភ្នំពេញហ្នឹងក្នុងខែមេសា ឆ្នាំ១៩៧៥ ដែរទេ?

**ឆៈ** អត់។ អត់មានប្រាប់ទេ។

**សៈ** បន្ទាប់ពីការដណ្តើមកាន់កាប់ទីក្រុងភ្នំពេញ ដោយកងកម្លាំងរបស់បក្សកុម្មុយនីស្តកម្ពុជានៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ តើលោកមកស្នាក់នៅទីក្រុងភ្នំពេញនៅពេលណាដែរ?

**ឆៈ** អត់ចាំដែរអាហ្នឹង។ ពេលខែ រំដោះហើយបានចូល ប្រហែលមួយខែពីរខែប៉ុណ្ណឹង មិនចាំដែរ។ ខ្ញុំមិនសូវចាប់អារម្មណ៍នៅក្មេង។

[១០:១៤:១២]

**សៈ** បាទអរគុណ។ សូមលោកជួយជម្រាបជូនអង្គសវនាការ អំពីស្ថានភាពទីក្រុងភ្នំពេញដែលលោកបានមកដល់ហ្នឹង តើមានសភាពយ៉ាងណាដែរនៅពេលនុ៎ង?

**ឆៈ** មានសភាព អត់មនុស្សអីផង មានតែកងទ័ពពេញតែនោះឯង។

**សៈ** តើលោកឃើញមានប្រជាជន ឬមនុស្សដែលនៅតាមផ្លូវដែរឬទេនៅពេលនុ៎ង?

**ឆៈ** មាននៅខ្លះ។

**ស៖** តើប្រជាជនដែលនៅខ្លះហ្នឹង គេធ្វើអ្វីដែរ?

**ឆ៖** មិនដឹងដែរ។

[១០:១៥:០៩]

**ស៖** ចាប់តាំងពីថ្ងៃដែលលោកចូលមកដល់ទីក្រុងភ្នំពេញ នៅក្នុងឆ្នាំ១៩៧៥ តើលោករស់នៅទីនេះរហូតដល់ដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី៧ មករា ១៩៧៩ ឬក៏យ៉ាងណា?

**ឆ៖** នៅហ្នឹងរហូត។ កាលហ្នឹងវាចល័តដែរហ្នឹង មិនមែននៅមួយកន្លែងទេ។

**ស៖** លោកបានជម្រាបជូនអង្គសវនាការអម្បាញ់មិញហើយថា លោកមកដល់ទីក្រុងភ្នំពេញ គឺលោកមកធ្វើការនៅកន្លែង ខាំ មី តើកន្លែង ខាំ មី ហ្នឹងគាត់ធ្វើអី? ហើយជាអង្គភាពអ្វីដែរ?

**ឆ៖** នែ៎ៗ យ១០ គាត់នៅខាងគ្រប់គ្រងកងការពារ ឬក៏កងទ័ពហ្នឹងហើយ។

**ស៖** តើលោកនៅចាំទេថា នៅពេលនោះអ្នកណាជាអ្នកនាំលោកមកទីក្រុងភ្នំពេញឲ្យចូលធ្វើការងារនុ៎ង?

**ឆ៖** កាលនោះមានតែ ហនុមាន, ហាគូ ពីរនាក់ហ្នឹង។

**ស៖** ឈ្មោះ ម៉ាន និងឈ្មោះ គូ ជាអ្នកមកជាមួយលោក។ ចុះអ្នកណាដែលអ្នកនាំលោកមកទីក្រុងភ្នំពេញ។ លោកចាំទេអ្នកនាំមក?

**ឆ៖** ហ្នឹងហើយពីរនាក់ហ្នឹង។

[១០:១៦:៥២]

**ស៖** នៅពេលដែលគេនាំលោកមកទីក្រុងភ្នំពេញ គឺលោកថា លោកគេត្រូវ-- លោកត្រូវបានគេនាំមកធ្វើការនៅ យ១០។ តើនៅពេលនោះលោកមានតួនាទីធ្វើអ្វីដែរនៅ យ១០ ហ្នឹង?

**ឆ៖** យាម។

**ស៖** នៅពេលនោះតើលោកត្រូវបានគេចាត់តាំង ឲ្យធ្វើជាកងការពារសន្តិសុខដល់ថ្នាក់ដឹកនាំបក្សណាដែរទេ?

**ឆ៖** ការពារជុំវិញកន្លែង។ យ១០ នេះការពារជុំវិញ។

**ស៖** ចំពោះរូបលោកផ្ទាល់ តើលោកត្រូវបានគេចាត់តាំង ឲ្យលោកធ្វើជាកងការពាររបស់ថ្នាក់ដឹកនាំបក្សណាដែរទេនៅពេលនុ៎ង?

**ឆ៖** អត់ៗទេ។

**សៈ** លោកបានឆ្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ដែលមានឯកសារលេខD234/23 ឬក៏ E3/443។ លោកបានឆ្លើយថា លោកគឺជាកងការពាររបស់ នួន ជា។ តើលោករក្សាចម្លើយនេះដែរទេ?

[១០:១៩:០៧]

**ប្រធានអង្គជំនុំ៖**

សូមៗអញ្ជើញតំណាង-- មេធាវីអន្តរជាតិការពារក្តី នួន ជា!

**លោក អេនឌ្រូ អ៊ីនូហ្វ៊ី៖**

សូមអរគុណលោកប្រធាន។ ហើយខ្ញុំបានពិនិត្យមើលប្រតិចារឹកក្នុងចម្លើយនោះ ឯកសារដែលដាក់លើអេក្រង់នេះត្រូវបានប្រើ ហើយមិនត្រូវបានជាទម្លាប់អនុវត្តតាមវិធានផ្ទៃក្នុងនោះទេ។ ហើយខ្ញុំជឿថា គប្បីតែជូនច្បាប់លើក្រដាស ដើម្បីឲ្យសាក្សីបានពិនិត្យ បើសិនជាមិនអាចបញ្ចាំងបានលើអេក្រង់ទេ ដូចជា លោកសហព្រះរាជអាជ្ញាអ៊ីចឹង ក៏គប្បីប្រាប់លេខ ERN នៃឯកសារនោះផងដែរ ដើម្បីឲ្យយើងខ្ញុំអាចតាមដានបាន។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ហើយតំណាងសហព្រះរាជអាជ្ញាជាតិគប្បីអនុវត្តដូចអ្វីដែលយើងបានកំណត់វិធានអនុវត្តរួចហើយ ការដែលផ្អែកទៅលើឯកសារត្រូវប្រាប់អត្តសញ្ញាណឯកសារនោះ ហើយប្រសិនបើឈានដល់ចំណុចពាក់ព័ន្ធរហូតដល់ទៅទំព័រ អានោះគឺត្រូវប្រាប់លេខ ERN ជាបីភាសា ឬពីរភាសាយ៉ាងតិចចំពោះឯកសារដែលមានបំណងដាក់ដេញដោល ហើយនិងថតចម្លងឯកសារជាក្រដាសមួយច្បាប់សម្រាប់ជូនទៅសាក្សីពិនិត្យមុនពេលដេញដោល។ ហើយគប្បីសួរសាក្សីផងដែរ បើសិនជាសាក្សីអត់ចេះអក្សរ ហើយដាក់ឲ្យគាត់មើលឯកសារជាអក្សរក៏មិនដឹងថាគាត់មើលយ៉ាងម៉េចដែរ។ នេះត្រូវតែច្បាស់លាស់ទាំងៗល្អិតល្អន់ ទាំងអស់គ្រប់ចំណុចនេះ។

[១០:២១:២៤]

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក សេង ប៊ុនឃាង៖**

**សៈ** លោកសាក្សី តើលោកអាចអានអក្សរបានទេ?

**លោក សូត្រ ទៀង៖**

**ឆ៖** មើលមិនឃើញផង ហើយម្យ៉ាងមិនសូវចេះដែរ វ៉ែនតា-- អានឲ្យស្តាប់មក ស្តាប់--

**លោក សេង ប៊ុនឃាង៖**

លោកប្រធាន ដោយសារសាក្សី គាត់មិនអាចអានអក្សរបាន តើគប្បីត្រូវប្រគល់ឯកសារជូនសាក្សីដដែល ឬក៏មិនបាច់ទេ ឬក៏តំណាងសហព្រះរាជអាជ្ញាគ្រាន់តែអាននូវចំណុច ហើយនិងផ្តល់លេខ ERN ហ្នឹង ជូនដល់សាក្សីដើម្បីស្តាប់បាទ?

[១០:២២:០១]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះជម្រាបហើយអំមិញ គប្បីគិតគូរដល់ការដែលផ្តល់ឯកសារទៅឲ្យសាក្សី បើសាក្សីអត់ចេះអក្សរ យកឲ្យគាត់ដើម្បីធ្វើអី? គោលបំណងនៃការឲ្យមើលឯកសារ គឺអានអក្សរ មើលអក្សរនៅលើឯកសារដែលឲ្យគាត់អាន ហើយបើសិនគាត់អត់ចេះអក្សរផង តើឲ្យគាត់អានយ៉ាងដូចម្តេច? ប៉ុន្តែយ៉ាងហោចណាស់ក៏ត្រូវយោងទៅលើឯកសារដែលពាក់ព័ន្ធនឹងការតាំងសំណួរបង្ហាញអំពីអត្ត-សញ្ញាណឯកសារ ហើយនិងលេខ ERN ឲ្យបានច្បាស់លាស់ដើម្បីភាគីដទៃទៀត គេតាមដានបាននៅលើកិច្ចពិភាក្សាដេញដោលនេះ។ ហើយគួរតែត្រូវបានចងចាំទាំងអស់គ្នានៃការធ្វើកិច្ចដំណើរការនីតិវិធីដេញដោលនៅក្នុងសំណុំរឿងនេះ គឺធ្វើដូច្នេះ។ លើកលែងតែទៅថ្ងៃក្រោយដោយសារវាមានបញ្ហាបច្ចេកទេសដែលមានលក្ខណៈជឿនលឿនជាងនេះ ដែលយើងអានផ្លាស់ប្តូរ និងកែប្រែស្ថានភាពនេះទៅជាស្ថានភាពអ្វីដែលល្អប្រសើរជាងនេះ។

សូមអញ្ជើញ!

[១០:២៣:១៣]

**លោក អេនកូ អ៊ីនូហ្វ៊ី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំយល់ថា ដើម្បីឲ្យច្បាស់ថាតើតុលាការបង្គាប់ឲ្យសហព្រះរាជអាជ្ញា ឬក៏បង្ហាញឯកសារលើអេក្រង់ ដើម្បីឲ្យយើងអាចមើលបាន។ សាក្សីលោកថា អានមិនបានទេបើសិនជាគាត់មានឯកសារនៅក្នុងដៃរបស់គាត់ បើមានឯកសារជាក្រដាស គាត់អាចមើលបាន អាច--គឺថាគាត់ ភ្នែកគាត់មើលមិនសូវច្បាស់ ឬក៏គាត់មិនអាចមើលនៅលើអេក្រង់បាន។ អ៊ីចឹងសូម្បី-- សូមតុលាការសួរបញ្ជាក់ទៅលោកសាក្សីពីបញ្ហានេះ។

**ប្រធានអង្គជំនុំ៖**

អនុវត្តធម្មតាមកលោកតំណាងសហព្រះរាជអាជ្ញា ហើយដូចជាហេតុអីក៏បង្កើតជាបញ្ហាស្មុគស្មាញម្ល៉េះ? ឥឡូវដាក់ទៅ ឲ្យជូនគាត់ទៅ!

បង្ហាញលេខ ERN ហើយនិងដាក់បញ្ចាំងឯកសារនៅលើអេក្រង់ទូរទស្សន៍ កុំព្យូទ័រចំពោះមុខអង្គជំនុំជម្រះសម្រាប់ភាគី និងសាធារណជនមើលផង!

[១០:២៤:២៧]

**លោក សេង ប៊ុនឃាង៖**

បាទ ឯកសារគឺលេខ E3/423 ឬក៏ D234/23។ ដោយសារតែឯកសារនេះ វាមានសំណួរនិងចម្លើយលេខរៀងស្រាប់ហើយ។ ដូច្នេះ បើយើងពិនិត្យទៅលើត្រង់ចម្លើយលេខ២១ នោះឃើញថា លោកសាក្សី គាត់បញ្ជាក់ថា លោកតំណាងឲ្យកងការពាររបស់តា នួន ជា។

**លោក អេនឌ្រូ អ៊ីន្នូហ្សី៖**

សូមអភ័យទោសលោក លោកស្រីចៅក្រម! ខ្ញុំសូមអនុញ្ញាត!

**ប្រធានអង្គជំនុំ៖**

ឥឡូវលោកផ្តល់វេទិកាម្តងទៀត ដូចជាវាញ៉ីកពេក ដូចអត់មានបានដេញដោយអីសោះឥឡូវនេះ។ លោកនិយាយអីឲ្យបានច្បាស់លាស់ និយាយឲ្យបានចប់សព្វគ្រប់មើល៍ ដើម្បីឲ្យភាគីតតាំងឲ្យហើយ លើបញ្ហាការជំទាស់តវ៉ារបស់លោកដើម្បីឈានដល់ការដេញដោលបានទៅមុខ។ បើពុំដូច្នោះទេ វាពុំមែនជានីតិវិធីដេញដោលសាក្សីទេឥឡូវនេះ។ វាទៅជានីតិវិធីនៃការជំទាស់តវ៉ា ក្នុងការមិនឲ្យកិច្ចដំណើរការហ្នឹងអាចទៅមុខរួច។

[១០:២៥:៥៥]

**លោក អេនឌ្រូ អ៊ីន្នូហ្សី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមដោយសង្ខេបទេ គឺថា ត្រឡប់ទៅបញ្ហាដែលខ្ញុំលើកឡើងព្រឹកនេះ ហើយយើងចូលទៅដល់ផ្នែកមួយដែលសាក្សីរូបនេះអាចៗនឹងរងការបំភិតបំភ័យ ហើយគាត់ត្រូវតែជម្រាបសួរសិទ្ធិរបស់គាត់គឺថា វិធានមួយទៀតគឺថា ២៨(៩) ប្រសិនបើមានបញ្ហាកើតឡើងក្នុងការឆ្លើយដាក់បន្ទុកខ្លួនឯង សហចៅក្រមស៊ើបអង្កេត ឬក៏អង្គជំនុំជម្រះសាលាដំបូងអាច ឬក៏ត្រូវៗបង្ហាញឲ្យច្បាស់ លើកលែងតែសាក្សីបោះបង់សិទ្ធិរបស់គាត់ ហើយត្រូវតែផ្តល់សាក្សី នូវមេធាវីដើម្បី

ការពារខ្លួនរបស់គាត់។ ដូច្នេះគោលជំហររបស់គាត់ ហើយសាក្សីរូបនេះមិនបានបោះបង់សិទ្ធិគាត់ទាំងស្រុងទេ ហើយបើការបន្តទៅ អាចនឹងចូលទៅការឆ្លើយដាក់បន្ទុកលើខ្លួនឯង។ សូមស្នើអង្គជំនុំជម្រះឲ្យគាត់មានសិទ្ធិពេញលេញក្នុងការមានមេធាវីជួយគាត់ ហើយយើងខ្ញុំសូមស្នើតាមវិធាន ២០(៩)(៩) ដើម្បីបន្តនីតិវិធីនេះទៅបានបាទ។

[១០:២៧:០៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក វីណ្សៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ យើងខ្ញុំសូមជំទាស់ដោយការរំខានដោយមេធាវីការពារក្តី។ ប្រសិនបើគាត់ចង់លើកនូវបញ្ហានេះ តុលាការបានបញ្ជាក់ហើយថា គប្បីតែគាត់ស្នើឲ្យមានសវនាការអសាធារណៈ ប៉ុន្តែសំណើនោះត្រូវបានបដិសេធ ហើយតុលាការបង្គាប់ឲ្យបន្តដេញដោលសាក្សី ហើយចេះតែបន្តជំទាស់។ ដូច្នេះ យើងខ្ញុំស្នើថា អាចនឹងមានការសម្រាកដើម្បីពិភាក្សាបញ្ហានេះដោយគ្មានវត្តមានសាក្សី ដើម្បីកុំឲ្យសាក្សីរងអារម្មណ៍ ដូចជាការបំភិតបំភ័យលើរូបគាត់។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីតណាង អ៊ំ! មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

[១០:២៨:១២]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថា អន្តរាគមន៍បែបនេះ នៅក្នុងដំណាក់កាលបែបនេះគឺថាមានលក្ខណៈរំលោភបំពាន ហើយមានលក្ខណៈមិនស្មោះត្រង់ទេ។ ការធ្វើឲ្យសាក្សីជឿថា ខ្លួនអាចនឹងត្រូវចោទប្រកាន់នោះគឺវាមិនត្រឹមត្រូវទេ វាជាការរំលោភបំពាន។ ហើយការធ្វើសវនាការអសាធារណៈនោះ ដើម្បីជៀសវាងការដាក់ពិរុទ្ធភាពលើខ្លួននោះ គឺមិនត្រឹមត្រូវទេ ហើយវាមិនស្មោះត្រង់ទៀតផង។ យើងមិន-- នៅពេលដែលគេអត់ដឹងថា តើអ្នកនេះ សាក្សីនិយាយអីនោះ វាមិនត្រឹមត្រូវទេ។ ខ្ញុំសូមឲ្យអង្គជំនុំជម្រះ មេត្តាដោះស្រាយបញ្ហានេះ ហើយសូមឲ្យអង្គជំនុំជម្រះរម្លឹកទៅដល់សាក្សីរូបនេះ។

[១០:២៩:០០]

យោងតាមវិធាន ២៨(៣)(ខ) សូមអង្គជំនុំជម្រះរម្លឹកថា អ្វីដែលគាត់និយាយនោះ មិនមានដាក់

ពិរុទ្ធលើខ្លួនគាត់ទេ យើងត្រូវតែធានាចំពោះសិទ្ធិនេះ។ ដូច្នេះ សូមបញ្ចប់ឲ្យការធ្វើរបៀបនេះ ហើយជាថ្មីម្តងទៀត អន្តរាគមន៍របស់មេធាវីការពារក្តីរបៀបនេះ គឺមិនសម មិនស្មោះត្រង់នោះទេ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីការពារក្តីលោក អៀង សារី!

**លោក ម៉ៃខល កាណាវាស៖**

សូមជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម ហើយនិងភាគីទាំងអស់។ សូមអភ័យទោសដោយថាខ្ញុំមកយឺតបន្តិចព្រឹកនេះ។ កាលពីសប្តាហ៍មុនពេល ឌុច ផ្តល់សក្ខីកម្ម ពេល វីល្លៀម ស្មីត នៅទីនេះ ហើយពេល សាក្សីថ្ងៃនេះគាត់បានបង្ហាញជាសាធារណៈថា ឌុច មានសិទ្ធិ មិនឆ្លើយដាក់បន្ទុកលើខ្លួនឯង។ ហើយមិនបានស្នើសុំថាឲ្យមានសវនាការអសាធារណៈទេ ប៉ុន្តែពេលនេះគាត់បានផ្តើមគំនិតស្នើសុំ ហើយគាត់លើកអន្តរាគមន៍ឲ្យមានសវនាការបែបនោះ។ ប៉ុន្តែយើងយល់ឃើញថាសហព្រះរាជអាជ្ញាមានជំហរមួយ។ ហើយយើងបានស្តាប់មតិរបស់ដើមបណ្តឹងរដ្ឋប្បវេណី គឺមិនត្រឹមត្រូវទេ ពីព្រោះថាភាគផ្សេងទៀតនៃដំណើររឿងគឺថា អាចនឹងគាត់នឹងត្រូវរងការចោទប្រកាន់ក្នុងករណីណាមួយនៅតុលាការផ្សេង នៅក្នុងព្រះរាជាណាចក្រកម្ពុជា ទោះបីជាមិនចំពោះមុខ អ.វ.ត.ក ក្តី គឺអាចតុលាការផ្សេង។ ហើយបើយើងមិនបានធ្វើបែបនោះចំពោះសាក្សី ឌុច ទេ ប៉ុន្តែសាក្សីរូបនេះគឺករណីខុសគ្នា ហើយយើងត្រូវ-- គាត់ដឹងជាមុន ហើយដើម្បីឲ្យភាគីនានាបានជម្រាបដល់អង្គជំនុំជម្រះថា សាក្សីអាចនឹងឆ្លើយដាក់បន្ទុកលើខ្លួនឯង ដើម្បីឲ្យអង្គជំនុំជម្រះចាប់ពីដំបូងនោះអាចនឹងជម្រាបដល់សាក្សីជាមុនឲ្យគាត់បានដឹង ដើម្បីឲ្យសាក្សីបានដឹងច្បាស់ជាមុន។ ប្រសិនបើសាក្សីចង់ឲ្យមានការណែនាំគាត់អាចស្នើ បើសិនគាត់មិនស្នើទេ អាចបន្តបាន។ នេះហើយគឺជាទម្លាប់អនុវត្តនីតិវិធីដ៏ល្អបំផុតនោះ។

[១០:៣១:២៦]

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

សូមអភ័យទោសតុលាការ។ ខ្ញុំសូមអនុញ្ញាតឆ្លើយតបដោយសង្ខេប ហើយខ្ញុំសូមជម្រាបថាខ្ញុំជំទាស់ការលើកឡើងរបស់សហព្រះរាជអាជ្ញានៅក្នុងកំណត់ហេតុដែលលោកថា យើងធ្វើការនេះមិនសមស្របនោះ។ គឺថាអ្វីដែលយើងស្នើឲ្យមានសវនាការអសាធារណៈនោះគឺនៅជាសំណើរបស់យើងខ្ញុំ

ហើយយើងខ្ញុំនឹងមានការពិភាក្សាក្នុងក្រុមរបស់យើងខ្ញុំទៀតអំពីបញ្ហានេះ។

**លោក ខេល លីសាក់៖**

លោកប្រធាន ខ្ញុំមិនយល់ថាការ សវនាការអសាធារណៈនោះគឺជាការចាំបាច់នោះទេ។ ហើយបើសិនជាករណីនេះ ហេតុអ្វីបានជាមេធាវីការពារលើកឡើងនូវបញ្ហានេះ? នៅពេលដែល ឌុច ផ្តល់សក្ខីកម្ម គាត់អះអាងដោយខ្លួនគាត់ថា គាត់-- ចំពោះសិទ្ធិមិនឆ្លើយតបរបស់គាត់ៗ បានប្រើនៅក្នុងករណីមានសំណួរពីរ ម-១៣ ប៉ុន្តែនៅក្នុងករណីសាក្សីរូបនេះគឺថា មិនមែនជាបញ្ហាដែលយើងត្រូវលើកមកជជែកចំពោះមុខសាក្សីបែបនេះនោះទេ។ នេះគឺជំហររបស់សហព្រះរាជអាជ្ញា។

[១០:៣២:៤០]

**លោក អេនឌ្រូ អ៊ីនូហ្វ៊ី៖**

ខ្ញុំសូមជម្រាបតុលាការថា ខ្ញុំមិនព្យាយាមបំភិតបំភ័យសាក្សីនោះទេ គឺថាជាវិធានផ្ទៃក្នុងដែលចែងថា "កាលណាភាគី-- កាលណាសាក្សីយល់ថា ចម្លើយហ្នឹងអាចប្រឆាំងនឹងខ្លួនឯង គឺថាគាត់មានសិទ្ធិ" តាមវិធានផ្ទៃក្នុងគឺថា បាទ គឺយើងមិនបានស្នើថា ឲ្យសាក្សីមានការភិតភ័យទៅលើចំណុចនេះទេ គឺវិធានផ្ទៃក្នុងទេដែលចែងបែបនេះ។

[១០:៣៣:១១]

**ប្រធានអង្គជំនុំ៖**

មានភាគីណាចង់និយាយទៀតទេ? សូមអញ្ជើញ!

មានភាគីណាចង់និយាយបញ្ហានេះទៀតទេ? សូមអញ្ជើញ!

[១០:៣៣:២៧]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៣៤:៥២]

**ប្រធានអង្គជំនុំ៖**

បាទ បើភាគីមិនមានមតិយោបល់អ្វីទៀតទេលើបញ្ហានេះ អង្គជំនុំជម្រះសម្រេចប្រកាសសម្រាក ២៥នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សូមអញ្ជើញលោកមេធាវី!

**លោក អាង ឧត្តមៈ**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ដោយសារបញ្ហាសុខភាពជាពិសេសបញ្ហាឈឺចង្កេះ ឆ្អឹងខ្នង និងជើង។ លោក អៀង សារី ស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនេះសម្រាប់ថ្ងៃនេះពេញតែម្តង ប៉ុន្តែសូមចូលរួមសវនាការដោយប្រយោលពីក្នុងបន្ទប់រង់ចាំខាងក្រោម។ អាស្រ័យហេតុសូមលោកប្រធានមេត្តាពិចារណា និងសម្រេច។ សូមអរគុណ។

[១០:៣៥:៤២]

**ប្រធានអង្គជំនុំ៖**

បាទ បានស្តាប់សំណើសុំរបស់មេធាវី របស់លោកជនជាប់ចោទ អៀង សារី ដែលធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ ស្នើសុំលះបង់សិទ្ធិមិនចូលរួមតាមដានកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ដោយទៅ សុំទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់មួយក្រោមបន្ទប់សវនាការនេះតាមរយៈប្រព័ន្ធសោតទស្សន៍ពេញមួយថ្ងៃនេះ ដោយបញ្ហាសុខភាព។ អង្គជំនុំជម្រះយល់ព្រមតាមសំណើសុំជនជាប់ចោទ នួន ជា ដែលបានស្នើសុំតាមរយៈមេធាវីការពារក្តីរបស់គាត់ដោយលះបង់សិទ្ធិមិនចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយនៅក្រោមបន្ទប់សវនាការនេះ តាមរយៈប្រព័ន្ធសោតទស្សន៍រយៈពេលពេញមួយថ្ងៃនេះ។

[១០:៣៦:២៩]

អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្តីជនជាប់ អៀង សារី ប្រគល់មកអង្គជំនុំជម្រះភ្លាមៗនូវលិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះដោយចុះហត្ថលេខា ឬផ្តិតម្រាមដៃយ៉ាងជាក់ច្បាស់ពីជនជាប់ចោទ អៀង សារី និងបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធ សោតទស្សន៍សម្រាប់ជនជាប់ចោទអាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ អៀង សារី ទៅកាន់បន្ទប់ខាងក្រោមដែលរៀបចំទុកជាសម្រេចនូវឧបករណ៍សោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ និងបង្គាប់ឲ្យ-- និងមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលសាក្សីក្នុងការឈប់សម្រាកនៅកន្លែងសម្រាកសម្រាប់សាក្សី ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនៅវេលាម៉ោងដប់មួយ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣៧ នាទី ដល់ម៉ោង ១១:១០ នាទី)*

[១១:១១:០២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅក្នុងកិច្ចដំណើរការសវនាការ ដែលអង្គជំនុំជម្រះបានគ្រោងទុកនៅក្នុងដំណើរការសវនាការសម្រាប់ថ្ងៃនេះ គឺការស្តាប់សក្ខីកម្មសាក្សី ឈ្មោះ សូត្រ ទឿង ប៉ុន្តែដោយសារបញ្ហាបច្ចេកទេសនៅក្នុងកិច្ចដំណើរការ គឺអង្គជំនុំជម្រះសម្រេចមិន ទាន់ស្តាប់-- បន្តការស្តាប់សក្ខីកម្មរបស់សាក្សីរូបនេះទេ។ កិច្ចដំណើរការស្តាប់សក្ខីកម្មសាក្សីឈ្មោះ សូត្រ ទឿង នេះនឹងលើកទៅបន្តធ្វើនៅរសៀលនេះ។

ហើយមុននឹងបន្តកិច្ចដំណើរការសវនាការពិភាក្សាដេញដោល អង្គជំនុំជម្រះសូមប្រកាសផ្ទាល់ មាត់នូវសេចក្តីសម្រេចពាក់ព័ន្ធនឹងសិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់ជនជាប់ចោទ។ អង្គជំនុំជម្រះកត់ សម្គាល់នូវសំណើសុំពាក់ព័ន្ធនឹងសិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់ជនជាប់ចោទ អៀង សារី និង ខៀវ សំផន ឯកសារ E164 និង E174។ អង្គជំនុំជម្រះកត់សម្គាល់បន្ថែមថា ក្រោយពីបានធ្វើសេចក្តីថ្លែង ការណ៍ពាក់ព័ន្ធនឹងវគ្គទីមួយ នៃការជំនុំជម្រះ ជនជាប់ចោទ នួន ជា បានបញ្ជាក់ថា គាត់អាចរក្សាសិទ្ធិ នៅស្ងៀមមិនឆ្លើយតប។

[១១:១៣:០៦]

អនុលោមតាមមាត្រា៣៥ថ្មី ចំណុច(ខ) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការ កម្ពុជា ជនជាប់ចោទមិនត្រូវបានបង្ខំឲ្យផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង ឬសារភាពអំពីពិរុទ្ធភាពឡើយ។ ហេតុដូច្នេះជនជាប់ចោទមិនអាចត្រូវបានបង្ខំឲ្យឆ្លើយសំណួរដែលត្រូវបានសួរចំពោះគាត់ឡើយ។ ទោះ ជាយ៉ាងណាក៏ដោយ នៅក្នុងការវាយតម្លៃអំពីពិរុទ្ធភាព ឬភាពសុចរិតរបស់ជនជាប់ចោទនៅក្នុង សាលក្រមរបស់ខ្លួន អង្គជំនុំជម្រះនឹងពិចារណានូវរាល់ភស្តុតាង ដែលបានដាក់ចំពោះមុខខ្លួន និងជា

កម្មវត្ថុនៃការពិនិត្យរួមទាំងសក្ខីកម្មរបស់ជនជាប់ចោទ និងរបៀបដែលជនជាប់ចោទផ្តល់សក្ខីកម្ម។

ក្នុងន័យនេះ និងនៅពេលដែលជនជាប់ចោទសម្រេចជ្រើសរើសដោយខ្លួនឯងរវាងសិទ្ធិនៅស្ងៀមមិនឆ្លើយតបនឹងការផ្តល់សក្ខីកម្មនោះ អង្គជំនុំជម្រះអាចនឹងកត់សម្គាល់អំពីបញ្ហានេះនៅពេលវាយតម្លៃអំពីភាពគួរឱ្យជឿជាក់បានរបស់គាត់។

យុត្តិសាស្ត្រអន្តរជាតិ ដែលពាក់ព័ន្ធបង្ហាញថា ការសម្រេចជ្រើសរើសដោយខ្លួនឯងក្នុងការនៅស្ងៀមមិនឆ្លើយតបអាចត្រូវបានប្រើក្នុងការទាញចេញជាសេចក្តីសន្និដ្ឋានផ្ទុយ។

[១១:១៤:៤៦]

នៅក្នុងករណីណាក៏ដោយ អង្គជំនុំជម្រះនឹងមិនផ្អែកទាំងស្រុងលើការទាញជាសេចក្តីសន្និដ្ឋានផ្ទុយចេញពីការរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបនៅក្នុងការវិនិច្ឆ័យអំពីកំហុសឡើយ។

បាទនេះជាសេចក្តីសម្រេចពាក់ព័ន្ធទៅនឹងការរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់ជនជាប់ចោទ។ ហើយជាកិច្ចបន្តអង្គជំនុំជម្រះសម្រេចធ្វើសវនាការជាអសាធារណៈ ដោយមិនពិភាក្សាដេញដោលលើសាក្សី ទៅលើអង្គហេតុដែលពាក់ព័ន្ធនឹងការផ្តល់សក្ខីកម្មនោះឡើយ។ ដោយសារបញ្ហាបច្ចេកទេសនៃការពិភាក្សាផ្ទៃក្នុងភាគីជាមួយនឹងអង្គជំនុំជម្រះ ដើម្បីរកដំណោះស្រាយជាមូលដ្ឋានក្នុងការអនុវត្តនូវវិធាន២៨ ចំណុច(៨), (៩) គឺសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងខ្លួនឯង ដែលបញ្ហានេះវាមានការចម្រូងចម្រាសខ្លាំងកាលពីព្រឹកមិញ ដើម្បីដោះស្រាយបញ្ហារួមក្នុងការបន្តធ្វើសក្ខីកម្ម ស្តាប់សក្ខីកម្មទៅមុខទៀតឱ្យបានច្បាស់លាស់ជ្រះស្រឡះនោះ អង្គជំនុំជម្រះសម្រេចបើកសវនាការអសាធារណៈ ដែលពិភាក្សាផ្ទៃក្នុងរវាងភាគីជាមួយនឹងអង្គជំនុំជម្រះលើបញ្ហានេះ សម្រាប់ដំណើរការសវនាការនេះរហូតដល់ពេលថ្ងៃត្រង់។ ដូច្នេះ សូមសាធារណជនជម្រាប។ ហើយបង្គាប់ឱ្យមន្ត្រីរដ្ឋបាលតុលាការរួតបិទវាំងនន ហើយនិងប្រព័ន្ធសោតទស្សន៍ផ្តាច់សំឡេងរូបភាពបញ្ចេញទៅសាលសាធារណៈ។

[១១:១៦:៣៥]

ហើយសាធារណជនអាចសម្រាកបានហើយ រហូតដល់ក្រោយពេលអាហារថ្ងៃត្រង់ ទើបអាចអង្គជំនុំជម្រះនឹងពិនិត្យពិចារណាសម្រេចថា តើធ្វើសវនាការតាមបែបណា សាជាថ្មីបន្ទាប់ពីការជជែកពិភាក្សា លើបញ្ហាបច្ចេកទេសក្នុងការសួរដេញដោលសាក្សីរូបនេះ។

សន្តិសុខ អញ្ជើញសាធារណជនចេញក្រៅ ចេញក្រៅបន្ទប់សវនាការ!

*(សវនាការអសាធារណៈចាប់ផ្ដើមពីម៉ោង១១:១៩នាទី ដល់ម៉ោង ១២:០៩នាទី)*

*(សវនាការជាសាធារណៈបន្តចាប់ពីម៉ោង ១៣:៣៦នាទី)*

[១៣:៣៦:៥៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ឥឡូវនេះអង្គជំនុំជម្រះបន្តការស្ដាប់សក្ខីកម្មសាក្សី សូត្រ ទឿង ដែលនឹងសួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញា។ ហើយឥឡូវនេះសួស្ដីលោក សូត្រ ទឿង! ឥឡូវនេះ លោកមានមេធាវីហើយ។ ដូច្នេះលោកអាចស្ដាប់នូវសំណួរដែលសួរ ហើយនិងឆ្លើយតបទៅនឹងសំណួរមកអង្គជំនុំជម្រះ ដើម្បីបានយល់ដឹងអំពីព័ត៌មានទាំងឡាយដែលលោកបានដឹង ពាក់ព័ន្ធទៅនឹងអង្គហេតុដែលបានចោទប្រកាន់ ហើយនិងអង្គហេតុបញ្ហានានា ព្រឹត្តិការណ៍នានា ដែលលោកបានដឹងពាក់ព័ន្ធទៅនឹងសំណួរដែលសួរ។ ហើយថ្ងៃនេះ គឺលោកមានវត្តមានមេធាវីដែលបានរៀបចំឡើងដោយអង្គភាពគាំពារសាក្សីអ្នកជំនាញ តាមការស្នើសុំរបស់អង្គជំនុំជម្រះ។

[១៣:៣៨:៥១]

ហើយលោកមេធាវីតើលោកឈ្មោះអីដែរ លោកមេធាវី?

**លោក លឹម ប៊ុនហេង៖**

បាទ ខ្ញុំបាទ ឈ្មោះ លឹម ប៊ុនហេង។

**ប្រធានអង្គជំនុំ៖**

លោកឲ្យអត្តលេខបានទេ? អត្តលេខប៉ុន្មានទៅ?

**លោក លឹម ប៊ុនហេង៖**

៦៨៩។

**ប្រធានអង្គជំនុំ៖**

អត្តលេខ?

**លោក លឹម ប៊ុនហេង៖**

៦៨៩។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

នៅក្នុងកិច្ចដំណើរការនេះ គឺលោកចូលមកការពារសាក្សីក្នុងនាមផ្តល់សក្ខីកម្ម ក្នុងន័យថា បញ្ចៀសនូវរាល់ការដែលសំណួរទាំងឡាយដែលបំណងឲ្យសាក្សីឆ្លើយដាក់ពិរុទ្ធភាពលើខ្លួនឯង។ មិនមែនលោកៗមេធាវីចូលមកការពារសាក្សីនេះ ក្នុងនាមគាត់ជាជនជាប់ចោទទេ។ ដូច្នេះ គឺលោកអាចពិភាក្សា សុំការពិភាក្សាជាមុនៗនឹងឆ្លើយ ឲ្យសាក្សីឆ្លើយតបនឹងសំណួរ នៅពេលមានសំណួរឯណាដែលសួរទៅហើយឲ្យលទ្ធផលនៃការឆ្លើយរបស់គាត់ហ្នឹង ឲ្យគាត់ឆ្លើយដែលមានខ្លឹមសារអាចដាក់ពិរុទ្ធភាពលើខ្លួនឯង ឬធ្វើសេចក្តីសន្និដ្ឋាន ឬអះអាងណាមួយ-- អ៉ន៎ធ្វើសេចក្តីអត្ថាធិប្បាយ ឬអំណះអំណាងណាមួយដែលដាក់ពិរុទ្ធភាពលើខ្លួនឯងប៉ុណ្ណោះ ពីព្រោះក្នុងន័យ គឺការពារ បញ្ចៀសឲ្យផុតពីការដែលសាក្សីធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ លោកមេធាវីយល់ទេ?

**លោក លឹម ប៊ុនហេង៖**

បាទ ខ្ញុំយល់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ អង្គជំនុំជម្រះផ្តល់វេទិកា ជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសក្នុងការតាំងសំណួរ ដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។ បាទ ជាបន្តខ្ញុំសូមអនុញ្ញាតពីលោកប្រធាន ដើម្បីដាក់បញ្ចាំងនូវឯកសារលេខ E3/423 នៅលើអេក្រង់ ហើយឯកសារនេះក៏បានប្រគល់ឲ្យទៅសាក្សីរួចហើយផងដែរ។

[១៣:៤១:០៣]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** លោកសាក្សី ខ្ញុំបន្តសំណួរតទៅទៀត។ កាលពីយើងសម្រាក ខ្ញុំបានលើកឡើងអំពីឯកសារដែលមានលេខ E3/423 ហើយឯកសារហ្នឹងគឺលោកបានឆ្លើយ នៅចំពោះមុខការិយាល័យ

សហចៅក្រមស៊ើបអង្កេត។ នៅត្រង់ចម្លើយលេខ១៩ នៃឯកសារហ្នឹង លោកបានឆ្លើយថា ខ្ញុំសូមអានពាក្យរបស់លោកទាំងស្រុងតែម្តងគឺថា "ខ្ញុំចង់និយាយការពិតបីចំណុច គឺអំពីការអមដំណើរតា នួន ជា ទៅទស្សនកិច្ចនៅប្រទេសចិន។ ទីពីរ អំពីតួនាទីរបស់ខ្ញុំជាអង្គរក្សការពារតា នួន ជា និងទីបី អំពីតួនាទីរបស់ខ្ញុំជានីរសារបញ្ជូនសំបុត្រដើម្បីកុំឲ្យមានការសង្ស័យតទៅទៀត"។ តើការឆ្លើយរបស់លោកនេះ លោកឆ្លើយដោយស្មោះត្រង់ និងត្រឹមត្រូវដែរទេកាលនុ៎ង?

**លោក សូត្រ ទៀង៖**

**ឆ៖** ត្រឹមត្រូវ។

[១៣:៤២:៣៣]

**ស៖** បាទ អរគុណ។ ហើយនៅក្នុងឯកសារនេះដែរ ត្រង់ចម្លើយលេខ៤៧ និងចម្លើយលេខ៤៨ ខ្ញុំសូមអានជូនលោកដែរ លោកបានឆ្លើយថា "ខ្ញុំជាអង្គរក្សរបស់តា នួន ជា ដែលមានភារកិច្ចការពារជុំវិញគាត់ទាំងយប់ទាំងថ្ងៃ ដើម្បីសុវត្ថិភាពរបស់គាត់"។ ហើយចម្លើយលេខ៤៨ គឺលោកបានឆ្លើយដែរថា "ខ្ញុំបានធ្វើជាអង្គរក្សរបស់តា នួន ជា ប្រហែលជាពាក់កណ្តាលឆ្នាំ១៩៧៥ រហូតដល់ពេលទៅប៉េកាំង ប្រហែលឆ្នាំ១៩៧៧"។ តើការឆ្លើយនេះត្រឹមត្រូវដោយស្មោះត្រង់ទេ?

**ឆ៖** ត្រឹមត្រូវ។

**ស៖** បាទ សូមអរគុណ។ តើលោកអាចឆ្លើយបញ្ជាក់ជូនអង្គសវនាការបានទេថា លោកបម្រើការងារជានីរសាររបស់លោក នួន ជា ហ្នឹងដែរទេ?

**ឆ៖** ខ្ញុំបានមួយរយៈដែលនាំឲ្យគាត់ ដូចដែលខ្ញុំធ្វើកាលមុនហ្នឹងថា ធ្លាប់ជូនសំបុត្រគាត់ទៅកន្លែង តាឌុច នៅទួលស្លែង។ ប៉ុន្តែសំបុត្រហ្នឹងមិនដឹងសំបុត្រអីទេណា ពេលហ្នឹងមានជាច្រើនដងដែរ មួយរយៈហ្នឹងប្រហែលជាបួនប្រាំដងហ្នឹង។ ខ្ញុំបញ្ជូនមែន។

[១៣:៤៤:១១]

**ស៖** បាទ អរគុណ។ តើលោកធ្វើការជាអង្គរក្ស ហើយនិងជានីរសាររបស់លោក នួន ជា ហ្នឹង អស់រយៈពេលប៉ុន្មានដែរ? លោកនៅចាំទេ?

**ឆ៖** វាអាចជា ប្រហែលជាបីឆ្នាំ។

**ស៖** កម្មាភិបាលនៅ យ១០ ដែលលោកធ្វើការនៅជាមួយនោះ តើត្រូវបានគេចាត់តាំងឲ្យទៅធ្វើការជាមួយលោក នួន ជា សរុបទាំងអស់ប៉ុន្មាននាក់ លោកដឹងទេ?

**ឆ៖** អត់ដឹងដែរ កម្លាំងចល័ត កម្លាំងជិះឡាន ទៅម្តងៗយ៉ាងតិចក៏បួនដប់នាក់ដែរ អត់ចំណាំឈ្មោះទេ អត់ចាំដែរ។ ជិះឡានទៅជាមួយ។

**សៈ** ចុះអ្នកដែលទៅការពារគាត់ជាប្រចាំតែម្តង សម្រាប់ក្រុម យ១០ របស់លោកទៅប៉ុន្មាននាក់ដែរ? មានប៉ុន្មាននាក់ដែលទៅការពារលោក នួន ជា ហ្នឹង?

**ឆ៖** ខ្ញុំអត់សូវចាំទេ ព្រោះមនុស្សវាច្រើន ចល័តគ្នា ឧស្សាហ៍ផ្លាស់ប្តូរ។

**សៈ** អ៊ីចឹងលោកដឹងទេថា នរណាគេជាប្រធានក្រុមដែរនៅពេលនុ៎ង?

**ឆ៖** ប្រធានក្រុម ខ្ញុំវាភ្លេចដែរ វាឈ្មោះ គឺ អានោះកងតូចដែរ ប្រធានក្រុមណ៎ះ ខ្ញុំភ្លេចដែរណ៎ះ អត់ស្គាល់ដែរ អត់ចំណាំដែរ។ បើកងតូចប្រហែល មិត្តគឺ ហើយនិងប្រធានក្រុម-- វាអត់ចាំដែរ។ មើលគិតមើល៍ វាយូរដែរ។ ពីរ-បីក្រុម កម្លាំងការពារគេហ្នឹង ប្រធានក្រុម។ ដល់ ខាំ មី គេមេកងគេ។

[១៣:៤៦:២៦]

**សៈ** បាទអរគុណ។ ចុះលោកធ្លាប់ធ្វើជាប្រធានក្រុមដែរទេ នៅក្នុងក្រុមនុ៎ង?

**ឆ៖** អត់ដែរ ធ្វើប្រធានក្រុម។

**សៈ** ក្នុងក្រុមរបស់លោកហ្នឹងមានកាន់អាវុធ ដើម្បីការពារថ្នាក់ដឹកនាំនេះដែរទេ?

**ឆ៖** កាន់។

**សៈ** តើលោកចាំទេថា អាវុធប្រភេទអីខ្លះទៅពេលនុ៎ង?

**ឆ៖** មានអាកា សេកាសេ ពីរមុខ។

**សៈ** បាទអរគុណ។ ចុះលោកដឹងទេថាពេលដែលលោក នួន ជា គាត់ចេញទៅណាមកណាហ្នឹង គាត់មានកាន់អាវុធអីដែរទេ?

**ឆ៖** អត់ដែលឃើញកាន់អីណា កងការពារកាន់។

**សៈ** តើអ្នកដែលធ្វើការនៅ យ១០ ផ្សេងទៀតហ្នឹងមានបានចាត់តាំងឲ្យធ្វើជាអង្គរក្ស ឬក៏ជានីរសាររបស់ ដូចជា ប៉ុល ពត, អៀង សារី, ខៀវ សំផន អីដែរទេ? លោកមានដឹងទេ?

**ឆ៖** អត់ៗដឹងទេ។

[១៣:៤៧:៥៧]

**សៈ** តើលោកអាចបញ្ជាប់បានទេថា ទីតាំង យ១០ នុ៎ងមានទីតាំងនៅត្រង់ណាដែរ នៅក្នុងក្រុងភ្នំពេញនេះ?

**ឆ៖** គឺនៅជាប់ ក១។ ស្ថានទូតអាមេរិក។

**ស៖** បាទអរគុណ។ ខ្ញុំត្រឡប់ទៅសំណួរមួយ សុំឲ្យលោកបញ្ជាក់ឡើងវិញ ដែលថាតើលោកធ្លាប់ធ្វើជាកងទ័ពច្បាំងជាមួយនឹងកងទ័ពខាងភាគីខាងណាដែរទេ?

**ឆ៖** ធ្លាប់ តែច្បាំង មិនសូវបានច្បាំងទេ បានតែធ្លាប់តែការពារប៉ុណ្ណោះឯង។ មកដល់យើងបែកគ្នាទៅ រត់ទៅព្រំដែន បានតែដឹកស្បៀងអាហារគ្រាប់ហ្នឹងហើយ។ មិនដែលបានច្បាំងទេ។

**ស៖** លោកដឹងទេថាពេលនុ៎ងនៅពេលណា ក្នុងខែណា ឆ្នាំណា ហើយនៅកន្លែងណាដែរ?

[១៣:៤៩:០៨]

**ឆ៖** ឆ្នាំទីប៉ុន្មាន?

**ស៖** នៅពេលដែលលោកដឹកស្បៀង ឬក៏ទៅជូនកងទ័ពមកច្បាំងហ្នឹង?

**ឆ៖** ៧៩-៨០ កាល អ៎!អង្កាល់រត់ទៅលិច ៧៩-៨០ ហ្នឹងឯង ៨១-៨២។

**ស៖** និយាយពីមុនឆ្នាំមួយពាន់--

**ឆ៖** មុន ៧៣-៧៤ ហ្នឹង។

**ស៖** នៅពេលនុ៎ងលោកមានដឹងទេថា មានអីកើតឡើងទៅចំពោះទាហាន លន់ នល់ ដែលកងកម្លាំងកងទ័ពបដិវត្តន៍ចាប់បាន?

**ឆ៖** អត់ដឹងដែរ ព្រោះយើងមិនបានទៅវ៉ៃផ្ទាល់។

**ស៖** ចុះអង្គភាពរបស់លោកដែលលោកធ្វើការហ្នឹងស្ថិតនៅក្នុងផ្នែកណា? ហើយភូមិភាគណាដែរ?

**ឆ៖** ធ្វើការហ្នឹង នៅកំពង់ចាម ខេត្តកំពង់ចាម។

**ស៖** លោកអាចបញ្ជាក់អំពីភូមិភាគ ឈ្មោះភូមិភាគបានទេ?

**ឆ៖** វាអត់ស្គាល់ទេ។

**ស៖** តើលោកនៅចាំទេថា នៅពេលនុ៎ងនរណាជាមេបញ្ជាការនៅអង្គភាពដែលលោកធ្វើការហ្នឹង?

[១៣:៥១:០២]

**ឆ៖** កាលណោះមានតែ នែ៎ អាប៉ង់! បញ្ជាការ។

**ស៖** តើលោកស្គាល់ឈ្មោះ ប៉ង់ ហ្នឹងពេញលេញទេ តើគាត់ឈ្មោះអី? ហើយ--

**ឆ៖** គាត់ហៅថាឈ្មោះ ប៉ង់ គាត់ធ្លាប់ចេញចូល។

**ស៖** បាទ អរគុណ។ បាទ ឥឡូវខ្ញុំត្រឡប់មកអង្គភាព យ១០ បន្តិចទៀត។ នៅអំឡុងពេលដែលលោកធ្វើការនៅអង្គភាព យ១០ នៅទីក្រុងភ្នំពេញហ្នឹង តើការហូបចុក ការស្នាក់នៅរបស់លោកហ្នឹងស្ថិតនៅកន្លែងណាដែរ?

**ឆ៖** នៅអាក្នុងបន្ទាយគេ ថាបន្ទាយកងទ័ពហ្នឹងឯង ដែលរួម ចង្ក្រានបាយរួមគ្នា។ ដល់ហើយបានចេញទៅ ក១ ។

**ស៖** លោកនៅចាំទេថា អ្នកធ្វើការនៅ យ១០ ទាំងអស់ហ្នឹងមានប៉ុន្មាននាក់ដែរ?

**ឆ៖** យី! កម្លាំងវាច្រើនដែរ ប្រហែលជា៣០នាក់ឯណោះ ប៉ុន្តែខ្ញុំអត់ចំណាំដែរ អត់ចាំដែរមេគេ។ ខាំ មី មិនដឹង គឺ មិនដឹងពីណា អត់ចាំទេ។ ខ្ញុំនៅរយៈខ្លីដែរ ប្រហែលបីខែ។

**ស៖** ចុះលោកចាំទេថា នរណាជាប្រធាន និងអនុប្រធានរបស់អង្គភាព យ១០ ហ្នឹង?

[១៣:៥២:៥៧]

**ឆ៖** មានប្រធាន ខាំ មី អនុប្រធាន មិនដឹងពីណាទេ ភ្លេចហើយ ថាខ្លាចលោខុស។ ជំនាន់ តាគឺមិនដឹងពីនរណាតែពីរនាក់ហ្នឹង ពីរនាក់អាប្រធាន អនុប្រធានហ្នឹង។

**ស៖** ចុះលោកស្គាល់ឈ្មោះ សាមី ទេ?

**ឆ៖** សាមី អីមិនស្គាល់!

**ស៖** គាត់មានតួនាទីអ្វីដែលនៅក្នុង យ១០?

**ឆ៖** គាត់អានុំងហើយខ្ញុំថា អានុំង ខាំ មី ក៏មិនដឹង ខ្ញុំមិនចំណាំដែរ។

[១៣:៥៣:៤៤]

**ស៖** ទាក់ទងទៅនឹងការរាយការណ៍អំពីសកម្មភាពផ្សេងៗរបស់ យ១០ ទៅថ្នាក់លើ ហើយនិងការទទួលបញ្ជាផ្សេងៗពីថ្នាក់លើមកវិញហ្នឹង។ តើប្រធាន និងអនុប្រធានហ្នឹងរាយការណ៍ទៅខាងណាហើយទទួលបទបញ្ជាពីខាងណាមកដែរ?

**ឆ៖** អាហ្នឹង ខ្ញុំមិនច្បាស់ដែរ មិនដឹងខាងលើ ទទួលបញ្ជាពីខាងលើហ្នឹងឯង ពីអង្គការហ្នឹងឯង។

**ស៖** តើលោកដឹងថា អ្វីទៅជា ក១, ក៣ តើកន្លែងហ្នឹងជាកន្លែងអ្វី សូមលោកជួយរៀបរាប់ជូនអង្គសវនាការ?

**ឆ៖** ក១, ក៣ ៗរបស់អង្គការនេះឯង មន្ទីរអង្គការគេ។

**ស៖** បាទ អរគុណ។ មន្ទីរ ក១ ហ្នឹងមានទីតាំងនៅកន្លែងណាដែរ?

**ឆ៖** *(ឮមិនច្បាស់)* នៅចតុមុខ នៅមាត់ទន្លេ។

**ស៖** សូមលោកជួយរៀបរាប់ថា តើមន្ទីរ ក១ នេះត្រូវបានការពារយ៉ាងដូចម្តេច? ឧទាហរណ៍ ដូចជាមានប៉ុស្តិ៍យាម និងជញ្ជាំង មានរបងព័ទ្ធជុំវិញបរិវេណនោះដែរទេ?

**ឆ៖** បាទ មាន។

**ស៖** ចុះមន្ទីរ ក៣ មានទីតាំងនៅកន្លែងណាដែរ?

**ឆ៖** នៅជាប់នឹងផ្សារថ្មីហ្នឹង។ ហ្នឹងខ្ញុំភ្លេចដែរ។

**ស៖** សូមលោកជួយរៀបរាប់ជូនអង្គសវនាការ អំពីការការពារសន្តិសុខនៅមន្ទីរ ក៣ តើធ្វើយ៉ាងដូចម្តេចខ្លះ?

**ឆ៖** ការពារសន្តិសុខនៅ ក៣, ក១ ដូចតែគ្នា។ យាមកាមអីជុំវិញ យាមទាំងយប់ទាំងថ្ងៃហ្នឹង ដាក់វេនគ្នា។

**ស៖** បាទអរគុណ។ តើមានថ្នាក់ដឹកនាំណាខ្លះ ដែលលោកបានឃើញឧស្សាហ៍ចេញចូលនៅមន្ទីរ ក១ និង ក៣ ហ្នឹង?

[១៣:៥៦:១៥]

**ឆ៖** ខ្ញុំអត់សូវចាំដែរ ប៉ុន្តែមានពួកគណៈតំបន់ហ្នឹងឯងចេញចូល។ ខ្ញុំអត់ចំណាំ ចំណាំគេដែរ។

**ស៖** លោកអាចជួយបញ្ជាក់ជូនអង្គសវនាការអំពីឈ្មោះរបស់អ្នកដែលចេញ-- អ្នកដែលលោកឧស្សាហ៍ឃើញចេញចូលនៅមន្ទីរនុំងបានដែរទេ?

**ឆ៖** ខ្ញុំចំណាំតា វន វេត, តាធុច ហើយតាណាខ្លះទេ ពួកតាញឹម ពួកអីហ្នឹង។ ខ្ញុំអត់ចាំទេ។ ហើយពួក តាកឺ បើតំបន់ខ្ញុំធ្លាប់ឃើញចូលប៉ុណ្ណឹងឯង ក្រៅពីហ្នឹងអត់ស្គាល់ទេ អត់ចំណាំទេ។

**ស៖** ចុះថ្នាក់ដឹកនាំបក្សផ្សេងៗទៀត ដែលលោកអាចចាំបានទេ?

**ឆ៖** អត់ចាំទេ។

**ស៖** ចុះលោកមានដែលឃើញដូចជា ប៉ុល ពត, នួន ជា ឬ សុន សេន, ខៀវ សំផន, អៀង សារី អីហ្នឹងដែលចូល ចេញចូលទីនោះទេ?

**ឆ៖** ធ្លាប់ឃើញដែរ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

[១៣:៥៧:៣៣]

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ ដូចយឺតបន្តិច ពីព្រោះថា ចម្លើយគឺថាឲ្យគាត់ឆ្លើយ “បាទ-- *យេស* ហើយគាត់ឆ្លើយ “បាទ”។ ហើយសហព្រះរាជអាជ្ញាបានប្រើសំណួរបែបឲ្យជម្រើសទៅសាក្សី។ នេះជាសំណួរនាំមុខ គឺថាឲ្យគាត់ជ្រើសរើសមែន ឬមិនមែន។ ដូច្នេះ ខ្ញុំសូមជម្រាបតុលាការនៅពេលដែលគាត់បានចម្លើយហើយ គាត់មិនឆ្លើយទេ ទៅមុខទៀត ជាជាងនាំមុខឲ្យសាក្សីឆ្លើយ។ បើសិនជាគាត់ថាមិនដឹង បន្ទាប់មកសហព្រះរាជអាជ្ញាបែរជាផ្តល់ពហុធាបែបចម្លើយពីរឲ្យជ្រើសរើស។ ដូច្នេះៗយើងខ្ញុំនឹងជំទាស់ទៅនឹងការប្រើវិធីសាស្ត្របែបនេះ បើសិនជាបន្តបែបនេះទៅមុខទៀត។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមលោកតំណាងសហព្រះរាជអាជ្ញាជាតិ រៀបចំនូវសំណួរ ការតាំងសំណួរ និងវិធីសាស្ត្រក្នុងការសួរដេញដោលចំពោះសាក្សី ធ្វើយ៉ាងណាឲ្យត្រឹមត្រូវ ចៀសវាងមានការជំទាស់តវ៉ាពីភាគីម្ខាងទៀត ដោយមូលហេតុលើសំណួរទាំងឡាយដែលច្បាប់ហាមឃាត់។

ហើយសូមរំឭកសាក្សីផងដែរថា សូមសាក្សីបង្អង់បន្តិច រង់ចាំក្បាលមីក្រូ ហ្នឹងមានសញ្ញាក្រហម សឹមនិយាយ។ កត់សម្គាល់ឃើញលោកច្រើនលើកច្រើនសា លោកភ្លេចខ្លួន និយាយនៅៗពេលដែលមិនទាន់ក្បាលមីក្រូ មានសញ្ញាក្រហម ភ្លើងក្រហមអ៊ីចេះ នាំឲ្យអត់បាន-- ភាគីពាក់ព័ន្ធអត់បានស្តាប់ទេ ហើយជាពិសេសអ្នកបកប្រែស្តាប់អត់បានទេ។

**លោក សេង ប៊ុនឃាង៖**

លោកប្រធានខ្ញុំសូមលោកបញ្ជាមួយ ទាក់ទងនឹងថា ដូចលោកមេធាវីគាត់បានលើកអម្បាញ់មិញហ្នឹង បើយើងពិនិត្យទៅលើចម្លើយរបស់សាក្សី គឺគាត់មិនបានចាំ។ អ៊ីចឹងហើយដែលតំណាងសហព្រះរាជអាជ្ញាសួរ ហើយចម្លើយនេះក៏គាត់បានឆ្លើយនៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេតផងដែរ ដែលមាននៅក្នុងឯកសារលេខ E3/103 នៅត្រង់ទំព័រលេខ ERN ជាភាសាខ្មែរ គឺ 00204014, ជាភាសាអង់គ្លេស 00204020 ហើយនិងជាភាសាបារាំង 00490624, ដែលនៅក្នុង

ហ្នឹងគាត់បានឆ្លើយដែលថា ខ្ញុំសូមដកស្រង់សម្ដីរបស់គាត់ "ខ្ញុំមិនមែនជាអ្នកការពារ ឬក៏អង្គរក្សផ្ទាល់របស់មេដឹកនាំទាំងនោះទេ។ ប៉ុន្តែអង្គភាព យ១០ នេះក៏មានតួនាទីការពារឲ្យ ប៉ុល ពត, នួន ជា, សុន សេន ហៅ ខៀវ, ខៀវ សំផន ហៅ ហែម, អៀង សារី ហៅ វ៉ាន់ និង វន វ៉េត។ មនុស្សទាំងអស់នេះសុទ្ធតែចេញចូលកន្លែង ក១ និង ក៣ ហើយក៏ឃើញ កុយ ធួន ចេញចូលកន្លែង ក១ និង ក៣ ដែរ"។

[១៤:០០:៣៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាង-- លោកមេធាវីអន្តរជាតិការពារក្ដីលោក អៀង សារី!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ នៅពេលព្រឹកនេះ ខ្ញុំលើកការព្រួយបារម្ភអំពីអ្វីដែលព្រះរាជអាជ្ញាបានប្រុងនឹងធ្វើ ហើយឥឡូវគាត់ធ្វើនៅរឿងនេះ។ គឺថានៅពេលដែលគាត់ចង់ឲ្យសាក្សី គាត់រំឭកឡើងវិញ ឬក៏ចង់ចោទសួរទៅលើសាក្សីហ្នឹងគួរតែបង្ហាញនូវឯកសារ។ ទោះបីថាការធ្វើហ្នឹង វាត្រឹមត្រូវឬមួយក៏ឲ្យអ្នកណាម្នាក់ផ្សេងដែលដឹង ដើម្បីធ្វើឲ្យបានត្រឹមត្រូវនោះ។ គឺថាគាត់បានចោទសួរ ហើយ និងឆ្លើយនូវសំណួរ។

[១៤:០១:២២]

ទាក់ទងទៅនឹងប្រយោគមួយនេះ គឺថា គាត់គួរតែអនុញ្ញាតឲ្យសាក្សីអាន ឬក៏មើលទៅលើប្រយោគមួយនេះ។ បន្ទាប់មកទុកឲ្យសាក្សីផ្ដល់នូវហេតុផល ហេតុអ្វីបានជាម្ដងគាត់និយាយបែបនេះម្ដងទៀតគាត់និយាយបែបនេះ? ដូច្នេះ គឺថាព្រះរាជអាជ្ញាគួរតែយល់ គួរតែចាំអំពីចំណុចទាំងអស់នេះ។ ប៉ុន្តែយើងគួរតែពន្យល់អំពីហេតុផល ឬក៏យើងប្រើប្រាស់នូវវិធីសាស្ត្រណាមួយ ដើម្បីឲ្យសាក្សីគាត់បង្ហាញថា ហេតុអ្វីបានជាគាត់និយាយម្ដងបែបនេះ ម្ដងបែបនោះ។

ខ្ញុំគិតថានេះ គឺជាវិធីសាស្ត្រដែលព្រះរាជអាជ្ញាបានប្រើកាលពីអាទិត្យមុន ហើយប្រសិនបើយ៉ាងណា គាត់មិនគួរបន្តមកសប្ដាហ៍នេះទៀតទេ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះរំឭកតំណាងសហព្រះរាជអាជ្ញាថា គ្រាន់តែឲ្យមានការផ្លាស់ប្ដូរនូវវិធីសាស្ត្រក្នុងការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក សេង ប៊ុនឃាង៖**

បាទ អរគុណលោកប្រធាន។ ជាបន្តខ្ញុំសូមអនុញ្ញាតប្រគល់ឯកសារលេខ E3/103 ជូនទៅសាក្សីដើម្បីរំឭកការចងចាំរបស់គាត់បាទ។

[១៤:០២:៣៥]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីតំណាងសហព្រះរាជអាជ្ញាជាតិជូនសាក្សីពិនិត្យ។

មានឯកសារដាក់បញ្ចាំងនៅលើឯកសារ-- នៅលើអេក្រង់ទូរទស្សន៍ទេ?

**លោក សេង ប៊ុនឃាង៖**

មានហើយ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាតដាក់បញ្ចាំងឯកសារនៅលើអេក្រង់កុំព្យូទ័រ។

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណ។

[១៤:០៣:១៦]

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** លោកសាក្សី នៅឯកសារលេខ E3/103 នេះនៅត្រង់ ERN ជាភាសាខ្មែរ 00204014, ជាភាសាអង់គ្លេស 00204020, ជាភាសាបារាំង 00490624។ ពោលគឺនៅត្រង់ទំព័រទី២ ជាភាសាខ្មែរ។ លោកបានជម្រាបជូនសហចៅក្រមស៊ើប-- ការិយាល័យសហចៅក្រមស៊ើបអង្កេតថា "ប៉ុល ពត, នួន ជា, សុន សេន ហៅ ខៀវ, ខៀវ សំផន ហៅ ហែម, អៀង សារី ហៅ វ៉ាន់ និង វន វ៉េត មនុស្សទាំងនេះសុទ្ធតែចេញចូលកន្លែង ក១ និង ក៣ ហើយក៏ឃើញ កុយ ធួន ចេញចូលកន្លែង ក១ និង ក៣ ដែរ"។ តើលោកឆ្លើយនៅពេលនោះត្រឹមត្រូវដែរទេ?

**លោក សូត្រ ទឿង៖**

**ឆ៖** ត្រឹមត្រូវ។

[១៤:០៤:៤៤]

**ស៖** បាទ សូមអរគុណ។ តើលោកនៅចាំទេថា ថ្នាក់ដឹកនាំណាខ្លះដែលស្នាក់នៅ ក១ ហើយ ថ្នាក់ដឹកនាំណាខ្លះស្នាក់នៅ ក៣?

**ឆ៖** ក១ មានតែតា នួន ជា ហ្នឹងហើយ គាត់ផ្លាស់គ្នា មិនដឹងដែរ។ តា នួន ជា, ប៉ុល ពត ហ្នឹង។

**ស៖** ចុះ ក៣?

**ឆ៖** ចុះ ក៣ កន្លែងចល័តៗ ចុះឡើងៗ អត់មានប្រចាំទេ។

**ស៖** បាទ អរគុណ។ តើលោកធ្លាប់ស្គាល់មន្ទីរមួយដែលមានឈ្មោះ ក៧ ដែរទេ? ហើយលោកធ្លាប់--

**ឆ៖** ស្គាល់។

**ស៖** លោកធ្លាប់ធ្វើការនៅ ក៧ ហ្នឹង ឬក៏ធ្លាប់ទៅ ក៧ ហ្នឹងដែរទេ?

**ឆ៖** ខ្ញុំធ្លាប់ដើរកាត់ មិនដែលធ្វើការហ្នឹងទេ។ កន្លែងហ្នឹង កន្លែងគេទទួលសម្ភារៈពីទន្លេ កម្លាំងថ្មីៗចូលទៅ ។

[១៤:០៦:០៧]

**ស៖** តើ ក៧ ហ្នឹងមានទីតាំងនៅកន្លែងណាដែរ?

**ឆ៖** ជាប់មាត់ទន្លេ ជាមួយផ្ទះពីរជាន់ហ្នឹង។

**ស៖** តើលោកអាចបញ្ជាក់ជូនអង្គសវនាការបន្ថែមបានទេ ថា ក៧ ហ្នឹងមានមុខនាទី ឬក៏តួនាទីធ្វើអីខ្លះទៅកន្លែងនុ៎ង?

**ឆ៖** អានុ៎ង ជាការទទួលមនុស្សមកពីជនបទហ្នឹង ទទួលហើយបានបំបែកទៅតាមកន្លែងអង្គភាពគេ។ គឺកម្លាំង។

**ស៖** តើលោកដឹងទេ ថាជាទូទៅអ្នកដែល មនុស្សដែលមកស្នាក់នៅទីនេះ ស្នាក់នៅរយៈពេលប៉ុន្មាន បានគេបំបែកទៅអង្គភាព?

**ឆ៖** កន្លែងណា? ក៧? ប្រហែលជួនកាលមួយយប់ពីរយប់ ជួនកាលបើនៅរហូតបានមួយខែក៏មានដែរ អត់ទៀង។

[១៤:០៧:១៣]

**ស៖** បាទអរគុណ។ សូមលោកជួយរៀបរាប់ជូនអង្គសវនាការផងដែរ ថាតើលោកធ្លាប់បាន

ឃើញថ្នាក់ដឹកនាំភូមិភាគ ឬក៏តំបន់ មកទីក្រុងភ្នំពេញ ដើម្បីចូលរួមប្រជុំជាមួយមេដឹកនាំនៅទីក្រុងភ្នំពេញដែរទេ?

**ឆ៖** វាធ្លាប់ឃើញពួកដែលគណៈតំបន់តាមខេត្តទៅហ្នឹង។

**ស៖** លោកអាចរៀបរាប់បន្ថែមបានទេ?

**ឆ៖** អត់ៗស្គាល់ឈ្មោះទេ អត់ចាំ វាភ្លេចហើយ។

**ស៖** តើពួកគាត់មកធ្វើអ្វី មកទីក្រុងភ្នំពេញហ្នឹង?

**ឆ៖** អាចជាគេហៅប្រជុំមើលទៅ អត់ច្បាស់ដែរ ព្រោះនៅខាងក្រៅ។

[១៤:០៨:១៦]

**ស៖** តើលោកធ្លាប់បានទៅការពារនៅកន្លែងប្រជុំនោះដែរទេ?

**ឆ៖** ធ្លាប់ទៅដែរ ចេញក្រៅ។

**ស៖** លោកនៅចាំទេ ថាកិច្ចប្រជុំនោះធ្វើឡើងញឹកញាប់ដែរទេ?

**ឆ៖** ជួនកាលមួយខែម្ដង។

**ស៖** ចុះកិច្ចប្រជុំហ្នឹងគេធ្វើកន្លែងណាដែរ? លោកនៅចាំទេ?

**ឆ៖** អត់សូវចាំដែរ ខ្ញុំនៅក្រៅ ខ្ញុំមិនដឹងដែរ។

**ស៖** បាទ អរគុណ។ តើលោកនៅចាំទេថា មានដឹកនាំនៅទីក្រុងភ្នំពេញណាខ្លះដែលបានចូលរួមក្នុងកិច្ចប្រជុំនេះ?

**ឆ៖** អត់ដឹងដែរ។

[១៤:០៩:២៨]

**ស៖** ចុះលោកបានដឹងទេថា កិច្ចប្រជុំហ្នឹងគេប្រជុំពីអ្វីទៅ?

**ឆ៖** ក៏អត់ដឹងដែរ នៅតែយាម អត់ដឹងការងារគេផង។

**ស៖** បាទ អរគុណ។ ទាក់ទងទៅនឹងអង្គភាពរបស់លោកដែលនៅ យ១០ ហ្នឹង តើលោកធ្លាប់បានចូលរួមប្រជុំស្វ័យទិតៀនអីដែរឬទេ នៅក្នុងអង្គភាព?

**ឆ៖** ធ្លាប់ មួយខែម្ដង។

**ស៖** ការប្រជុំហ្នឹង ប្រជុំនៅកន្លែងណាដែរ?

**ឆ៖** ប្រជុំៗ តាម-- កាលនោះ គ្មានសាលាដូចយើង បែបប្រជុំក្នុងផ្ទះហ្នឹងឯង។ កន្លែងវាល

កណ្ដាលវាលអ៊ីចឹងឯង នឹងរោងអ៊ីចឹងទៅ។

**ស៖** បាទ សូមអរគុណ។ តើលោកនៅចាំទេ ថាតើនរណាជាអ្នកដឹកនាំការប្រជុំហ្នឹង?

**ឆ៖** បើប្រជុំនៅ(ឮមិនច្បាស់) មាន ខាំមី មាន គឺ ពីរនាក់ហ្នឹង។

**ស៖** ចុះអ្នកដែលចូលរួមប្រជុំជាមួយលោក តើនរណាខ្លះ លោកនៅចាំទេ?

**ឆ៖** នែ៎ ចូលរួម មានតែ ខាំមី-- សាំមី ចូលរួម ជួនកាល អាប៉ង់។

**ស៖** តើច្រើនគ្នាទេ?

**ឆ៖** កាលបើថា ប្រជុំធំ បានបួនដប់នាក់ ម្ភៃនាក់។ បើប្រជុំក្រុម បួនប្រាំនាក់ ដប់នាក់ប៉ុណ្ណឹង។

**ស៖** ការប្រជុំទិតៀន ឬស្វ័យទិតៀនអប់រំហ្នឹង គេធ្វើឡើងក្នុងគោលបំណងអីទៅ?

**ឆ៖** គោលបំណង ស្នេហាជាតិ រំដោះវណ្ណៈជិះជាន់។

**ស៖** ក្រៅពីការចូលរួមប្រជុំនេះ តើលោកធ្លាប់បានចូលរួមប្រជុំរៀនសូត្រ វគ្គនយោបាយអ្វីដែរទេ?

**ឆ៖** វគ្គនយោបាយអត់យល់ដែរ ប៉ុន្តែគេថាអប់រំទូទៅ។ តម្រិះល្អ ខ្ញុំយល់ថាអាហ្នឹងហើយនយោបាយ។ អប់រំរៀនឲ្យបានល្អ ធ្វើការឲ្យបានល្អហ្នឹង រួចហើយបានកសាងទិតៀន។ នយោបាយផ្សេង ខ្ញុំអត់ដឹងដែរ អត់យល់ដែរ។

[១៤:១២:២៣]

**ស៖** ការកសាងទិតៀនហ្នឹង យ៉ាងម៉េចខ្លះទៅ សូមលោកជួយរៀបរាប់ជូនអង្គសវនាការផង?

**ឆ៖** កសាងទិតៀន របៀប យើងមានយោបល់ហើយ គឺគេជួយកសាងបន្ថែមពីលើទៅ។ ឲ្យយើងកែប្រែអាក្រក់ កម្ចាត់ចោល ល្អអនុវត្ត ប៉ុណ្ណឹង។

**ស៖** បាទ អរគុណ។ ក្រៅពីការប្រជុំជាស្វ័យទិតៀនហ្នឹង តើលោកមានប្រជុំជា-- ចូលរៀនសូត្រជាវគ្គនយោបាយនៅកន្លែងណាផ្សេងទៀតដែរទេ?

**ឆ៖** មាន-- អត់ទេ មានតែកន្លែងតាម បើទៅរៀន មានតែតាមក្រុម និងតាមអង្គភាពហ្នឹងហើយ អត់មានទៅណាផ្សេងទេ។

**ស៖** បាទ អរគុណ។ តើលោកមានចាំទេ មានកម្មាភិបាល យ១០ ណាខ្លះ ដែលត្រូវបានគេចោទប្រកាន់ថា យ៉ាងនេះ យ៉ាងនោះ ហើយបាត់ខ្លួន?

[១៤:១៣:៣៥]

**ឆ៖** ខ្ញុំអត់ដឹងដែរ អត់ចាំទេ។ ដឹងតែបាត់ពី យ១០ មិនដឹងទៅណា មិនដឹងដែរ។

**លោក សេង ប៊ុនឃាង៖**

បាទ លោកប្រធាន ខ្ញុំអស់សំណួរហើយ ហើយជាបន្តសហការីខ្ញុំនឹងបន្តសំណួរតទៅទៀត។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

ទិវាសួស្តី លោកសាក្សី!

**ស៖** ខ្ញុំសូមចាប់ផ្តើមដោយត្រឡប់ទៅលើសំណួរមួយចំនួន ដែលលោកបានផ្តល់សក្ខីកម្មចំពោះសំណួររបស់សហការីខ្ញុំកាលពីមុននេះ។ នៅពេលដែលគេសួរលោក ថាតើលោកធ្វើអ្វីនៅពេលដែលលោកចូលបដិវត្ត។ លោកបានបញ្ជាក់ថា លោកត្រូវបានគេបញ្ជូនទៅមកៗ នៅការិយាល័យផ្សេងគ្នាៗ តើលោកចង់សំដៅទៅលើមន្ទីរអ្វីទុំង? តើលោកចាំទៀតទេ ថាតើគេបញ្ជូនលោកទៅមកៗ នៅមន្ទីរហ្នឹង តើមន្ទីរអ្វីដែរ នៅក្នុងសម័យ-- នៅពេលធ្វើបដិវត្តន៍នោះ? សូមអរគុណ។

**លោក សួត ទៀង៖**

**ឆ៖** សួរថាម៉េចហ្នឹង? សួរខ្ញុំ? សូមគាត់និយាយម្តងទៀត។

**លោក លឹម ប៊ុនហេង៖**

សូមឲ្យសហព្រះរាជអាជ្ញាសួរម្តងទៀត ស្តាប់សំណួរអត់ច្បាស់។

**លោក សួត ទៀង៖**

ខ្ញុំអត់ដឹងមិញ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកបាននិយាយពីដើមថា ក្រោយពេលដែលលោកចូលបដិវត្ត គេបញ្ជូនលោកទៅមន្ទីរផ្សេងៗជាច្រើន។ តើមន្ទីរផ្សេងៗនោះសំដៅលើមន្ទីរអ្វីដែរ?

[១៤:១៥:៥០]

**លោក សូត្រ ទឿង៖**

**ឆ៖** មន្ទីរហ្នឹងគឺជាមន្ទីរប្រចាំការហ្នឹង។ ខ្ញុំអត់ដឹងដែរ មន្ទីរជាមន្ទីរកន្លែងគេប្រចាំការ ទុកកម្លាំងសម្រាប់ប្រចាំការកន្លែងធ្វើការ។ ធ្វើការអីមិនដឹងដែរណា៎ះ មិនមែនមន្ទីរអីធំដុំទេ មន្ទីរតូចតាចមន្ទីរធំដុំមានតែភ្នំពេញទេ ក្រៅពីហ្នឹងអត់មានធំទេ មន្ទីរសម្រាប់យើងចេញចូលប៉ុណ្ណឹងឯង។

**ស៖** សហការីរបស់ខ្ញុំបានសួរលោក ថាតើលោកមានបានទទួលឯកសារណាមួយពីបក្សដែរឬទេ? នៅពេលដែលខ្ញុំស្តាប់ជាភាសាអង់គ្លេសគេបកប្រែ និយាយអំពីទង់បដិវត្ត ដូច្នេះខ្ញុំចង់សួរលោកឱ្យប្រាកដថា ខ្ញុំស្តាប់ត្រឹមត្រូវដែរឬអត់។ ក្នុងនាមដែលលោកគឺជាសមាជិករបស់យុវកក តើលោកធ្លាប់ទទួលបានទស្សនាវដ្តី ដែលគេហៅថា យុវជនយុវនារីបដិវត្ត ដែរឬទេ?

**ឆ៖** បាទ ទទួលដែរ ប៉ុន្តែទទួលវា យើងមិនចេះអក្សរប៉ុន្មានកាលនោះ គ្រាន់តែទទួលៗ ខ្ញុំមើលអក្សរមិនដាច់ផង។

**ស៖** ខ្ញុំនឹងមិនសួរលោកអំពីខ្លឹមសារនៃឯកសារទាំងអស់នេះទេ ប៉ុន្តែខ្ញុំចង់ឱ្យលោកពិនិត្យមើលទៅលើទស្សនាវដ្តីយុវជនយុវនារីបដិវត្តមួយចំនួន ដើម្បីឱ្យលោកមើលទៅ អាចបញ្ជាក់ថាតើវាដូចអ្វីដែលលោកធ្លាប់បានទទួលនៅក្នុងសម័យនោះដែរឬអត់?

[១៤:៤៧:៤៣]

**លោក ឌេល លីសាក់៖**

លោកប្រធានខ្ញុំមានឯកសារចំនួនពីរ ដែលខ្ញុំចង់ផ្តល់ទៅសាក្សីគឺ E3/146 ដែលមាននៅក្នុងសំណុំរឿងគឺ D175/6.2 ហើយនិងឯកសារ E3/729 ហើយខ្ញុំក៏សូមផ្តល់នូវលេខ ERN-- អ៊ំ លេខ IS គឺ IS11.3។ លោកប្រធានដើម្បីបញ្ជាក់ឱ្យច្បាស់ ហេតុផលដែលខ្ញុំលើកហ្នឹងគឺថាយើងមាន យើងបានកំណត់នូវលេខ E ថ្មីមួយទៀត ដោយសារតែឯកសារមួយចំនួនមិនទាន់មាននៅក្នុង*បញ្ជីឧបសម្ព័ន្ធ* ដែលមានលេខ E1 ជាដើម។ ហេតុដូច្នេះហើយ ទើបខ្ញុំផ្តល់នូវឯកសារ E3 ហើយនិងឯកសារដែលមានលេខ IS នេះ។ ដូច្នេះ ខ្ញុំចង់បង្ហាញដល់សាក្សី នូវទំព័រមួយចំនួននៃឯកសារយុវជនយុវនារីបដិវត្តនេះ ដើម្បីឱ្យគាត់បង្ហាញថាតើគាត់ធ្លាប់ស្គាល់នូវទស្សនាវដ្តីនេះ ដែរឬអត់?

**ឆ៖** ធ្លាប់ស្គាល់ដែរ។

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់បង្ហាញ ហើយនិងបញ្ជូនឯកសារទៅសាក្សី។ រង់ចាំស្តាប់ការជំទាស់តវ៉ាពីមេធាវី

អន្តរជាតិការពារក្តីលោក អៀង សារី ជាមុនសិន។ បាទ សូមអញ្ជើញលោកមេធាវី!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថា ការចោទសួរនេះ វាហាក់ដូចជា មានលក្ខណៈអត្តនោម័តិពេកហើយ ព្រោះថា ដោយសារតែគាត់លើកថា គាត់បានជួបប្រទះ។ ដូច្នេះ ការអនុញ្ញាតការសួរគាត់ឲ្យដឹងថាតើវាយ៉ាងម៉េចដែរ វាមានទម្រង់យ៉ាងម៉េចដែរ? ដូច្នេះវាពិបាកដែលថាសួរគាត់ថា តើមើលទៅដូចយ៉ាងម៉េចដែរ? ដូច្នេះវាពិបាក ដើម្បីឲ្យគាត់ប្រាប់នូវការពិត ទាក់ទងទៅនឹងអ្វីដែលគាត់បានលើកឡើង ហើយនិងអ្វីដែលផ្ទុយទៅនឹងអ្វីដែលគាត់បានលើកឡើងនោះ។ ដូច្នេះ មុននឹងបង្ហាញឯកសារណាមួយចំពោះគាត់ ខ្ញុំគិតថាមុននឹងបង្ហាញឯកសារនោះ គឺថាដោយយើងបង្ហាញឯកសារដើម្បីបង្ហាញពីយថភាព គឺថា-- ប្រសិនបើ-- ដោយសារតែសាក្សីគាត់និយាយថា គាត់មិនអាចអានបានច្បាស់លាស់ទេ គាត់មិនចេះអានឲ្យច្បាស់លាស់នោះទេ។ ដូច្នេះយើងគួរតែសួរគាត់ថា តើឯកសារហ្នឹងវាមើលទៅដូចយ៉ាងម៉េច? ដើម្បីឲ្យគាត់បង្ហាញនូវអ្វីដែលគាត់ចងចាំ។ ប្រសិនបើគាត់មិនចងចាំទេ-- ដូច្នេះ ប្រសិនបើខាងព្រះរាជអាជ្ញាចង់បង្ហាញឯកសារណាមួយ ដើម្បីរម្លឹកនូវការចងចាំរបស់សាក្សីអាហ្នឹងគឺគាត់អាចធ្វើបាន។ ប៉ុន្តែដំបូងបំផុត គឺយើងត្រូវចោទសួរសាក្សីដើម្បីឲ្យគាត់រម្លឹកថា តើគាត់ពិតជាបានចងចាំដែរឬអត់នោះ? សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

[១៤:២០:៥៥]

**លោក ឌេល លីសាក់៖**

លោកប្រធាន លោក កាណាវាស អាចចោទសួរសំណួរបែបនេះបាន ប៉ុន្តែសាក្សី គាត់និយាយថាគាត់បានធ្លាប់ឃើញទស្សនាវដ្តីយុវជនយុវនារីបដិវត្ត។ ដូច្នេះហើយខ្ញុំគ្រាន់តែចង់បង្ហាញឲ្យសាក្សីគាត់បានឃើញដើម្បីឲ្យគាត់ដឹងថា តើគាត់ធ្លាប់អានឬអត់? ចំណែកលោក កាណាវាស ប្រសិនបើគាត់ចង់ធ្វើការសួរដេញដោល គាត់អាចធ្វើនៅពេលដែលគាត់មានពេលរបស់គាត់។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន ប្រសិនបើយើងបង្ហាញឯកសារដែលមានរូបភាព ដែលមានស្លាកសញ្ញា ហើយសួរថាឯកសារហ្នឹងធ្លាប់ឃើញអត់ហ្នឹង? អាហ្នឹងវាហាក់ដូចជាការស្នើថា បង្ហាញថាឲ្យគាត់ឃើញហើយ ដូច្នេះហើយវាបង្ហាញនូវគោលដៅរបស់វា។ នេះជាការណែនាំ។

[១៤:២១:៤៨]

ដូចជាគាត់បាននិយាយថា គាត់ធ្លាប់បានឃើញ។ ដល់ពេលនោះយើងអាចសួរគាត់ថា តើគាត់ឃើញហ្នឹងជាសៀវភៅ ឬក៏ជាៗក្រដាស? តើសៀវភៅនោះវាស្តើង ឬក៏ក្រាស់? វាមានពណ៌អី? ថាតើនៅទំព័រដើមនោះ វាមានរូបភាពអី? បើសិនជាគាត់ចងចាំ អាហ្នឹងជារឿងល្អ ហើយយើងបន្តទៅមុខទៀត។ ប៉ុន្តែប្រសិនបើយើងបង្ហាញគាត់នូវគម្របដែលមានចំណងជើងដែលមានរូបភាពអីហ្នឹង គឺវាជាការបង្ហាញ ជាការណែនាំដល់សាក្សី អាហ្នឹងមិនមែនជាភស្តុតាងទេ អាហ្នឹងឯងគឺជាហេតុផលដែលខ្ញុំធ្វើការជំទាស់។ សូមអរគុណ។

[១៤:២២:២៦]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:២៣:១៥]

**ប្រធានអង្គជំនុំ៖**

សេចក្តីជំទាស់របស់មេធាវីអន្តរជាតិការពារក្តីលោក អៀង សារី ពុំមានប្រសិទ្ធភាព។ អង្គជំនុំជម្រះអនុញ្ញាតឲ្យតំណាងសហព្រះរាជអាជ្ញាប្រគល់ឯកសារជូនទៅសាក្សីពិនិត្យតាមរយៈមន្ត្រីរដ្ឋបាលតុលាការ ហើយនិងដាក់បង្ហាញឯកសារនៅលើអេក្រង់កុំព្យូទ័រ។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ដូច្នេះដំបូងយើងផ្តល់ឯកសារ E3/146 ហើយយើងបង្ហាញនូវពីរបីទំព័រនៃឯកសារនេះនៅលើអេក្រង់ គឺយើងបង្ហាញនូវទំព័រដើម គឺគម្របនៃទស្សនាវដ្តីនេះនៅលើអេក្រង់។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី សូមលោកពិនិត្យមើលទៅលើឯកសារជាពិសេសទៅមើលទំព័រ ទៅមើលគម្របឯកសារនេះ ថាតើលោកអាចចាំបានដែរឬទេ ថាតើឯកសារហ្នឹងដូចឯកសារដែលលោកបាន

ទទួលនៅក្នុងរយៈពេលដែលលោកនៅក្នុង-- ជាសមាជិកយុវកកហ្នឹង តើវាដូចគ្នាដែរឬទេ ឯកសារហ្នឹង និងឯកសារដែលលោកបានទទួលនៅពេលសម័យនោះ? សូមអរគុណ។

[១៤:២៤:៥៣]

**លោក សួត្រ ទៀង៖**

**ឆ៖** ដូចគ្នាអាពណ៌ពងមាន់ និងពណ៌ស ក្រដាសរ៉ាម។

**ស៖** តើទង់ជាតិដែលនៅគម្របហ្នឹងវាមានពណ៌អីដែរ? តើលោកចាំទេ វាពណ៌អីដែរ?

**ឆ៖** ពណ៌ក្រហមមានក្បូរស្រូវ។

**លោក ឌេល លីសាក់៖**

លោកប្រធានខ្ញុំចង់ប្រគល់ជូននូវឯកសារទីពីរទៅសាក្សី ដែលមានលេខ E3/729 ហើយនៅក្នុងសំណុំរឿងគឺ IS11.3។

[១៤:២៦:១៣]

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីតំណាងសហព្រះរាជអាជ្ញាជូនសាក្សីពិនិត្យ ហើយនិងអនុញ្ញាតឲ្យបង្ហាញឯកសារនៅលើអេក្រង់កុំព្យូទ័រ!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សំណួររបស់ខ្ញុំគឺដូចគ្នានឹងសំណួរមុនដែរ ថាតើវាជាទស្សនាវដ្តី យុវជនយុវនារីបដិវត្តដែលលោកបាននិយាយថាលោកបានឃើញនៅសម័យនោះ តើវាដូចគ្នាដែរឬទេ?

**លោក សួត្រ ទៀង៖**

**ឆ៖** ឈប់មិនទាន់ច្បាស់ សួរម្តងទៀតមើល។ ថាម្តងទៀត អត់ច្បាស់ទេ សួរម្តងទៀតមើល។ អត់ច្បាស់ទេ និយាយម្តងទៀតមើល!

**ប្រធានអង្គជំនុំ៖**

លោក១តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ សូមតាំងសំណួរចុងក្រោយអម្បាញ់មិញនេះសាជាថ្មីម្តងទៀត ពីព្រោះសាក្សីស្តាប់មិនច្បាស់ទេ។ គាត់យល់មិនច្បាស់អំពីសំណួរដែលលោកបានសួរគាត់។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** សំណួររបស់ខ្ញុំគឺថា ឯកសារនេះគឺជាឯកសារមួយដែលៗចង់សួរលោកថា តើលោកចាំទេថា តើឯកសារហ្នឹងវាដូចជាឯកសារ យុវជនយុវនារីបដិវត្ត ដែលលោកឃើញកាលពីសម័យមុន។ តើវាដូចគ្នាដែរឬទេ?

[១៤:២៧:៤២]

**លោក សួត្រ ទៀង៖**

**ឆ៖** ន៎ែ អាឆ្នាំនោះឆ្នាំឥឡូវហ្នឹងអ្អី? និយាយសម័យមុន? ខ្ញុំអត់ទាន់ច្បាស់កន្លែងហ្នឹង។ បើឆ្លើយខ្លាចខុស។ មិនទាន់ច្បាស់ទេ ខ្ញុំយល់អត់ទាន់បានទេ និយាយម្តងទៀត ព្រោះសម័យនោះ សម័យនេះ -- ខ្ញុំឆ្លើយសម័យនេះ ឬក៏សម័យពេលហ្នឹង? ចង់ប្រៀបធៀបសម័យឥឡូវ និងសម័យនោះ? មិនអ៊ីចឹង ចង់ដឹងអ៊ីចឹងណា៎។ ប្រាប់គាត់បន្តិចមើល៍ ឲ្យគាត់និយាយម្តងទៀត។ ឲ្យច្បាស់អាកន្លែងអាពេលហ្នឹង។

**ប្រធានអង្គជំនុំ៖**

តំណាងសហព្រះរាជអាជ្ញាតាំងសំណួរគាត់ ចំពោះគាត់ម្តងទៀត។ បង្ហាញពីពេលវេលាផងដើម្បីឲ្យបានច្បាស់លាស់។ ពេលវេលានៃឯកសារដែលសួរគាត់ហ្នឹង ឯកសារហ្នឹងវាមាននៅពេលណាដែលគាត់បានដឹង បានឮ បានឃើញៗនុំងណេះ? ដូចជាវិលវល់នឹងបញ្ហាការកំណត់ពេលវេលានឹងការតាំងសំណួរ។ សូមឲ្យបញ្ជាក់នូវពេលវេលាហ្នឹងឲ្យបានច្បាស់លាស់ផង ដើម្បីរំឭកការចងចាំ ហើយនិងការឆ្លើយហ្នឹងចំទៅនឹងសំណួរដែលបានសួរ។

[១៤:២៩:០២]

**លោក ខេល លីសាក់៖**

អរគុណលោកប្រធាន។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** ឯកសារទីពីរដែលខ្ញុំបានផ្តល់ជូនលោកហ្នឹង គឺមានចំណង-- គឺនៅ-- គឺលេខ១០ ខែតុលា ឆ្នាំ៧៥ ដែលមានចំណងជើងថា "យុវជនយុវនារីបដិវត្ត"។ សំណួររបស់ខ្ញុំគឺថានៅឆ្នាំ៧៥ហ្នឹង គឺនៅពេលដែលលោកបានទទួលទស្សនាវដ្តីយុវជនយុវនារីបដិវត្ត តើវាជាពេលនុំងឬ?

**លោក សួត្រ ទៀង៖**

**ឆ៖** វា-- ហ៊ឺ! មិនដឹងឆ្លើយម៉េច? ខ្ញុំមិនចេះឆ្លើយ វាដូចមិនសូវច្បាស់។ ដូចគ្នា។

[១៤:៣០:០០]

**សៈ** ឥឡូវខ្ញុំសួរលោកដោយសំណួរសាមញ្ញ។

ថាតើឆ្នាំណាដែលលោកបានទទួលសៀវភៅយុវជនយុវនារីបដិវត្ត ថាតើនៅឆ្នាំណាដែលលោកបានទទួលសៀវភៅហ្នឹង?

**ផះ** នែ៎ ៧៤។ គេបង្កើតតាំងពី៧៤មក ត្រឹមត្រូវ ៧៤។

**សៈ** តើលោកនៅតែបានទទួលទស្សនាវដ្តីយុវជននិងយុវនារីបដិវត្ត តាំងពីឆ្នាំ១៩៧៥ អ៊ំ! ពី៧៤ រហូតមក៧៥ រហូតតទៅទៀតឬយ៉ាងដូចម្តេច?

**ផះ** ត្រឹម៧៥, ៧៦ អស់ហើយ។

**សៈ** ដូច្នេះលោកបានបញ្ជាក់ថា ឯកសារហ្នឹង គឺថាបានទទួលដោយសារលោកជាសមាជិកនៃសម្ព័ន្ធយុវកក។ តើក្របនេះដែលលោកបានឃើញនេះ ដូចគ្នាហ្នឹងក្របទស្សនាវដ្តីយុវជន និងយុវនារីបដិវត្តដែលលោកបានទទួលចាប់ពីឆ្នាំ១៩៧៤ ដល់៧៥ ដែលឬទេ វាដូចគ្នាដែរទេ?

**ផះ** ដូច អាខ្លះពណ៌លឿង អាខ្លះពណ៌ក្រហម។ ចាំដែរ វាមានពីរពណ៌។

**សៈ** តើលោកចាំចំនួនទង់ជាតិនៅទស្សនាវដ្តីហ្នឹងទេ ដែលលោកបានទទួលនៅក្នុងឆ្នាំ១៩៧៤ ហើយនិងឆ្នាំ១៩៧៥? តើទង់នៅលើក្របហ្នឹងមានចំនួនប៉ុន្មាន?

**ផះ** អត់ចាំដែរអាហ្នឹង អត់បានចាំ។

**សៈ** លោកបាននិយាយថា លោកមិនអាចអានឯកសារនេះបានទេ ខ្លួនឯងនោះ។ តើមានអ្នកណាម្នាក់ផ្តល់ការណែនាំអំពីអត្ថន័យ ឬក៏អំពីន័យនៃឯកសារនេះដែរឬទេ?

**ផះ** ប្រធាន ពេលប្រជុំហ្នឹងគេណែនាំ គេប្រាប់។ ជួនកាល ខាំ មី ជួនកាល ប៉ង់។ អានទៅគេស្តាប់។ ព្រោះកាលណោះអត់ចេះអក្សរ។

[១៤:៣៣:១៦]

**សៈ** តើ ប៉ង់ គាត់មានតួនាទីជាអ្វី?

**ផះ** គាត់គ្រប់គ្រងរួម មួយ ក១។ មន្ទីរអង្គការ។

**សៈ** ថាតើការប្រជុំទាំងអស់នោះប្រជុំនៅកន្លែងណាដែល ប៉ង់ ជាអ្នកបង្រៀនលោកអំពីខ្លឹមសារយុវជន និងយុវនារីបដិវត្តនេះ ប្រជុំនៅកន្លែងណា?

**ផះ** មាននៅ ក៧ មួយកន្លែង ហើយហ្នឹងមាននៅ យ១០។ ពីរកន្លែង។

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំក៏ចង់សួរលោក សំណួរមួយចំនួនទៅលោកដែរ អំពីការងាររបស់លោកជាយោធា នៅក្នុងរយៈកាលមុនឆ្នាំ១៩៧៥ ហើយខ្ញុំចង់យោងទៅរកឯកសារអំពីចម្លើយរបស់លោកនៅក្នុង E3/423 នៅក្នុងសំណួរ៥១ ចម្លើយ៥១ ។

**លោក ខេល លីសាក់៖**

លោកប្រធានខ្ញុំសូមអនុញ្ញាតបង្ហាញឯកសារនេះនៅលើអេក្រង់ ដោយសារលោកសាក្សីនេះគាត់មានឯកសារ លើឯកសារនោះស្រាប់ហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

មន្ត្រីបុគ្គលិកជំនួយការ សូមបង្ហាញឯកសារនៅលើអេក្រង់កុំព្យូទ័រ។

[១៤:៣៥:០០]

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោក សូត្រ ទើង នៅក្នុងចម្លើយរបស់លោកដែលបានឆ្លើយទៅសហចៅក្រមស៊ើបអង្កេត លោកបានចង្អុលបង្ហាញថា គេបានបង្រៀនលោកឲ្យធ្វើជាអង្គរក្ស ហើយខ្ញុំបាន មានតែបង្ហាត់ទាហាន ពេលវ៉ៃជាមួយទាហាន លន់ នល់។ តើលោកចង់និយាយដូចម្តេច នៅពេលដែលលោកជាទាហាន ពេលវ៉ៃជាមួយ លន់ នល់។ តើលោកបានចូលរួមក្នុងការច្បាំងនោះដែរឬទេ? ឬក៏ការបង្រៀនហ្នឹង គេបង្រៀនឲ្យច្បាំងទេ?

**លោក សូត្រ ទើង៖**

**ឆ៖** កាលណោះអត់បានរៀនទេ បើថាទ័ពពេលដែលគេច្បាំង គេរៀន ប៉ុន្តែខ្ញុំអត់បានរៀនទេ បានតែតាមការពារប៉ុណ្ណឹងឯង។

**ស៖** លោក សូមលោកពិនិត្យនូវសំណួរបន្ទាប់ទៅទៀត សំណួរ និងចម្លើយ គឺនៅសំណួរ និងចម្លើយ៥២។ សំណួរនោះគេសួរថា៖ នៅក្នុងការបង្ហាត់ជា នៅពេលបង្ហាត់ទាហាននោះ អ្នកណាជាអ្នកបង្ហាត់ឈ្មោះអ្វីដែរ? ពេលនោះលោកឆ្លើយថា៖ អ្នកបង្ហាត់ទាហាននោះឈ្មោះ ផែន ជាអ្នកមកពីហាណូយ។ សូមលោកជម្រាបតុលាការបានទេ ថាតើការបង្ហាត់នោះ គេបង្ហាត់អ្វី? តើលោកទទួលការបង្ហាត់ពី ផែន ហ្នឹង មេរៀនអីនៅកាលណោះ?

[១៤:៣៧:២៧]

**ឆ៖** បាទ រឿងបង្ហាត់ ប៉ុន្តែខ្ញុំមិនបានទៅហាត់ទេ។ ប៉ុន្តែក្បួនដែលហាត់ហ្នឹង គឺហាត់រៀនលូន រៀនបាញ់ រៀនគ្រាប់ផ្លោងប៉ុណ្ណឹង។ តាផែន ហ្នឹងគាត់មកពីហាណូយ។ គាត់មកបង្ហាត់កងទ័ពនេះ បង្ហាត់បាញ់កាំភ្លើង ហើយលូន ហើយរត់។ តែប៉ុណ្ណឹងឯង។

[១៤:៣៧:៥៦]

**ស៖** តើនៅពេលដែលលោកចូលរួមវគ្គបង្ហាត់ហ្នឹង ចូលរួមនៅក្នុងខែឆ្នាំណាដែរ?

**ឆ៖** ខ្ញុំអត់បានចូលទេ មិនបានចូលទេ មិនបានរៀនទេ។

**ស៖** ថាតើវគ្គបង្ហាត់ហ្នឹង បង្ហាត់នៅក្នុងខែឆ្នាំណាដែរតាមដែលលោកចាំ?

**ឆ៖** តាមខ្ញុំចាំ ច្រើនខែប្រាំង។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំរង់ចាំការណែនាំពីតុលាការ បើសិនជាលោកប្រធានចង់ឈប់សម្រាកនៅពេលណា សូមមេត្តាប្រាប់ខ្ញុំផងបាទ។

[១៤:៣៨:៥៨]

**ប្រធានអង្គជំនុំ៖**

បាទ បំណងចាកិលបន្តិចទៀតដែរ ប៉ុន្តែលោកសួរហើយ ហើយពេលវេលាសមល្មមនឹងសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី ហើយសូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ ហើយមន្ត្រីរដ្ឋបាលតុលាការ សមស្របសម្រួលផ្តល់កន្លែងសម្រាកសម្រាប់សាក្សី ហើយនិងមេធាវីការពារសាក្សី ហើយនិងឲ្យអញ្ជើញគាត់មកកន្លែងផ្តល់សក្ខីកម្មនេះវិញនៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៩ នាទី ដល់ម៉ោង ១៥:០១ នាទី)*

[១៥:០១:១៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការ។

សូមអញ្ជើញ លោកស្រីមេធាវីតំណាង-- នាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន សូមអរ-- ខ្ញុំទើបតែអានសំបុត្រមួយរបស់អ្នកស្រី សូហ្សាន ឡែម ហើយដែលបានបញ្ជាក់ថា ទាក់ទងទៅនឹងដើមបណ្ដឹងរដ្ឋប្បវេណី ហើយនិងសហព្រះរាជអាជ្ញាថា យើងមានរយៈពេលមួយថ្ងៃកន្លះ។ ហើយយើងយើងត្រូវចែករយៈពេលមួយថ្ងៃកន្លះនេះរវាងយើងទាំងពីរក្រុមហ្នឹង។ ដោយសារយើងក្រុមពីរនេះ ដាច់ពីគ្នា ហើយយើងមិនត្រូវចែកពេលវេលាជាមួយនឹងគ្នានោះទេ។ ក៏ប៉ុន្តែខ្ញុំគិតថា នៅថ្ងៃអនាគតគួរតែប្រាប់យើងឲ្យបានជាមុនឲ្យបានយូរបន្តិច គឺថាមុននឹងពេលចោទសំណួរនេះ ពីព្រោះថាយើងមានការលំបាក ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការសម្របសម្រួល បែងចែកពេលវេលា។ ហើយពេលក្រោយមកនោះ យើងត្រូវតែសម្របសម្រួលខ្លួនរយៈទាក់ទងនឹងរយៈពេលពេលវេលានេះ។

[១៥:០២:៤១]

យើងខ្ញុំទាំងអស់គ្នាបានសុំរយៈពេលបីម៉ោង ហើយយើងរហូតដល់ពេលនេះយើងមិនទាន់ដឹងថាយើងទទួលពេលវេលាប៉ុន្មាននោះទេ។ អ៊ីចឹងដោយគោរព គឺថាសូមឲ្យអង្គជំនុំជម្រះជម្រាបប្រាប់មកយើងឲ្យបានមុន។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិបន្តការតាំងសំណួរ!

**លោក ឌេល លីសាក់៖**

អរគុណលោកប្រធាន។

[១៥:០៣:៣៦]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សីខ្ញុំចង់សួរលោកនូវសំណួរមួយចំនួន អំពីតួនាទីរបស់លោកក្នុងនាមជានីរសាររបស់ ក៏ដូចជាអង្គរក្សរបស់លោក នួន ជា។ តើលោកអាចពណ៌នាបានទេអំពីតួនាទី អំពីការងាររបស់លោកក្នុងនាមជានីរសារ និងការអង្គរក្សការពារលោក នួន ជា? តើលោកអាចរៀបរាប់ពីតួនាទីរបស់

លោកបានដែរឬទេ?

**លោក សូត្រ ទឿង៖**

**ឆ៖** បាទ ភារកិច្ចដែលខ្ញុំការពារហ្នឹងគ្មានស្អីឲ្យវែងឆ្ងាយទេ គ្រាន់តែថាយាមជុំវិញ ហើយនិងជូនដំណើរតាមផ្លូវតែប៉ុណ្ណឹងឯង ការពារជុំវិញអី អត់មានអីវែងឆ្ងាយទេ។

[១៥:០៤:៣៧]

**ស៖** តើលោកធ្លាប់ហែហមលោក នួន ជា នៅពេលដែលគាត់ធ្វើដំណើរទៅខេត្តដែរឬទេ?

**ឆ៖** ទៅដែរ។

**ស៖** តើលោក នួន ជា ធ្វើដំណើរទៅខេត្តញឹកញាប់ប៉ុនណាដែរ?

**ឆ៖** ទៅញឹកញាប់ដែរ ពីរបីខែម្តង។

**ស៖** តើគាត់បន្តធ្វើដំណើរទៅខេត្តហ្នឹងរហូត បានន័យថាក្នុងពេលដែលលោកធ្វើការជាមួយគាត់ហ្នឹង គាត់នៅតែធ្វើដំណើរទៅខេត្តជារៀងរហូត ឬមួយក៏យ៉ាងដែរ?

**ឆ៖** វាអត់រៀងរហូតទេ ជួនកាលយូរម្តង។

**ស៖** តើគាត់ធ្វើដំណើរទៅគ្រប់ខេត្ត គ្រប់ក្រុងនៅទូទាំងប្រទេសដែរ ឬក៏អត់ទេ?

**ឆ៖** ខាងបាត់ដំបង បាត់ដំបងហើយនិង តាកែវ ហើយនិងកំពង់ឆ្នាំង, កំពង់ស្ពឺ, បូព៌ា ប៉ុណ្ណឹង។

**ស៖** តើក្នុងដំណើរទស្សនកិច្ចទៅតាមខេត្តហ្នឹង តើមានមនុស្សប្រហែលប៉ុន្មាននាក់ដែលទៅជាមួយលោក ទៅជាមួយ នួន ជា ហ្នឹង? តើមានមនុស្សប៉ុន្មាននាក់ដែរ?

[១៥:០៦:២៦]

**ឆ៖** ជួនកាល ១០នាក់ ជួនកាលជាង១០នាក់ក៏មានដែរ។

**ស៖** តើលោកជាអ្នកបើកបរ ឬក៏មានអ្នកផ្សេងជាអ្នកបើកបរក្នុងដំណើរនេះ?

**ឆ៖** គេអ្នកផ្សេង។

**ស៖** តើលោកជិះឡានជាមួយលោក នួន ជា ដែរឬទេ នៅពេលធ្វើដំណើរ?

**ឆ៖** ជិះឡានកងការពារ។

**ស៖** តើមានអ្នកណាផ្សេងដែរ ជិះឡានជាមួយ នួន ជា ក្រៅពីអ្នកបើកបរនោះ?

**ឆ៖** ឃើញគាត់ជិះម្នាក់ឯង ហើយនិងតែកុងឡាន ហើយនិរសារផ្ទាល់គាត់។

**ស៖** ថាតើអ្នកបើកបរឲ្យ នួន ជា ហ្នឹងជានរណាដែរ នៅលោកធ្វើដំណើរនោះ?

**ឆ៖** មានឈ្មោះ យ៉ាង ឈ្មោះ សុត តែពីរហ្នឹងឯង ឈ្មោះ ធុង តែបី ធ្វើការផ្លាស់ប្តូរគ្នា។

**ស៖** តើលោកទៅជាមួយ នួន ជា គ្រប់ពេលនៅពេលដែល នួន ជា ទៅខេត្ត ឬមួយក៏អត់គ្រប់ពេលទេ?

**ឆ៖** អត់សូវគ្រប់ដែរ ជួនកាលរវល់នៅយាមក៏មាន ជួនកាលគេទៅក៏មាន ដូរគ្នា។

[១៥:០៨:៤៦]

**ស៖** តើលោកអាចជម្រាបបានទេ នៅពេលដែល នួន ជា ធ្វើដំណើរទៅខេត្តហ្នឹង គាត់ធ្វើអីខ្លះ? គាត់ទៅធ្វើអី?

**ឆ៖** ទៅអប់រំ ទៅបើកអង្គប្រជុំ។

**ស៖** តើគាត់ទៅធ្វើប្រធានអង្គប្រជុំហ្នឹង អង្គប្រជុំរបៀបណាដែរ? អង្គប្រជុំបែបណាដែរ?

**ឆ៖** អង្គប្រជុំរបៀបហៅថា ទៅរៀនសូត្រ ដែលប្រធានសហករណ៍គេចេះដឹង ដឹកនាំធ្វើស្រែ ធ្វើភ្លឺប៉ុណ្ណឹងឯង ដាំស្រូវ ស្ទូងស្រូវ។

[១៥:១០:០៩]

**ស៖** តើ នួន ជា គាត់មានជួបជាមួយប្រធានភូមិភាគ ប្រធានតំបន់ដែរទេ នៅពេលដែលគាត់ចុះខេត្តនោះ?

**ឆ៖** ដែលជួបដែរ។

**ស៖** ថាតើប្រធានតំបន់ភូមិភាគណា ដែលលោកចាំថា បានមកជួបជាមួយ នួន ជា នោះ?

**ឆ៖** តាមខ្ញុំចាំ មានន៉ៃ សោ ភឹម, តាញឹម, តាប៉ាល់, តាធុច ហើយណាទៀតទេ, កឺ, តាម៉ុក ដែលថាជួប។

**ស៖** នៅពេលដែល នួន ជា ទៅខេត្តហ្នឹង តើ នួន ជា គាត់ធ្លាប់ទៅមើលទំនប់ ប្រឡាយ ឬក៏ទៅមើលការដ្ឋានដែរឬទេ?

**ឆ៖** ទៅញឹកណាស់ ញឹកញាប់។

**ស៖** តើលោកចាំដែរឬទេ ថាតើ នួន ជា ទៅទស្សនកិច្ចទំនប់ប្រឡាយហ្នឹង តើទំនប់ប្រឡាយនៅតំបន់ណាដែរ?

[១៥:១១:៤៣]

**ឆ៖** តាមខ្ញុំចាំ មកវាមួយ ហើយទំនប់នៅខាង-- មិនសូវចាំដែរ នៅខាងកោះកុង ក៏គាត់ទៅ

មើល នៅខាងពោធិ៍សាត់ ក៏ទៅមើល។ មើលពីរបីកន្លែងហ្នឹង បូព៌ាទៅមើល មករហូតហ្នឹង។

**ស៖** ទំនប់១មករា ដែលលោកបាននិយាយហ្នឹង តើតំនប់១មករា ហ្នឹង នៅកន្លែងណាដែរ? មានទីតាំងនៅកន្លែងណា?

**ឆ៖** ១មករា ដូចនៅខាងកំពង់ឆ្នាំង ខ្ញុំមិនសូវចាំដែរណ៎ា។

**ស៖** តើលោកចាំដែរឬទេ នៅពេលដែលលោក នួន ជា ទៅមើលទំនប់ហ្នឹង គឺគាត់ធ្លាប់ទៅមើលនៅទំនប់ជីនិត នៅចន្លោះខេត្តកំពង់ឆ្នាំង កំពង់ធំ តើលោកចាំទេ គាត់ធ្លាប់ទៅទំនប់ជីនិតហ្នឹងដែរទេ?

**ឆ៖** ធ្លាប់ទៅដែរ។

**ស៖** តើលោកចាំដែរទេ ថាគាត់នៅកន្លែងនុ៎ង ទៅជីនិតហ្នឹង ប៉ុន្មានដងដែរ?

**ឆ៖** មិនសូវចាំដែរ ជួនកាលវា ខ្ញុំទៅទាន់បានតែពីរដងបីដងដែរ។

**ស៖** តើ នួន ជា គាត់ធ្វើដែរ នៅពេលដែលគាត់ទៅមើលនៅទំនប់ប្រឡាយទាំងអស់នោះ?

**ឆ៖** ទៅពិនិត្យអារឿងទំនប់ល្អមិនល្អ ស្រូវល្អមិនល្អ ទឹកហូរមិនហូរ គាត់ទៅពិនិត្យហ្នឹងឯង។ ហើយបើមិនល្អ គាត់អប់រំប្រាប់អ្នកប្រធានសហករណ៍នោះ ឲ្យមកកែកុន។

[១៥:១៣:៥២]

**ស៖** តើ នួន ជា ធ្លាប់ជួបជាមួយនឹងប្រធាន ឬក៏មេការដ្ឋានកសាងទំនប់ប្រឡាយហ្នឹង ដែរឬទេ?

**ឆ៖** ឧស្សាហ៍ជួបដែរ ជួបជាប់។

**ស៖** នៅពេលដែលលោកធ្វើដំណើរជាមួយ នួន ជា ទៅតាមខេត្តហ្នឹង តើនួន ជា ធ្លាប់ទៅចូលវត្តដែរឬទេ?

**ឆ៖** អត់ដែលចូលទេវត្ត អត់មានលោកផង។ អត់លោកសង្ឃទេ។

**ស៖** តើនៅពេលដែល នួន ជា នៅភ្នំពេញហ្នឹង គាត់ធ្លាប់ដែលទៅវត្តទេ?

**ឆ៖** ទៅវត្ត បើអត់មានលោក ទៅធ្វើអី។

**ស៖** តើលោកធ្លាប់ឮ នួន ជា និយាយពីពុទ្ធសាសនាទេ?

**ឆ៖** អត់ដែលឮទេ។

[១៥:១៥:១៤]

**ស៖** នៅពេលដែលលោកធ្វើការជាមួយគាត់នោះ តើលោកធ្លាប់ឃើញ នួន ជា ចូលរួមពិធីបុណ្យបែបពុទ្ធសាសនាទេ?

**ឆ៖** អត់ដែលឃើញ។

**ស៖** ខ្ញុំនឹងសួរសំណួរទាក់ទងទៅនឹងមេតំបន់ ឬក៏មេភូមិភាគ ដែល នួន ជា បានជួប តើ នួន ជា-- តើលោកធ្លាប់ធ្វើដំណើរជាមួយ នួន ជា ទៅតាកែវទេ?

**ឆ៖** ធ្លាប់ទៅដែរ ទៅម្តង។

[១៥:១៦:១១]

**ស៖** តើនៅពេលដែល នួន ជា ទៅតាកែវហ្នឹង នួន ជា ទៅជួបអ្នកណាដែរ?

**ឆ៖** តាម៉ុក។

**ស៖** តើ នួន ជា ជួប តាម៉ុក ហ្នឹង ជួបនៅឯណា? ជួបនៅសាលាខេត្ត ឬក៏ជួបនៅកន្លែងណាមួយផ្សេងទៀត?

**ឆ៖** ច្រើនតែជួបផ្ទះគាត់តែម្តង។

**ស៖** តើលោកចាំទេផ្ទះតាម៉ុកហ្នឹងនៅកន្លែងណាដែរ?

**ឆ៖** ចាំដែរ ដូចហួសក្រុងទៅខាងឆ្វេង។

**ប្រធានអង្គជំនុំ៖**

សាក្សីចាំបង្អង់បន្តិចសឹមឆ្លើយ ចាំបង្អង់បន្តិចទៅសឹមឆ្លើយ តែកាលណាឆ្លើយភ្លាមៗទៅអា មីក្រូហ្នឹងមិនទាន់បើក ក្បាលមីក្រូលោកនិយាយទៅស្តាប់តែម្នាក់ឯង អត់បានចូលទៅប្រព័ន្ធបកប្រែភាសាទេ។ អ៊ីចឹងហើយអាចអ្នកដែលចូលរួមទាំងអស់ហ្នឹងមិនយល់បាន។ បាទ សូមអញ្ជើញបន្ត!

**លោក ឌេល លីសាក់៖**

អរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** នៅពេល នួន ជា ទៅជួប តាម៉ុក តើពួកគេជួបតែពីរនាក់ទេ ឬក៏មានអ្នកដទៃទៀតចូលរួមក្នុងការប្រជុំហ្នឹងដែរ?

**ឆ៖** ខ្ញុំទៅហ្នឹង អត់បានដឹង ព្រោះខ្ញុំវានៅខាងក្រៅ។

[១៥:១៨:១៦]

**ស៖** តើ នួន ជា ធ្លាប់និយាយជាមួយលោកអំពីរឿងតាម៉ុកទេ?

**ឆ៖** អត់ដែលឮនិយាយទេ អត់ដឹង។

**ស៖** តើលោកធ្លាប់ឃើញតាម៉ុកមកភ្នំពេញ ក្រោយពេលប្រជុំជាមួយ នួន ជា ឬមួយក៏ក្រោយប្រជុំជាមួយមេដឹកនាំផ្សេងៗនៅភ្នំពេញទេ?

**ឆ៖** ធ្លាប់មកជួបតា នួន ជា មករៀន។

**ស៖** តើលោកឃើញ តាម៉ុក នៅភ្នំពេញហ្នឹងញឹកញាប់បែបណាដែរ?

**ឆ៖** មិនសូវញាប់ដែរ ប្រហែលមួយខែពីរខែមកម្ដង។

**ស៖** តើលោកឃើញតាម៉ុកនៅភ្នំពេញហ្នឹងនៅតំបន់នៅកន្លែងណាដែរ?

**ឆ៖** នៅក-១។

**ស៖** លោកបាននិយាយថា នួន ជា ទៅភូមិភាគបូព៌ា ថាតើនៅពេលដែលគាត់ទៅភូមិភាគបូព៌ាហ្នឹងគាត់ទៅជួបអ្នកណាដែរ?

**ឆ៖** ជួបតា សោ ភឹម។

**ស៖** តើ នួន ជា ទៅភូមិភាគបូព៌ាហ្នឹងញឹកញាប់បែបណាដែរ?

**ឆ៖** មិនសូវញឹកដែរ ជួនកាលពីរខែបីខែទៅម្ដង។

**ស៖** តើនៅពេលដែល នួន ជា ទៅបូព៌ាហ្នឹង គាត់ជួប សោ ភឹម នៅកន្លែងណាដែរ?

**ឆ៖** ផ្ទះគាត់។

**ស៖** តើលោកចាំទេ ថាផ្ទះ សោ ភឹម ហ្នឹងនៅកន្លែងណាដែរ?

**ឆ៖** អត់ចាំដែរ អត់ចាំៗ។

**ស៖** នៅពេលដែល នួន ជា ទៅជួបប្រជុំជាមួយ តាម៉ុក ឬក៏ជួយ សោ ភឹម តើគេជួបប្រជុំហ្នឹងប្រហែលប៉ុន្មាន មានរយៈពេលប៉ុន្មានដែរ? បានន័យថាការប្រជុំហ្នឹងវាមានរយៈពេលប៉ុន្មានម៉ោង ប៉ុន្មានថ្ងៃអីដែរ?

[១៥:២១:២៥]

**ឆ៖** ជួនកាលមួយថ្ងៃ ជួនកាលពីរថ្ងៃ ប៉ុណ្ណឹង។

**ស៖** នៅពេលដែល នួន ជា ទៅប្រជុំហ្នឹង តើលោកធ្លាប់ឃើញ នួន ជា មានយកឯកសារអីតាមខ្លួនដែរឬទេ?

**ឆ៖** អត់ដឹងដែរ ពេលដែលប្រជុំហ្នឹង។

**ស៖** តើនៅពេលដែល នួន ជា ប្រជុំចប់ហ្នឹងលោកធ្លាប់ឃើញគាត់មានយួរឯកសារ ឬក៏យកឯកសារអីត្រឡប់មកភ្នំពេញទេ?

**ឆ៖** ខ្ញុំមិនសូវដឹងដែរ គាត់មានកាបូបរបស់គេ មិនដឹងដែរ។

**ស៖** តើនៅក្នុងឆ្នាំ៧៨ លោកមានដឹងទេថា នួន ជា គាត់ធ្លាប់ធ្វើដំណើរទៅភូមិភាគបូព៌ា?

**ឆ៖** អត់ដឹងដែរ មិនសូវដឹង។

[១៥:២២:៥៩]

**ស៖** តើលោកចាំដែរឬទេ ថាតើនៅពេលណាដែលលោក នួន ជា គាត់ឈប់ធ្វើដំណើរទៅភូមិភាគបូព៌ា? គឺថាគាត់ឈប់ធ្វើដំណើរទៅជួប សោ ភឹម ហ្នឹងនៅពេលណាដែរ?

**ឆ៖** ខ្ញុំអត់ចាំដែរអាហ្នឹង អត់ចាំទេ។

**ស៖** លោកបាននិយាយថា នួន ជា ធ្លាប់ទៅបាត់ដំបង ថាតើពេលគាត់ទៅបាត់ដំបងហ្នឹង គាត់ទៅជួបអ្នកណាដែរ?

**ឆ៖** ជួប តា ញឹម ភូមិភាគ។

**ស៖** តើ នួន ជា ទៅបាត់ដំបូងហ្នឹងញឹកញាប់ដែរឬទេ?

**ឆ៖** វាមិនសូវញឹកទេ ប្រហែលដូចជាទៅបីខែបួនខែទៅម្តង។

**ស៖** តើ នួន ជា ជួបតាញឹម ហ្នឹងជួបនៅកន្លែងណាដែរ?

[១៥:២៤:២៨]

**ឆ៖** ជួបកន្លែង កាលខ្ញុំទៅជួបកន្លែងវត្ត ហៅវត្តអី មិនដឹងដែរ មិនស្គាល់ដែរ វត្តហ្នឹង វត្តគេចោល។

**ស៖** តើវត្តហ្នឹងៗនៅម្តុំណាដែរ?

**ឆ៖** ជិតផ្លូវទៅអង្គរ។ មិនមែនទេ ផ្លូវទៅសៀមរាប។

**ស៖** តើវានៅជិតទីរួមខេត្តបាត់ដំបងទេ?

**ឆ៖** ជិតដែរ។

**ស៖** តើគេប្រើប្រាស់វត្តហ្នឹង ធ្វើអីដែរពេលហ្នឹង តើនៅពេលហ្នឹងមានព្រះសង្ឃ មានអីនៅដែរឬទេ?

**ឆ៖** អត់មានទេ។

**ស៖** តើលោកអាចប្រាប់បានទេ តើវត្តហ្នឹងគេប្រើធ្វើជាទីកន្លែងអីដែរ?

**ឆ៖** វត្តហ្នឹង វត្តគេចោល។

[១៥:២៦:០៦]

**ស៖** តើលោកចាំឈ្មោះវត្តនោះទេ?

**ឆ៖** អត់ស្គាល់ តែអត់ចាំដែរ។

**ស៖** តើ នួន ជា ធ្លាប់ទៅខេត្តបន្ទាយមានជ័យទេ?

**ឆ៖** អត់ អត់ឃើញទៅ។

**ស៖** តើលោកធ្លាប់ឃើញ តាញ៉ឹម ហ្នឹងមកភ្នំពេញទេ ក្រោយពេលជួបជាមួយ នួន ជា ឬក៏ជួបមេដឹកនាំបក្សដឹកនាំបក្សផ្សេងៗ តើ តាញ៉ឹម ហ្នឹង គាត់ធ្លាប់មកភ្នំពេញទេ?

**ឆ៖** តែដល់ខែគាត់មកហើយ។ ដល់ខែប្រជុំគាត់មកហើយ។

**ស៖** នៅពេលដែលគាត់មកភ្នំពេញ ដើម្បីមកភ្ជុំបិណ្ឌហ្នឹង តើគាត់មកប្រហែលរយៈពេលប៉ុន្មានថ្ងៃអីដែរ?

**ឆ៖** បើថាប្រជុំធំខ្លះកន្លះខែ ជួនណា១០ថ្ងៃ អត់កំណត់ទេ។

**ស៖** តើនៅពេលដែលលោកឃើញ តាញ៉ឹម មកភ្នំពេញហ្នឹង លោកឃើញគាត់នៅកន្លែងណាដែរ?

**ឆ៖** គាត់ចូលទៅ ចូល ក១។

[១៥:២៨:១១]

**ស៖** តើគាត់នៅ ក១ រហូត ពេលដែលគាត់មកភ្នំពេញ១០ ទៅ១៥ថ្ងៃហ្នឹង?

**ឆ៖** គាត់មករហូតទាល់តែគាត់ទៅវិញ។

**ស៖** ចុះ សោ ភឹម វិញ តើលោកធ្លាប់ឃើញ សោម ភឹម ហ្នឹងមកភ្នំពេញដើម្បីប្រជុំជាមួយ នួន ជា និងមេដឹកនាំផ្សេងទៀតដែរទេ?

**ឆ៖** ធ្លាប់ចូលប្រជុំនៅ ក១ ជាមួយគ្នាហ្នឹង។

**ស៖** តើ សោ ភឹម មក ក១ ដើម្បីប្រជុំហ្នឹង ញឹកញាប់បែបណាដែរ?

**ឆ៖** ឈរចាំហ្នឹង ជួនកាលពីរបីខែ គាត់មកម្តង។

**សៈ** លោកបាននិយាយផងដែរអំពីតំបន់មួយ គឺខេត្តកំពង់ឆ្នាំង។ តើនៅពេលដែល នួន ជា ទៅកំពង់ឆ្នាំងហ្នឹង គាត់ទៅជួបអ្នកណាដែរនៅកំពង់ឆ្នាំង?

**ឆៈ** កំពង់ឆ្នាំង គ្រាន់តែទៅមើលកន្លែងគេធ្វើស្រែ ភ្លឺស្រែ ភ្លឺអីហ្នឹង។

[១៥:៣០:១៣]

**សៈ** តើលោកធ្លាប់ទៅការដ្ឋានសាងសង់ព្រលានយន្តនៅកំពង់ឆ្នាំងជាមួយ នួន ជា ទេ?

**ឆៈ** អត់ទេ! អត់បានទៅទេ។

**សៈ** តើលោកធ្លាប់ទៅខេត្តកំពង់ស្ពឺជាមួយ នួន ជា ទេ?

**ឆៈ** ធ្លាប់។

**សៈ** តើគាត់បានជួបអ្នកណា នៅពេលដែលគាត់ទៅកំពង់ស្ពឺនោះ?

**ឆៈ** គាត់ទៅជួប តាប៉ាល់។

**សៈ** តើ តាប៉ាល់ នោះគាត់ជាអ្នកណា? គាត់មានឋានៈជាអ្វី?

**ឆៈ** គាត់គណៈតំបន់។

[១៥:៣១:២៤]

**សៈ** តើលោកធ្លាប់ឃើញ នួន ជា ជួបជាមួយមនុស្សម្នាក់ឈ្មោះ ជូ ជេត ដែរឬទេ នៅកំពង់ស្ពឺ?

**ឆៈ** អត់ស្គាល់។

**សៈ** តើនៅកំពង់ស្ពឺហ្នឹង នួន ជា ជួបតាប៉ាល់ ហ្នឹងជួបកន្លែងណា?

**ឆៈ** ជាប់ផ្ទះ គេហៅចំការ ផ្ទះ-- ចំការមន។

**សៈ** សូមលោកពន្យល់ថាតើ ចំការមននោះ ដែលលោកថា ចំការមននៅកំពង់ស្ពឺនោះ នៅកន្លែងណា?

**ឆៈ** នៅក្នុងខេត្តកំពង់ស្ពឺហ្នឹង តាមផ្លូវ។

[១៥:៣២:៥៧]

**សៈ** សូមលោកបំភ្លឺបន្តិច តើលោកចង់និយាយថា “ច្បារមន” ឬក៏ “ចំការមន”? មានពីរពាក្យ “ច្បារមន” ឬក៏ “ចំការមន”?

**ឆៈ** ចំការមនទេ ច្បារមកនៅភ្នំពេញ ចំការមន។

**ស៖** នៅពេលដែល នួន ជា គាត់បានទៅកំពង់ស្ពឺ ឬក៏ទៅភូមិភាគផ្សេងទៀត តើលោកចាំទេ គាត់ទៅចូលរួមក្នុងមហាមីទ្ទិងរបស់ភូមិភាគ ឬក៏អង្គប្រជុំណាមួយដែលពួកកម្មាភិបាលពីតំបន់ ពីភូមិភាគគេចូលរួមទេ?

**ឆ៖** មិនសូវចាំដែរ ព្រោះខ្ញុំនៅយាមខាងក្រៅ។

**ស៖** នៅពេលដែល នួន ជា ធ្វើដំណើរទៅកំពង់ស្ពឺ តើលោកចាំថាគាត់ទៅចូលរួមប្រជុំនៅចម្ការមួយ កន្លែងចម្ការគេដាំដូងហ្នឹងឬទេ?

**ឆ៖** ចម្ការដាំដូងហ្នឹង។

[១៥:៣៤:៣៣]

**ស៖** ថាតើគាត់ទៅកន្លែងហ្នឹងញឹកញាប់ប៉ុនណា? គាត់ទៅប៉ុន្មានដង ទៅកន្លែងចម្ការដូង?

**ឆ៖** ប៉ុន្មានដងមិនសូវចាំដែរ គាត់ទៅប្រហែល ទៅដូចមួយឆ្នាំម្តង ពីរដងប៉ុណ្ណឹងឯង មិនសូវចាំដែរ គាត់ទៅញឹកញាប់ដែរ គាត់ទៅ។

**ស៖** តើចម្ការដូងនោះ ស្ថិតនៅកន្លែងណា ទីតាំង? តើលោកអាចជម្រាបតុលាការពីទីតាំងកន្លែងនោះបានទេ?

**ឆ៖** អត់បានដែរ អត់ចំណាំដែរ។ ចម្ការដាំដូងជុំវិញផ្ទះថ្មហ្នឹងឯង តាមខ្ញុំឃើញ។ ផ្ទះច្បារមន- - អំ ចម្ការមន។

**ស៖** ថាតើនេះជាផ្ទះមួយ ដែលគាត់ទៅជួប តាប៉ាល់ ទេ ដែលថាផ្ទះថ្មហ្នឹងនោះ?

**ឆ៖** ផ្ទះថ្មហ្នឹងជាផ្ទះ ជាហៅថា ផ្ទះជ័យភណ្ឌ ផ្ទះស្អី ខ្ញុំមិនស្គាល់ដែរណ៎ា។ ផ្ទះពួកជំនាន់ព្រោះយើងដេញ លន់ នល់ ចេញ។ ខ្ញុំមិនដឹងដែរ មិនដឹងផ្ទះពីណា។

**ស៖** តើលោកអាចប្រាប់ខ្ញុំបានទេ ថាអ្នកណាខ្លះ ដែលចូលរួមនៅក្នុងប្រជុំ នៅកន្លែងចម្ការដូងនោះ?

**ឆ៖** ខ្ញុំអត់ស្គាល់ដែរ។ ព្រោះមានកម្មាភិបាលខ្លះក្រោមៗ ខ្ញុំអត់ដឹងអី អត់ចំណាំដែរ មានច្រើនដែរ បួនដប់នាក់អ៊ីចឹងទៅ ប៉ុន្តែខ្ញុំអត់ស្គាល់គេ។

[១៥:៣៦:៥៩]

**ស៖** តើលោកចាំទេ ថាតើ នួន ជា បានថ្លែងសុន្ទរកថានៅក្នុងការប្រជុំនោះនោះបាទ?

**ឆ៖** ខ្ញុំអត់ដឹងដែរ។

**ស៖** តើ នួន ជា-- តើលោកធ្លាប់ទៅជាមួយ នួន ជា ទៅកំពង់ត្រឡាចថ្មីទេ នៅក្នុងខេត្តកំពង់ឆ្នាំង?

**ឆ៖** អត់ដែលទៅផង។ អត់ស្គាល់។

**ស៖** តើលោកធ្លាប់ទៅជាមួយគាត់ ទៅឃុំពាមទេ កាលពីសម័យនោះ?

**ឆ៖** អត់បានទៅជាមួយ។

**ស៖** តើ តាប៉ាល់ ក៏បានមកភ្នំពេញមកជួបជាមួយលោក នួន ជា និងមេដឹកនាំបក្ស ដែរឬទេ?

**ឆ៖** ធ្លាប់មកដែរ។

**ស៖** តើគាត់មកប៉ុន្មានដង? ហើយលោកបានឃើញ តាប៉ាល់ មកភ្នំពេញហ្នឹងប៉ុន្មានដងញឹកញាប់ប៉ុនណា?

**ឆ៖** អាហ្នឹងអត់សូវចាំដែរ ជួនកាល ខ្ញុំតាមចាំបានពីរបីដងដែរ។

[១៥:៣៩:០៣]

**ស៖** ខ្ញុំបានសួរលោកហើយ អំពីៗដំណើរខ្លះ ទៅទស្សនកិច្ចនៅទំនប់។ តើលោកបានទៅជាមួយ នួន ជា ទៅកំពង់ចាម ហើយបានជួបមេដឹកនាំៗបក្សនៅកំពង់ចាមនោះដែរឬទេ?

**ឆ៖** អង្កាល់នោះ ខ្ញុំអត់បានទៅទេ។

**ស៖** តើលោកធ្លាប់ទៅជាមួយ នួន ជា ទៅខេត្តក្រចេះ ដែរឬទេ?

**ឆ៖** អត់។

**ស៖** តើលោកធ្លាប់ទៅជាមួយគាត់ទៅមណ្ឌលគិរី ឬរតនគិរី ដែរឬទេ?

**ឆ៖** គាត់មិនដែលទៅនោះទេ។

**ស៖** តើអំពីខេត្តសៀមរាបវិញ តើគាត់ធ្លាប់ទៅខេត្តសៀមរាបទេ?

**ឆ៖** នោះក៏អត់។ មិនបានទៅទេ ក្រែងលោគាត់ទៅម្នាក់គាត់មិនដឹងទេណា ខ្ញុំមិនបានទៅជាមួយ។

[១៥:៤០:៥១]

**ស៖** នៅក្នុងសម័យដែលលោកធ្វើការជាមួយ នួន ជា តើលោកធ្លាប់ឮគាត់និយាយអ្វីអំពីវៀតណាមដែរឬទេ?

**ឆ៖** អត់ដែលឮនិយាយ ឮនិយាយតែថា ថាវៀតណាមឈ្លានពាននៅខាងកើតហ្នឹងប៉ុណ្ណឹង។

**ស៖** តើលោកបានឮគាត់និយាយអំពីការឈ្លានពានរបស់វៀតណាមហ្នឹង លោកឮគាត់និយាយនៅកន្លែងណា?

**ឆ៖** អាហ្នឹងគេផ្សាយទូទៅ កន្លែងណាក៏គេផ្សាយទូទៅដែរ។

**ស៖** ខ្ញុំចង់ឲ្យលោកបញ្ជាក់ឲ្យច្បាស់។ តើលោកឮ នួន ជា និយាយអំពីការឈ្លានពានរបស់វៀតណាម តាមការផ្សាយវិទ្យុដែរឬទេ?

**ឆ៖** តាមស្ដាប់វិទ្យុ។

**ស៖** តើលោកនៅចាំទេឆ្នាំណាដែលមានការផ្សាយបែបនោះ?

**ឆ៖** ចាដែលឆ្នាំ៧៣-៧៤ នេះឯង អ្ហ៎ មិនមែនទេ មិនមែន៧៤ទេ ៧៦-៧៧។

[១៥:៤២:៥៥]

**ស៖** តើលោកបានស្ដាប់ឮលោក នួន ជា និយាយសំឡេងគាត់តាមវិទ្យុនៅឱកាសណាផ្សេងទៀតទេ ឬក៏ឮតែម្ដងពីរដងហ្នឹង?

**ឆ៖** អត់ដែលឮទេ ឮតាមផ្សាយអ្នកផ្សាយវិទ្យុ។

**ស៖** តើនៅកន្លែងណាដែលលោកតែងតែបានឮការផ្សាយវិទ្យុ នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ? តើលោកត្រូវទៅកន្លែងណាមួយ ដើម្បីស្ដាប់រ៉ាឌីយ៉ូ ឬក៏នៅកន្លែងណា?

**លោក អេនគ្រូ អ៊ីនួហ្ស៊ី៖**

ខ្ញុំសូមជំទាស់លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាល-- សាក្សីកុំអាលឆ្លើយ! សូមអញ្ជើញលោកមេធាវី!

**លោក អេនគ្រូ អ៊ីនួហ្ស៊ី៖**

ខ្ញុំឮសាក្សីនិយាយថា គាត់ឮតែម្ដងទេ ហើយៗសហព្រះរាជអាជ្ញាបានលើកគំនិតថា គាត់បានឮវិទ្យុផ្សាយហ្នឹងពីរដង ឬបីដង។ ដូច្នេះ សូមឲ្យលោកសហព្រះរាជអាជ្ញាបញ្ជាក់ឡើងវិញ។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំមិនបាននិយាយអំពីការផ្សាយតាមវិទ្យុទេ។ ខ្ញុំសួរគាត់អំពីឮ នួន ជា និយាយ ហើយខ្ញុំក៏សួរគាត់ថា តើគេអាចស្ដាប់វិទ្យុ រ៉ាដ្យូ សម័យកម្ពុជាប្រជាធិបតេយ្យហ្នឹង គេតែងតែស្ដាប់កន្លែងណា?

**លោក អេនគ្រូ អ៊ីនួហ្ស៊ី៖**

ក្នុងករណីនេះ មិនមានការជំទាស់ទេបាទ។

**ប្រធានអង្គជំនុំ៖**

សាក្សីអាចឆ្លើយតបទៅនឹងសំណួរ ដែលសួរចុងក្រោយដោយសហព្រះរាជអាជ្ញាអម្បាញ់មិញនេះ។

តំណាងសហព្រះរាជអាជ្ញា តាំងសំណួរសាជាថ្មីម្តងទៀត ព្រោះទំនងជាសាក្សីភ្លេចសំណួរដែលលោកសួរហើយ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** បាទ សំណួររបស់ខ្ញុំគឺថា តើបើលោកចង់ស្តាប់ការផ្សាយវិទ្យុ នៅសម័យកម្ពុជាប្រជាធិបតេយ្យនោះ លោកត្រូវទៅស្តាប់នៅកន្លែងណា?

**លោក សូត្រ ទឿង៖**

**ឆ៖** កាលនុំងតាមគេមានវិទ្យុស្តាប់តាមគេ បើកាលនោះដាក់វិទ្យុរួម ស្តាប់វិទ្យុតាមវិទ្យុហ្នឹង។

**ស៖** ថាតើមានទីកន្លែងណាផ្សេងដែលគេចាក់មីក្រូ ដើម្បីគេចាក់ផ្សាយឲ្យប្រជាជនមកស្តាប់ដែរឬទេ ឬក៏យ៉ាងម៉េច? លោកអាចប្រាប់តុលាការបានទេ។

**ឆ៖** ដូចអត់មាន។

[១៥:៤៦:៣៥]

**ស៖** តើលោកធ្លាប់ធ្វើដំណើរជាមួយ នួន ជា ទៅក្រៅប្រទេសកម្ពុជាដែរឬទេ? នៅកន្លែងណាក្រៅប្រទេសកម្ពុជានោះណ៎ា?

**ឆ៖** ទៅចិន។

**ស៖** តើលោកធ្វើដំណើរជាមួយគាត់ទៅក្រៅប្រទេសប៉ុន្មានដង? ទៅតែម្តង ឬក៏ច្រើនជាងម្តង?

**ឆ៖** ម្តង។

**ស៖** ខ្ញុំសូមអនុញ្ញាតសួរឡើងវិញលោកប្រធាន។ តើលោកបានធ្វើដំណើរទៅជាមួយលោក នួន ជា តែមួយជើង មួយម្តង ឬក៏ច្រើនដង? ដែលថាទៅក្រៅប្រទេសកម្ពុជានោះណ៎ា?

**ឆ៖** ទៅពីកម្ពុជាទៅចិន? ពីរដង អ៎ ម្តង។

**ស៖** តើដំណើរហ្នឹងទៅតែប្រទេសចិនតែមួយ ឬក៏ក្នុងដំណើរតែម្តងហ្នឹងទៅប្រទេសផ្សេងក្រៅ

ពីប្រទេសចិនដែរឬទេ?

**ឆ៖** ទៅកូរ៉េ។

[១៥:៤៨:២៨]

**ស៖** នៅពេលដែលលោកនិយាយថា កូរ៉េ តើកូរ៉េ មួយណា? កូរ៉េខាងជើង ឬក៏ខាងត្បូង?

**ឆ៖** កូរ៉េខាងជើង។

**ស៖** តើដំណើរដែលលោកទៅជាមួយលោក នួន ជា ទៅចិន ហើយទៅ កូរ៉េខាងជើងហ្នឹង អស់រយៈពេលប៉ុន្មានដែរ?

**ឆ៖** ប្រហែលមួយអាទិត្យ។

**ស៖** តើមួយសប្ដាហ៍ពេញ ឬក៏មួយដំណើរហ្នឹងទាំងអស់មួយអាទិត្យ ឬក៏ប្រទេសមួយមួយអាទិត្យ?

**ឆ៖** ប្រទេសមួយ មួយអាទិត្យ។

[១៥:៤៩:៣១]

**ស៖** ចាតើមានអង្គរក្ស ឬនីរសារទៅជាមួយលោកហ្នឹងមានប៉ុន្មាននាក់ ដែលថាទៅប្រទេសចិន និងទៅកូរ៉េខាងជើងនោះ?

**ឆ៖** អង្គរក្សគាត់មានបីនាក់នឹងខ្ញុំហ្នឹងមាន សុទ្ធ មានណាភ្លេចបាត់ហើយ។ បីនាក់ ខ្ញុំភ្លេចដែរ។

ស៖ ចាតើលោកធ្វើដំណើរពីប្រទេសកម្ពុជាទៅចិន ទៅកូរ៉េនោះធ្វើដំណើរតាមមធ្យោបាយអ្វីដែរ បានន័យថាជិះអ្វី?

**ឆ៖** យន្តហោះប៊ូអ៊ីង។

**ស៖** ចាតើលោកដឹងទេកប៉ាល់ហោះប៊ូអ៊ីងហ្នឹងជារបស់អ្នកណា? ជារបស់កម្ពុជាប្រជាធិបតេយ្យឬ?

**ឆ៖** របស់ចិន។

**ស៖** តើដំណើរនេះជាលើកទីមួយសម្រាប់លោកដែលថាទៅក្រៅប្រទេសកម្ពុជាឬ?

**ឆ៖** លើកទីមួយ មិនដែលទៅទេ។

[១៥:៥០:១៧]

**ស៖** ចាតើ--

**អ្នកបកប្រែ៖**

លោកប្រធានសូមឲ្យសហព្រះរាជអាជ្ញាសួរម្តងទៀត អ្នកបកប្រែស្តាប់មិនទាន់ឃ្លាខ្លីបាទ?

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** បាទ នេះជាលើកទីមួយដែលលោកបានឃើញយន្តហោះដែរឬទេ?

**លោក សូត្រ ទឿង៖**

**ឆ៖** លើកទីមួយទៅយន្តទៅហ្នឹង។

**ស៖** តើលោកនៅចាំទេថា នៅក្នុងគណៈប្រតិភូនោះមានមនុស្សប៉ុន្មាននាក់នៅជាមួយនឹង? ថាតើយន្តហោះនោះមានមនុស្សជិះពេញដែរឬទេ?

**ឆ៖** មនុស្សជិះពេញ មិនដឹងអ្នកណាខ្លះ ភ្ញៀវបរទេសទៅផង។

**ស៖** តើលោកនៅចាំឈ្មោះមនុស្សផ្សេងទៀត ដែលតំណាងឲ្យកម្ពុជាប្រជាធិបតេយ្យទេនៅក្នុងដំណើរមួយនេះនោះ?

**ឆ៖** ខ្ញុំភ្លេចដែរ ពីរនាក់ គណៈតំបន់ម្នាក់អត់ចាំឈ្មោះទេ។ ស្រីម្នាក់ ប្រុសម្នាក់។

[១៥:៥៣:០០]

**ស៖** តើលោកចាំទេថា តើដែលថា អ្នកដែលលេខាតំបន់ ឬក៏ភូមិភាគដែលមកនោះមកពីភូមិភាគ ឬក៏តំបន់ណាដែលទៅជាមួយហ្នឹង?

**ឆ៖** អត់ចាំដែរ អត់ចាំ។

**ស៖** នៅពេលដែលចេញដំណើរទៅហ្នឹង គឺចេញដំណើរពីណា? ចេញពីព្រលានយន្តហោះពោធិ៍ចិនតុង ឬក៏ចេញពីកន្លែងណា?

**ឆ៖** ពីពោធិ៍ចិនតុង។

**ស៖** តើលោកនៅចាំទេថាៗ តើមានក្រុមអ្នកមេដឹកនាំមួយចំនួនដែលថា ទៅជូនដំណើរគណៈប្រតិភូទៅចិន ទៅកូរ៉េ តើលោកនៅចាំទេ? បានឃើញទេ?

**ឆ៖** អត់បានចាំ អត់ឃើញទេ កម្លាំងគេផ្សេង។

[១៥:៥៤:២៧]

**លោក ឌេល លីសាក់៖**

លោកប្រធាន ដើម្បីជួយឲ្យសាក្សីចងចាំនៅពេលនេះ ខ្ញុំសូមបង្ហាញជូនគាត់នូវឯកសារមួយ

ដែល E3/76 ពីមុននៅក្នុងសំណុំរឿងគឺឯកសារ D262.45 ហើយនិងផ្នែកនៃឯកសារនេះដែលខ្ញុំចង់បង្ហាញឲ្យសាក្សី-- សួរសាក្សីនោះគឺនៅខ្មែរ ERN 00701871 រហូតទៅដល់ 7017872, អង់គ្លេស ERN 00170340 ហើយបារាំង ERN 00701861។ ហើយជា--នៅកញ្ញា ទី២ ឆ្នាំ១៩៧៨ ជាវិទ្យុផ្សាយព័ត៌មានក្នុងស្រុក និយាយថា "នួន ជា ដឹកនាំគណៈប្រតិភូចាកចេញ ដំណើរទៅសាធារណរដ្ឋប្រជាមា-- អ្វី ប្រទេសចិន"។ ហើយខ្ញុំសូមអនុញ្ញាតជូនឯកសារលើក្រដាសជូនលោកសាក្សី ហើយនិងសូមបង្ហាញឯកសារនៅលើអេក្រង់ផងដែរ លោកប្រធានបាទ។

[១៥:៥៦:០៨]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីតំណាងសហព្រះរាជអាជ្ញាដើម្បីយកទៅជូនសាក្សីពិនិត្យ!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោក សួត្រ ទៀង តើលោកអាចអានទំព័រទីមួយនៃឯកសារនេះបានដែរឬទេ ឬក៏លោកចង់ឲ្យខ្ញុំអានឲ្យលោកស្តាប់វិញបាទ?

**លោក សួត្រ ទៀង៖**

**ឆ៖** អានឲ្យស្តាប់វិញ ខ្ញុំអត់ចេះអាន។

**ស៖** អត្ថបទនោះនៃឯកសាររបាយការណ៍ថ្ងៃទី២ កញ្ញា ឆ្នាំ១៩៧៨ និយាយដូចខាងក្រោមនេះសេចក្តីដកស្រង់ "នៅថ្ងៃទី២ ខែកញ្ញា នៅម៉ោង១៣ គណៈប្រតិភូសភាតំណាងប្រជាជនកម្ពុជាដឹកនាំដោយសមមិត្តនួន ជា អនុលេខានៃគណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា និងជាប្រធានគណៈអចិន្ត្រៃយ៍សភាតំណាងប្រជាជនកម្ពុជា បានចាកចេញពីទីក្រុងភ្នំពេញតាមផ្លូវអាកាស ដើម្បីធ្វើដំណើរការទស្សនកិច្ចផ្លូវការជាមួយ-- ជាមិត្តភាពមួយទៅកាន់សាធារណរដ្ឋប្រជាមានិតចិន តាមការអញ្ជើញរបស់សភាប្រជាជនប្រជាមានិតចិន។ សមមិត្តខៀវ សំផន គណៈប្រធានរដ្ឋ, សមមិត្ត អៀង សារី ឧបនាយករដ្ឋមន្ត្រីការបរទេស, សមមិត្ត វន វ៉េត ឧបនាយករដ្ឋមន្ត្រីកិច្ចការសេដ្ឋកិច្ច, សមមិត្ត ជួន ជឿន រដ្ឋមន្ត្រីសុខាភិបាលសាធារណៈ, សមមិត្ត អៀង ធីរិទ្ធ រដ្ឋមន្ត្រីសង្គមកិច្ច, សមមិត្ត យុន យ៉ាត រដ្ឋមន្ត្រីឃោសនាការ អប់រំ និងវប្បធម៌ និងកម្មាភិបាលជាច្រើនរូបទៀតមកពីក្រសួង និងមន្ទីរនានាមានវត្តមានចូលរួមជូនដំណើរ និងជូនពរឲ្យដំណើរទស្សនកិច្ចរបស់សមមិត្តប្រធាន នួន ជា និងគណៈ

ប្រតិភូរបស់លោកទទួលបានជោគជ័យ"។

សំណួរទីមួយរបស់ខ្ញុំសម្រាប់លោកនោះ បាទ តើព័ត៌មាននេះធ្វើឲ្យលោកនឹកឃើញទេ អំពីរយៈពេលដែលលោកទៅធ្វើដំណើរទៅជាមួយនួន ជា ទៅប្រទេសចិននោះ? តើលោកបានចាកចេញៗដំណើរហ្នឹងនៅថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៧៨ មែនឬទេ?

**ឆ៖** មែន។

[១៥:៥៩:២៨]

**ស៖** លោកនៅចាំទេថាបញ្ជីឈ្មោះដែលខ្ញុំបានអានហ្នឹង គាត់បានវត្តមាននៅព្រលានយន្តហោះដើម្បីជូនដំណើរដល់គណៈប្រតិភូដែរឬទេ?

**ឆ៖** អត់ អត់បានជូនទេ។

**ស៖** នៅក្នុងរយៈពេលដែលលោកធ្វើការឲ្យលោក នួន ជា តើលោកបានឃើញលោក អៀង សារី ឬលោក ខៀវ សំផន ហ្នឹងញឹកញាប់ប៉ុនណាដែរ?

**ឆ៖** គាត់មកដែរ យូរៗមកម្តង។

**ស៖** តើពួកគាត់តែងតែមកកន្លែងណា ដែលលោកតែងតែបានឃើញពួកគាត់នោះ?

**ឆ៖** ទៅកន្លែង ក១។

**ស៖** ខ្ញុំសូមសួរសំណួរពីរបីទៀត អំពីដំណើររបស់លោកទៅចិន ហើយនិងទៅកូរ៉េខាងជើង។ តើលោកចាំកន្លែងទីមួយដែលលោកបានទៅមើលទេ បន្ទាប់ពីចេញដំណើរពីកម្ពុជានៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៧៨? កន្លែងទីមួយដែលលោកបានទៅនុ៎ង លោកចាំទេឈ្មោះកន្លែងអី?

**ឆ៖** ខ្ញុំចាំតែចុះក្រុងប៉េកាំង ហើយនិងរយៈមីទិ្ទង គាត់ដើរទស្សនកិច្ចតាមជនបទ។

[១៦:០១:៤៥]

**ស៖** នៅពេលដែលយន្តហោះចុះនៅព្រលានយន្តហោះនៅប៉េកាំង តើមានក្រុមមេដឹកនាំចិនមកទទួល មកជួបក្រុមប្រតិភូពីខាងលោកដែរឬទេ ពីខាងកម្ពុជា?

**ឆ៖** មាន។

**ស៖** បាទ បន្ថែមនូវការទៅទស្សនកិច្ចនៅជនបទ តើលោក នួន ជា ធ្វើអ្វីខ្លះនៅក្នុងការធ្វើទស្សនកិច្ចនេះ នៅប៉េកាំង ហើយនិងនៅកូរ៉េខាងជើងនោះ?

**ឆ៖** ទៅប៉េកាំង គាត់ទៅមើលរោងចក្រនៃ ចាក់ដែក រោងចក្រនៃ បំពង់ទីប ហើយនិងទៅ

មើលអាកន្លែងធ្វើស្រែ និងផ្តែឈើ ប៉ុណ្ណឹងឯង។

[១៦:០២:៥៣]

**ស៖** តើលោកបានទៅមើលផ្ទះរបស់ ម៉ៅ សេទុង ដែរឬទេ?

**ឆ៖** បានទៅមើលដែរ។

**ស៖** តើមេដឹកនាំប្រទេសចិនជាអ្នកទទួលពិធី *បង់កេ* បានន័យថាជប់លៀងទៅគណៈប្រតិភូរបស់លោក នួន ជា ដែរឬទេ?

**ឆ៖** មាន។

**ស៖** តើលោកបានចូលរួមនៅក្នុងពិធី *បង់កេ* ពិធីជប់លៀងហ្នឹងដែរឬទេ?

**ឆ៖** បានចូលរួមដែរ។

**ស៖** តើលោកនៅចាំទីកន្លែងណាផ្សេងទៀត ដែលគេរៀបចំពិធីជប់លៀងឲ្យគណៈប្រតិភូនៅពេលដែលលោកធ្វើដំណើរនៅទៅប្រទេសចិនហ្នឹង? តើលោកមានចាំកន្លែងផ្សេងទេ?

[១៦:០៣:៥៨]

**ឆ៖** ខ្ញុំអត់ចាំដែរ បានតែពីរកន្លែង មិនដឹងទៅណា។

**ស៖** តើលោកនៅចាំថា ពិធីជប់លៀងស្វាគមន៍គេៗរៀបចំនៅ មហាវិមានប្រជាជន នៅពេលដែលលោកទៅដល់ប្រទេសចិននោះ?

**លោក អេនគ្រូ អ៊ីន្ទូហ្ស៊ី៖**

លោកប្រធានខ្ញុំសូមអនុញ្ញាតជំទាស់

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលឆ្លើយតប។ សូមៗអញ្ជើញ!

**លោក អេនគ្រូ អ៊ីន្ទូហ្ស៊ី៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតជំទាស់។

**ប្រធានអង្គជំនុំ៖**

បាទៗ។

**លោក អេនគ្រូ អ៊ីន្ទូហ្ស៊ី៖**

ដូចដែលខ្ញុំសូមអភ័យទោស សូមអភ័យទោសដែលថា សហព្រះរាជអាជ្ញាហាក់ដូចជាងាកឆ្ងាយ

ពេកពីទិសដៅ។ បានន័យថា គាត់ទៅសួរសាក្សីអំពីពិធីជប់លៀង*បង់កេ* ផ្សេងដែរថាៗ ប្រាសចាកអំពីគោលដៅនេះឆ្ងាយបន្តិចបាទ។

**លោក ខេល លីសាក់៖**

ខ្ញុំសូមអនុញ្ញាតឆ្លើយលោកប្រធាន មេធាវីការពារក្តីរបស់លោក នួន ជា គាត់មិនមានបានឯកភាពទៅលើអង្គហេតុ-- យល់ស្របទៅលើអង្គហេតុនោះទេ។ ប៉ុន្តែខ្ញុំត្រូវដេញដោលលម្អិតទៅលើដំណើរនេះ ដែលអាចនឹងបញ្ជាក់ដោយរបាយការណ៍ព័ត៌មានមួយចំនួន ដើម្បីឲ្យៗក្រុម នួន ជា អាចនឹងជំទាស់ទៅនឹងសក្ខីកម្មរបស់សាក្សីនេះ។ នេះគឺជាការច្បាស់ណាស់ ដើម្បីឲ្យមានព័ត៌មានគ្រប់គ្រាន់ឲ្យៗច្បាស់លាស់គ្រប់គ្រាន់។ នេះហើយ ជាមូលហេតុដែលខ្ញុំបាទសួរសាក្សីអំពីសកម្មភាពនានារបស់ នួន ជា នៅក្នុងពិធីជប់លៀង ក្នុងអំឡុងពេលដែលគាត់ធ្វើទស្សនកិច្ចទៅប្រទេសចិន ទាក់ទងទៅនឹងតួនាទី ហើយនិងការភារកិច្ចរបស់គាត់ នៅក្នុងករណី ដែលយើងនឹងជំនុំជម្រះ។

**លោក អេនទ្រូ អ៊ីនូហ្វ៊ី៖**

ខ្ញុំមិនជំទាស់ចំណុចចុងក្រោយនេះទេ ប៉ុន្តែចំណុចមួយចំនួន គឺថាមិនពាក់ព័ន្ធទៅនឹងប្រព័ន្ធទំនាក់ទំនងនៃអង្គហេតុដែលយើងនិយាយទេ។ ខ្ញុំមិនគិតថា ជាការសំខាន់ដែលថាសួរទៅសាក្សីអំពីចំណុចលម្អិតតូចៗ ដែលថាគាត់មិនឆ្លើយពីមុន។ ដូច្នេះ សហព្រះរាជអាជ្ញាគប្បីតែឈរទៅលើកម្រិតដែលបានកំណត់ ដោយអង្គជំនុំជម្រះ។ បើសិនជាបន្តបែបនេះ ខ្ញុំមិនដឹងថា ត្រូវប្រើពេលយូរប៉ុនណាទៀតនោះទេ។ លោកប្រធាន លោក លោកស្រីចៅក្រម។

[១៦:០៦:២៥]

**លោក ខេល លីសាក់៖**

ខ្ញុំសូមអនុញ្ញាតលើកឡើងនូវការកត់សម្គាល់។ ខ្ញុំយល់ថា សហមេធាវីលើកឡើងនូវបញ្ហាដែលមិនពាក់ព័ន្ធហ្នឹង គឺចំណុចនេះទេ។ ប៉ុន្តែគឺយើងមានលទ្ធភាពដើម្បីនឹងសួរអំពីវិសាលភាពទាក់ទងទៅនឹងតួនាទីរបស់ជនជាប់ចោទនៅទីនេះ គឺតួនាទីរបស់ នួន ជា ក្នុងឋានៈជាតំណាងរបស់កម្ពុជាប្រជាធិបតេយ្យដែលជាតួនាទីក្នុងដំណើរផ្លូវការរបស់គាត់ទៅប្រទេសចិន។

**ប្រធានអង្គជំនុំ៖**

ការជំទាស់របស់មេធាវីការពារក្តី នួន ជា ចំពោះសំណួរចុងក្រោយ ដែលតំណាងសហព្រះរាជអាជ្ញាអន្តរជាតិសួរទៅសាក្សីនោះ គឺមានប្រសិទ្ធភាព។ ដូច្នេះ សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរចុង

ក្រោយដែលសួរឡើងតំណាងសហព្រះរាជអាជ្ញាអន្តរជាតិនោះទេ។

បាទ ឥឡូវពេលវេលាសមល្មមនឹងសម្រាកហើយ សម្រាប់កិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។ ប៉ុន្តែមុននឹងប្រកាសផ្អាកកិច្ចដំណើរការសវនាការ អង្គជំនុំជម្រះចង់ដឹងថា តើតំណាងសហព្រះរាជអាជ្ញាត្រូវការពេលវេលាប៉ុន្មានទៀត ក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ? ដើម្បីឲ្យអង្គជំនុំជម្រះនឹង មានមូលដ្ឋានក្នុងការដោះស្រាយទៅលើសំណើសុំរបស់ក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានលើកឡើងនៅក្នុងអំឡុងពេល ដែលអង្គជំនុំជម្រះចូលមកចាប់ផ្តើមកិច្ចដំណើរការសវនាការដេញដោលនៅរសៀលនេះ។

[១៦:០៧:៥៩]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ដោយសន្មតថា យើងថាមានសំណួរតិចតួចសួរសាក្សីព្រឹកនេះ ហើយខ្ញុំប្រហែលជា១ យើងបានប្រើពេលដប់ប្រាំនាទី។ ហើយយើងអាចនឹងធ្វើការបាននៅក្នុងពេលដែលបានកំណត់ជូន។ ខ្ញុំគិតថា ខ្ញុំអាចបញ្ចប់នៅពេលល្ងាចថ្ងៃស្អែក។ នឹងមានន័យថា សហព្រះរាជអាជ្ញាអាចនឹងសុំពេលប្រហែលជាមួយថ្ងៃថែម។ ដោយសន្និដ្ឋានថា មួយថ្ងៃកន្លះមិនរាប់បញ្ចូលមួយព្រឹកពេញថ្ងៃនេះ ដែលថាយើងបានប្រើពេលតែបន្តិចប៉ុណ្ណោះ ព្រឹកនេះប្រហែលជាដប់ប្រាំនាទី។ អ៊ីចឹង គឺថាយើង-- ខ្ញុំអាចនឹងបញ្ចប់នៅមុនពេល-- នៅម៉ោងពិសាអាហារថ្ងៃត្រង់ ថ្ងៃស្អែក បាទ។

[១៦:០៩:០៤]

*(ចៅក្រមពិភាក្សាគ្នា)*

[១៦:០៩:២១]

**ប្រធានអង្គជំនុំ៖**

ម៉េចទៅតំណាងក្រុមមេធាវី-- នាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវការពេលវេលាប៉ុន្មានដែរទៅ ក្នុងការសួរដេញដោលសាក្សីរូបនេះ?

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន យើងត្រូវការពេលយ៉ាងតិចបំផុត គឺពីរម៉ោង ហើយអាចទៅដល់បីម៉ោង។

**ប្រធានអង្គជំនុំ៖**

ចុះខាងភាគីការពារក្តីវិញ លោក-- ពីមេធាវី នួន ជា មុន។

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

សូមអរគុណលោកប្រធាន។ យើងត្រូវការពេលប្រហែលកន្លះថ្ងៃ។ បាទ គឺជាមួយនឹងលោក សុន អរុណ ហើយនិងខ្ញុំ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ចុះខាងមេធាវីការពារក្តីលោក អៀង សារី?

**លោក អាង ឧត្តម៖**

យើងខ្ញុំប្រើពេលប្រហែលជាមួយម៉ោង ឬជាងមួយម៉ោងបន្តិចបន្តួចយើងព្យាយាមបាទ។

[១៦:១០:៣១]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើននូវការផ្តល់ព័ត៌មានរបស់លោកមេធាវី។ ចុងក្រោយ លោកមេធាវី ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន?

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ យើងត្រូវការពេលប្រហែលជាមួយម៉ោង ឬក៏អាចតិចជាងនេះបាទ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើននូវការផ្តល់នូវព័ត៌មាន ស្តីពីពេលវេលាក្នុងការដេញដោលសាក្សីរូបនេះ។

ឥឡូវនេះ ពេលវេលាសមល្មមនឹងសម្រាកហើយ ដូច្នេះអង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ការសួរដេញដោលសាក្សី ស្វូត្រ ទឿង សម្រាប់ថ្ងៃនេះត្រឹមនេះ។ ហើយកិច្ចដំណើរការនីតិវិធីក្នុងការពិភាក្សាសួរដេញដោលសាក្សីរូបនេះ បន្តទៅទៀតនៅថ្ងៃស្អែក ហើយនិងចាំបាច់គឺយើងធ្វើនៅថ្ងៃខានស្អែក ថ្ងៃសុក្រទៀត ដើម្បីឲ្យចប់នូវកិច្ចដំណើរការសវនាការនេះ។ ដូច្នេះ លោក ស្វូត្រ ទឿង អង្គជំនុំជម្រះនឹងអញ្ជើញលោកមកផ្តល់ បន្តផ្តល់សក្ខីកម្មទៀតនៅថ្ងៃស្អែកចាប់ពីម៉ោងប្រាំបួនព្រឹក ហើយទន្ទឹមនេះដែរ ក៏សូមអញ្ជើញលោកមេធាវីប្រឹក្សាសាក្សីក៏ដូចគ្នា សូមលោកអញ្ជើញមកអមសាក្សីនៅក្នុងអំឡុងពេលនៃការអង្គជំនុំជំម្រះ-- នៃភាគី ឬអង្គជំនុំជម្រះតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ រហូតដល់ចប់។ ហើយមន្ត្រីរដ្ឋបាលតុលាការឲ្យសម្របសម្រួលសាក្សីរូបនេះទៅជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ដើម្បីផ្តល់មធ្យោបាយទៅមក ហើយនិងកន្លែងស្នាក់នៅ

សមរម្យសម្រាប់គាត់ ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះ នៅព្រឹកថ្ងៃស្អែកឲ្យបានមុន-- ឲ្យបានម៉ោងប្រាំបួនព្រឹក ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំជនជាប់ចោទទាំងបីរូបទៅកាន់មន្ទីរឃុំឃាំង នៃ អ.វ.ត.ក វិញ ហើយនិងឲ្យនាំពួកគាត់មកកាន់បន្ទប់សវនាការនេះ នៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:១៣ នាទី)*